ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរ</u>**
**<u>នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី “ឌុច”</u>**
**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង

**ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩**
**សវនាការលើកទី២៩**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍
*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង
លោក ម៉ាត្ទូ គ្រីស្ពារ *(Mr. Matteo Crippa)*
លោកស្រី សែ កុលវុឌ្ឍី
កញ្ញា ណាថាក់ វិចស៊ែល
*(Ms. Natacha Wexels-Riser)*
លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េត ចរិយា

លោក វីលៀម ស្មីត *(Mr. William Smith)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំប៉ែល

*(Mr. Zachery Lampell)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ (*François Roux)*

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គង់ ពិសី

លោក ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី អេលីហ្សាប៉ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

*កញ្ញា ចេស្ស៊ីកា ហ្វីណែល (Ms. Jessica FINELLE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី ៖** ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ១០
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្តើមពី ....................ទំព័រ ៤០
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ៥៤

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលវ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គីមសួន | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក វ៉ាបេសាន់ដ្រារាតាណា | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ ហើយជាបន្តនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការដេញដោលលើអង្គហេតុនៃការសួរចម្លើយ និងអង្គហេតុនៃការធ្វើទារុណកម្ម និងវិធីធ្វើទារុណកម្ម ។

មុននឹងដំណើរក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាព អវត្តមាន វត្តមានភាគីដែលត្រូវចូលរួមក្នុងដំណើរនីវិធីសវនាការនៅព្រឹកនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលបានចូលរួមនៅក្នុងដំណើរការនីវិតិធីសវនាការក្នុងថ្ងៃនេះ មានវត្តមានគ្រប់ចំនួន លើកលែងតែមេធាវីការពារជនជាប់ចោទលោក ការ សាវុត្ថ អវត្តមានព្រឹកនេះ ។

**ប្រធានអង្គជំនុំ៖**

អរគុណក្រឡាបញ្ជី ។ លោកមេធាវី ហុង គឹមសួន តើចង់មានយោបល់អ្វីទៅ? សូមអញ្ជើញ ។

**លោក ហុង គឹមសួន៖**

សូមគោរពលោកប្រធាន! ខ្ញុំបាទសូមណែនាំសមាជិកនៅក្នុងក្រុមទីបួន ដែលប្រធានអនុញ្ញាតពីម្សិលមិញ ដែលមានកញ្ញា ចេស្ស៊ីកា ដែលចូលរួមអង្គុយស្តាប់ជំនួសលោក លោក ព្យែរ អូលីវីយេស័រ សូមអញ្ជើញ ។

**លោកស្រី ចេស្ស៊ីកា ហ្វីណែល៖**

*ម៉ែកស៊ី ម៉ាស្យឺប្រេស៊ីដង់* ។

**លោក ហុង គឹមសួន៖**

សូមអរគុណ ។

[០៩:០៧:១៣]

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទមកកាន់ឈើរាងវង់ក្រចកសេះនៅទីនេះ ។

មុននឹងចាប់ផ្តើមធ្វើការដេញដោល អង្គជំនុំជម្រះសូមធ្វើការឆ្លើយតបទៅនឹងសំណើសុំឆ្លើយបញ្ជាក់

របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែលបានលើកឡើងពីម្សិលមិញអំពីគោលបំណង ឬក៏ផែនការនៃដំណើរសវនាការដេញដោលរបស់អង្គជំនុំជម្រះ តើប្រព្រឹត្តទៅរបៀបណារវាងប្រតិបត្តិការនៅមន្ទីរស-២១ ជើងឯក និងប្រតិបត្តិការនៅមន្ទីរសន្តិសុខព្រៃស ។

អង្គជំនុំជម្រះសូមជម្រាបជូនដល់តំណាងសហព្រះរាជអាជ្ញា ព្រមទាំងភាគីជ្រាបថាអង្គជំនុំជម្រះនូវតែប្រកាន់ជំហរ ដូចសេចក្តីសម្រេចដែលបានសម្រេចកាលពីដំបូងនៃការកំណត់ការធ្វើសវនាការគឺបែងចែកដាច់ស្រឡះរវាងអង្គហេតុនៃប្រតិបត្តិការស-២១ រួមទាំងជើងឯក និងប្រតិបត្តិការស-២៤ ដែលយើងហៅថា ម្យ៉ាងទៀតគឺមន្ទីរអប់រំកែប្រែនៅព្រៃស ។ ទីពីរ លំដាប់អង្គហេតុនៃប្រតិបត្តិការ ស-២១ព្រមទាំងជើងឯកនោះ គឺយើងរៀបចំដំណើរការនៃការសួរដេញដោយតាមលំដាប់ដូចខាងក្រោម៖

ទីមួយ គឺការចាប់ខ្លួន ការបញ្ជូនខ្លួន និងការឃុំឃាំង ឬក៏ដាក់គុក ។ នេះយើងបានធ្វើសវនាការកាលពីម្សិលមិញហើយ ។ ទីពីរ ការសួរចម្លើយនិងការធ្វើទារុណកម្មនៅក្នុងរយៈអំឡុងពេលនៃដំណើរដេញដោលអំពីការសួរចម្លើយនិងទារុណកម្មនេះ ក៏មានការពាក់ព័ន្ធទៅនឹងអង្គហេតុតូចៗផ្សេងទៀតដែលមានចែងនៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតដែរ ។ ដូចជាការធ្វើឲ្យទៅជាទាសករ ការរំលោភផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ អំពើអមនុស្សធម៌ និងអំពើផ្សេងៗទៀត ដែលមាននៅក្នុងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ដែលមានមូលដ្ឋាននៃអង្គហេតុចោទប្រកាន់ជាក់លាក់នៅក្នុងដីកាដំណោះស្រាយនោះ ។ ទីបី អំពីការសម្លាប់។ ការសម្លាប់នេះយើងធ្វើបែងចែកជាពីរគឺការសម្លាប់នៅក្នុងមន្ទីរស-២១ និងបរិវេណមន្ទីរស-២១ និងទីពីរ ការសម្លាប់នៅជើងឯក ។

អង្គជំនុំជម្រះក៏សូមជម្រាបដល់ភាគីទាំងអស់បានជ្រាបថា អង្គជំនុំជម្រះបានធ្វើការកំណត់ចំនួនម៉ោងសម្រាប់ភាគីនីមួយៗក្នុងការធ្វើការពិភាក្សាដេញដោលចំពោះអង្គហេតុដែលបានលើកឡើងដូចខាងលើនេះចំពោះជនជាប់ចោទ ។ បីម៉ោងសម្រាប់តំណាងសហព្រះរាជអាជ្ញា បីម៉ោងសម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម បួនម៉ោងសម្រាប់មេធាវីការពារក្តី ។ នេះជាផែនការក្នុងការដំណើរការធ្វើសវនាការនៅក្នុងអង្គហេតុនេះ ។ អ៊ីចឹង សូមអស់លោកលោកស្រីដែលជាភាគីចូលរួមនៅក្នុងដំណើរការនីតិវិធីនៃជ្រាប ។ សូមអញ្ជើញលោក ។

[០៩:១១:៤៦]

**លោក វីលៀម ស្មីត៖**

អរុណសួស្តីលោកលោកស្រីចៅក្រមនិងមេធាវី ! សូមអរគុណចំពោះសេចក្តីណែនាំដើម្បីឲ្យ

ខ្ញុំយល់ឲ្យច្បាស់ គឺវាទាក់ទងទៅនឹងអង្គហេតុនៃការប្រតិបត្តិការស-២១ទាំងមូល ។ សហព្រះរាជអាជ្ញាទទួលបានសេចក្ដីណែនាំទាក់ទងទៅនឹងរយៈពេលកំណត់បីម៉ោង ។ ថាតើត្រឹមត្រូវដែរឬទេ គឺរយៈពេលបីម៉ោងទៅលើចំណុចនេះ? ហើយការចោទសួររបស់សហព្រះរាជអាជ្ញា គឺថាយើងអាចចប់ផ្ដើមនៅថ្ងៃច័ន្ទ ទី២២ ដែរឬទេ ចំពោះការដេញដោលតាងសំណួរនោះ? ដោយសារតែវាទាក់ទងទៅនឹងបញ្ហាពេលវេលាចំពោះយើងខ្ញុំ ។

ដូច្នេះហើយ គឺដើម្បីអនុញ្ញាតឲ្យយើងរៀបចំសំណួររបស់យើងឲ្យមានប្រសិទ្ធភាព ហើយមិនមានភាពជាន់គ្នា ។ ជាពិសេសនោះ សហព្រះរាជអាជ្ញាចង់មានរយៈពេលបន្ថែមនៅពេលដែលលោកចៅក្រមបញ្ចប់ការតាំងសំណួរនៅត្រឹមថ្ងៃស្អែកពេលរសៀល ហើយយើងចង់ដាក់នូវឯកសារមួយចំនួននៅចំពោះមុខជនជាប់ចោទ ។ ឯកសារទាំងអស់នោះ គឺឯកសារដែលមានចំណាររបស់ជនជាប់ចោទ ហើយអាចជួយឲ្យអង្គសវនាការក្នុងការបញ្ជាក់អំពីការចោទប្រកាន់ដូចមានចោទនៅក្នុងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះ ។

សហព្រះរាជអាជ្ញាក៏ចង់ដាក់ជូននូវរូបភាពមួយចំនួន ដែលវាពាក់ព័ន្ធទៅនឹងសកម្មភាពផ្សេងៗរបស់ជនជាប់ចោទនេះ ។ ដូចដែលលោកលោកស្រីចៅក្រមជ្រាបហើយ ការពិនិត្យទៅលើឯកសារនៅក្នុងសវនាការគឺវាមានសារសំខាន់ចំពោះភាគីនិងសហព្រះរាជអាជ្ញា ។ ហើយដើម្បីឲ្យយើងធ្វើឡើងឲ្យមានប្រសិទ្ធភាព ។

ហើយនៅក្នុងថ្ងៃគឺវាជាការអនុវត្តមួយដែលមានភាពស្មុគស្មាញផងដែរ ។ ដូច្នេះសហព្រះរាជអាជ្ញាចង់ធ្វើនោះ គឺដើម្បីផ្ដល់ឲ្យជនជាប់ចោទនិងខាងការពារក្ដីនូវឯកសារថតចម្លើយដែលយើងនឹងយោងតាមការស្នើសុំដាក់នៅក្នុងកិច្ចប្រជុំរៀបចំរបស់យើង ។ ការធ្វើដូច្នេះ គឺដើម្បីអនុញ្ញាតឲ្យយើងមានភាពស្រដៀងគ្នាដែលយើងធ្លាប់ធ្វើនៅក្នុងសំណុំរឿងធំៗរបស់យើង ។ ហើយចំណុចទីពីរ យើងសង្ឃឹមថា យើងនឹងអាចដោះស្រាយបញ្ហាមួយចំនួនដែលបានលើកឡើងទាក់ទងទៅនឹងជំទាស់ផ្សេងៗ។

ហើយយើងខ្ញុំក៏ស្នើសុំលោកលោកស្រីចៅក្រមផងដែរថា ទាក់ទងទៅនឹងរយៈពេលដែលលោកលោកស្រីចៅក្រមបានពិចារណានោះ ប្រសិនបើសហព្រះរាជអាជ្ញា ឬក៏ភាគីគាត់តាំងសំណួរទៅលើចំណុចសំខាន់នៃអង្គហេតុ ។ ហើយយើងខ្ញុំសូមឲ្យមានការពិចារណាធ្វើការពិនិត្យលើរយៈពេលកំណត់នេះ ដោយយើងត្រូវចាំថាចំណុចខ្លះទៅវាមានចំណុចសំខាន់ ហើយវាអាចត្រូវការពេលវេលាច្រើនដែលត្រូវការតាំងសំណួរពីខាងសហព្រះរាជអាជ្ញាទៅលើអង្គហេតុ នៅលើការគាំទ្របូកការដាក់បន្ទុក ឬ

ដោះបន្ទុកផ្សេងៗដែលដាក់ដោយខាងមេធាវីការពារក្តី ។

[០៩:១៥:១០]

ដូច្នេះ យើងដឹងហើយទៅលើចំណុចទាំងអស់នេះ ។ លោកលោកស្រីចៅក្រមដើម្បីឲ្យយើងមានដំណើរការតាំងសំណួរឲ្យមានភាពរលូននោះ គឺយើងស្នើសុំឲ្យមានការពិនិត្យទៅលើប្រតិចារឹកដើម្បីយើងអាចផ្តល់នូវឯកសារផ្សេងៗទៅតាមនុ៎ង ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២០:៤៨]

**ប្រធានអង្គជំនុំ៖**

កាលដែលឡើងរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះយល់ហើយថា ពិតជាមានបញ្ហាដូច្នោះមែន ដោយសារនីតិវិធីនៃការប្រព្រឹត្តិទៅរបស់យើងនេះត្រូវការ ឬក៏បង្ហាញភស្តុតាងជាឯកសារនានា ឬរូបភាពនានាដែលជាខ្សែវីដេអូ ឬក៏ជារូបភាពផ្សេងៗនោះ ពិតជាត្រូវការចំណាយពេលវេលាច្រើនជាងក្នុងករណីដែលសួរធម្មតាមែនហើយ ។ ហើយការធ្វើនោះវាឆ្លុះបញ្ចាំងឲ្យឃើញអំពីទិដ្ឋភាពទាំងឡាយនៅក្នុងសំណុំរឿងនេះ ច្បាស់ជាងការដែលយើងទៅសួរដោយមិនបានបង្ហាញនូវភាពទាំងនោះ ។ ប៉ុន្តែយើងជឿជាក់ថានៅក្នុងអំឡុងពេលនៃការដំណើរការសវនាការនេះ គឺអង្គជំនុំជម្រះនឹងប្រឹងប្រែងឲ្យបានចប់នៅក្នុងពិភាក្សាដេញដោលនៅក្នុងអង្គហេតុនេះ នៅក្នុងថ្ងៃស្អែកនឹងបញ្ចប់នៃកិច្ចការរបស់ខ្លួន ។

អ៊ីចឹងក្នុងអំឡុងពេល ថ្ងៃដែលនៅសល់គឺអង្គជំនុំជម្រះយល់ថាខាងភាគីដែលមានឱកាសគ្រប់គ្រាន់ក្នុងសិក្សាស្រាវជ្រាវហើយនិងកំណត់នូវ ចេញនូវសំណួរទាំងឡាយដែលយើងធានាថាសំណួរនោះមិនជាន់គ្នានឹងសំណួរដែលអង្គជំនុំជម្រះបានសួរនោះទេ ។ បញ្ហាទីពីរ គឺនឹងមានឱកាសក្នុងការរៀបចំនូវឯកសារទាំងឡាយដែលប៉ុនប៉ងក្នុងការបង្ហាញភស្តុតាងនៅពេលដេញដោល នៅក្នុងអំឡុងពេលដេញដោលនោះហើយ ។ ហើយបញ្ហាមួយទៀត នេះជាការកំណត់ពេលម៉ោងជាមូលដ្ឋានមួយដើម្បីឲ្យមានការប្រឹងប្រែង ដើម្បីពន្លឿនក្នុងកិច្ចការនីតិវិធីសវនាការរបស់យើងឲ្យបានឆាប់រហ័ស ។

ក្នុងករណីដែលអង្គជំនុំជម្រះពិនិត្យឃើញថាលទ្ធភាពក្នុងការចាំបាច់ ក្នុងការបង្ហាញភស្តុតាងជាឯកសារនានាដែលអំឡុងពេលការកំណត់ ដូចដែលអង្គជំនុំជម្រះបានសម្រេចបែងចែករួចហើយនេះ ប្រសិនបើចាំបាច់នោះអង្គជំនុំជម្រះនឹងកំណត់ពេល ឬពន្យារពេលដាក់ស្តែងទៅតាមកាលៈទេសៈសម

ស្របដើម្បីឲ្យលទ្ធភាពនៃការបង្ហាញភស្តុតាងរបស់ភាគី នោះគឺអាចធ្វើទៅបានយ៉ាងល្អប្រសើរ ។ នេះជាការដែលណែនាំក្នុងការអនុវត្តនេះ ។ តើលោកតំណាងសហព្រះរាជអាជ្ញាអាចទទួលយកបានទេ បើធ្វើដូច្នេះ? លោកចង់និយាយអីបាទ?

សូមអញ្ជើញលោកស្រីចៅក្រម ។

[០៩:២៣:៣៣]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមិនប្រាកដថាតើការនិយាយជាភាសាខ្មែរហ្នឹង វាមានការកំណត់ច្បាស់លាស់ដែរឬក៏អត់ទេ? ខ្ញុំចង់បញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូង និងអរគុណណាស់ប្រសិនបើឯកសារដែលនឹងត្រូវធ្វើការបែងចែកនោះគឺនឹងត្រូវបានរៀបចំជាមុន ហើយអាចរៀបចំសម្រាប់ផ្តល់ជូនដល់ភាគីពាក់ព័ន្ធនិងផ្តល់ជូនដល់អង្គជំនុំជម្រះនៅក្នុងអំឡុងពេលពីរបីថ្ងៃខាងមុខនេះ ចៀសជាងការទទួលយកឯកសារនៅពេលដែលធ្វើការបង្ហាញតែម្តងនៅក្នុងសវនាការនោះ ។

ហើយចំណុចទីពីរ ខ្ញុំគិតថាយើងនឹងពិនិត្យមើលថាតើការសួរសំណួរនៅថ្ងៃស្អែកហ្នឹងនឹងដំណើរការយ៉ាងដូចម្តេច? ហើយយើងនឹងចេញសេចក្តីសម្រេចចិត្តប្រហែលជានៅថ្ងៃច័ន្ទដែលខាងភាគីពាក់ព័ន្ធនានានឹងអាចសួរសំណួរបាន ។ តើលោកប្រធានយល់ថាជាការសមស្របដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ខ្ញុំយល់ស្របដូច្នេះ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធានហើយនិងលោកស្រីចៅក្រម ។ អ្វីដែលលោកប្រធាននិងលោកស្រីចៅក្រមបាននិយាយគឺច្បាស់លាស់ហើយ ។ ទាក់ទងទៅនឹងការកំណត់ពេលវេលាទោះបីជាយើងពិចារណាទៅលើការបង្ហាញឯកសារក៏ដោយ សម្រាប់ពេលបន្ថែមនោះគឺខាងសហព្រះរាជអាជ្ញាមិនអាចកំណត់អំពីពេលវេលាឲ្យបានពិតប្រាកដ ដើម្បីកំណត់រួមបញ្ចូលទាំងការបង្ហាញឯកសារផងនោះ ។

ដូច្នេះ ខ្ញុំសូមស្នើទៅលោកប្រធានផ្តល់នូវការកំណត់ពេលវេលាសម្រាប់ភាគីនីមួយៗ ប៉ុន្តែគឺមានភាពមួយដែលអាចផ្លាស់ប្តូរបាននៅពេលដែលលោកចៅក្រមបានបញ្ចប់នូវការសួរសំណួរហើយនោះ គឺថាទុកឱកាសឲ្យភាគីពាក់ព័ន្ធនានាផ្តល់នូវឯកសារដែលគេចង់បង្ហាញនៅក្នុងសវនាការ ។ ទាក់ទងទៅនឹងការរៀបចំផែនការ និងការបង្ហាញឯកសារនៅចំពោះមុខអង្គសវនាការនិងដល់ភាគីពាក់ព័ន្ធនានា និង

ការពិនិត្យមើលឯកសារអស់ទាំងនុ៎ង ខ្ញុំសូមស្នើទៅលោកប្រធានថា ក្នុងអំឡុងពេលនៃថ្ងៃសវនាការអាស្រ័យទៅលើនីតិវិធីនៃការធ្វើសវនាការ គឺសូមឲ្យលោកលោកស្រីចៅក្រមផ្តល់ចម្លើយថាតើខាងសហព្រះរាជអាជ្ញាសូមស្នើនៅថ្ងៃស្អែក ឬក៏នៅថ្ងៃច័ន្ទ ពីព្រោះអីការកំណត់នូវបន្ទុកការងារសម្រាប់សហព្រះរាជអាជ្ញានោះ គឺវាមានចំនួនច្រើនណាស់ហើយការបង្ហាញដល់ភាគីនានាក៏អាចនឹងត្រូវស៊ីពេលផងដែរ ។

[០៩:២៦:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានមតិពីរដែលខ្ញុំចង់បញ្ចេញ ។ ដំបូងខ្ញុំសូមបញ្ចេញនូវភាពភ្ញាក់ផ្អើររបស់ខ្ញុំ ដែលថា ខាងការិយាល័យសហព្រះរាជអាជ្ញាបានមតិរបស់ខ្លួន ហើយនិងព្រមទាំងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ដែលពួកគេបង្ហាញនូវការទុកចិត្តបន្តិចបន្តួចទៅលើអង្គជំនុំជម្រះ។ មានន័យថាពួកគេ នៅពេលដែលពួកគេចង់ឡើងឈរនិយាយនោះ ករណីជួនកាលអាចស៊ីពេលយូរនៅពេលដែលសួរសំណួរដល់ជនជាប់ចោទ ។ បន្ទាប់ពីដែលលោកលោកស្រីចៅក្រម បានសួរសំណួរយ៉ាងលម្អិតដល់ជនជាប់ចោទហើយនោះ ។ នេះជាចំណុចមួយដែលខ្ញុំដូចជាមិនយល់សោះ ពីព្រោះទៅតាមការយល់ដឹងអំពីវិធានរបស់យើងនៅពេលដែលលោក លោកស្រីចៅក្រម បានសួរសំណួរយ៉ាងល្អិតល្អន់ដល់ជនជាប់ចោតរួចហើយនោះ ។ សម្រាប់ខ្ញុំៗយល់ថា ភាគីដទៃទៀត គឺមានសំណួរបន្ថែមតែបន្តិចបន្តួចតែប៉ុណ្ណោះ ។ ហើយដែលពួកគេមិនត្រូវការសួរឡើងវិញនូវកិច្ចដែលបានធ្វើឡើងដោយលោកៗស្រីចៅក្រមរួចទៅហើយនោះ ។ នេះជាមតិទីមួយរបស់ខ្ញុំ ។ មតិទីពីររបស់ខ្ញុំ គឺដូចខាងក្រោមនេះ៖

ខ្ញុំមិនមានទម្លាប់ក្នុងការរិះគន់ដល់សេចក្តីសម្រេចរបស់លោក លោកស្រីចៅក្រមទេ ក៏ប៉ុន្តែខ្ញុំចង់ឲ្យមានកត់សម្គាល់ផងដែរថា គឺមានការមិនយល់គ្នាមួយ ។ ខ្ញុំមិនគិតថា ខ្ញុំបានយល់នូវពេលដែលសហព្រះរាជអាជ្ញានិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលប្រាំមួយម៉ោងដើម្បីសួរ ប្តូរវេនគ្នាសួរសំណួរដល់ជនជាប់ចោទ ។ ហើយហេតុអ្វីបានជាយើងជាមេធាវីការពារក្តីមានតែរយៈពេលតែបួនម៉ោងតែប៉ុណ្ណោះ ។ មានន័យថា គឺមានចំនួនលើសតែពាក់កណ្តាលបន្តិចតែប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងពេលវេលាដែលបានបែងចែកសម្រាប់សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ យ៉ាង

ហោចណាស់ មេធាវីការពារក្ដីគួរតែមានចំនួនម៉ោងសួរសំណួរដូចគ្នានឹងភាគីបដិបក្ខបូកបញ្ចូលគ្នាផងដែរ ។

លោក លោកស្រីចៅក្រមក៏បានកត់សម្គាល់ផងដែរ ទាក់ទងទៅនឹងសាក្សី ។ ជាទូទៅមេធាវីការពារក្ដីគិតពេលវេលាសម្រាប់តែបួនថ្ងៃប៉ុណ្ណោះសម្រាប់សាក្សី ។ ប៉ុន្តែ បើយើងពិនិត្យមើលខាងសហព្រះរាជអាជ្ញា ហើយនិងខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងបុគ្គលិកតាមអង្គភាពនីមួយៗនោះ គឺវាមានភាពខុសគ្នាឆ្ងាយណាស់ ។ ហើយនៅក្នុងអង្គជំនុំជម្រះនេះ យើងគួរតែចាំផងដែរថា នៅពេលដែលលោកត្រូវបានគេចោទប្រកាន់អំពីបទល្មើសដ៏ធ្ងន់ធ្ងរ គឺអ្នកនៅតែមានសិទ្ធិដើម្បីទទួលបានការការពារក្ដីដោយយុត្តិធម៌ ។ មានន័យថា យ៉ាងហោចណាស់ គឺយើងត្រូវការតុល្យភាពនៃការបែកចែកពេលវេលាដូចជាការបែងចែកពេលវេលាសម្រាប់ខាងសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីដែរ ។ ប៉ុន្តែ សេចក្ដីសម្រេចចិត្តនេះ គឺលោក លោកស្រីចៅក្រមបានធ្វើបានហើយ ហើយខ្ញុំមិនតវ៉ាទេ ខ្ញុំគ្រាន់តែចង់បញ្ចេញឲ្យជាប់នៅក្នុងកំណត់ត្រាថា ខ្ញុំបានមានការរក្សាសិទ្ធិទៅលើអតុល្យភាពនៃការបែងចែកពេលវេលា ហើយជាលទ្ធផលមានន័យថា នឹងអាចនាំឲ្យមានការធ្វើឧទ្ធរណ៍នៅពេលក្រោយទៅថ្ងៃខាងមុខទៀត ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមធ្វើការឆ្លើយតបចំពោះការលើកមតិរបស់មេធាវីការពារក្ដី។ ជាដំបូង យើងគួរតែបង្ហាញឲ្យច្បាស់ថា ខាងមេធាវី ខាងសហព្រះរាជអាជ្ញា គឺមានទំនុកចិត្តពេញលេញទៅលើនីតិវិធីនិងសេចក្ដីសម្រេចចិត្តរបស់អង្គជំនុំជម្រះ ។ សហព្រះរាជអាជ្ញា គឺយល់ថា អ្វីដែលបានលើកឡើងដោយមេធាវីការពារក្ដីអាចជំទាស់បានទាំងស្រុង ហើយយើងសូមធ្វើការបញ្ជាក់ថា យើងមិនពាក់ព័ន្ធទៅនឹងអ្វីទៅនឹងការលើកឡើងរបស់មេធាវីការពារក្ដីនោះទេ ។ មេធាវីការពារក្ដី បានដឹងច្បាស់ហើយថា ភាគីផ្សេងៗគ្នានៃនីតិវិធីនេះ គឺមានតួនាទីផ្សេងៗគ្នា ក៏បានយល់អំពីតួនាទីរបស់អង្គជំនុំជម្រះ ហើយខាងសហព្រះរាជអាជ្ញា គឺមានតួនាទី និងភារកិច្ច ដែលកំណត់ដោយច្បាប់ ដោយវិធាន ដើម្បីធ្វើការធានាថា ការចោទប្រកាន់ដែលមានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយនោះ គឺត្រូវបង្ហាញឲ្យហួសពីវិមតិសង្ស័យ ។ ហើយនេះ គឺជាភារកិច្ចឯករាជ្យ ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គជំនុំជម្រះទេ ។ ហើយបើសិនជាខ្ញុំធ្វើការបង្ហាញដល់ភស្តុតាងអស់ទាំងហ្នឹង ទៅតាមកម្រិតដែលខាងសហព្រះរាជអាជ្ញាយល់ថា ជាកម្រិតដើម្បីពន្យល់អំពីភស្តុតាងនោះឲ្យបានហួសពីវិមតិសង្ស័យ បើសិនជា

សហព្រះរាជអាជ្ញាមិនបានធ្វើដូច្នេះទេ មានន័យថា ខាងសហព្រះរាជអាជ្ញាមិនបានបំពេញការងារឱ្យសមរម្យ សមស្របសម្រាប់ប្រជាជនកម្ពុជា និងសម្រាប់អង្គសវនាការទេ ។ ភាគីផ្សេងៗដែលបានសួរសំណួរផ្សេងៗគ្នា ពីសំណួរដែលអង្គសវនាការបានសួរនោះ គឺវាមិនមែនមានចំណុចអ្វីពាក់ព័ន្ធទៅនឹងការជឿ ការមានទំនុកចិត្តទៅលើអង្គជំនុំជម្រះនោះទេ ។ នេះគឺអាស្រ័យទៅលើទំហំនៃភស្តុតាង ទៅលើភាពស្មុគស្មាញនៃបញ្ហា ហើយជាការត្រឹមត្រូវយើងនិយាយថា នៅពេលដែលយើងដោះស្រាយទៅលើរឿងក្តីមួយដែលមានទំហំប៉ុននេះ គឺថា យើងមិនអាចគិតដល់ចំណុចលម្អិតនីមួយៗ ដែលជាតម្រូវការនេះទេ ។ នេះគឺជាធម្មជាតិរបស់មនុស្សលោក ។ ហើយខាងសហព្រះរាជអាជ្ញាបានធ្វើការតាំងចិត្តហើយបានគាំទ្រដល់សេចក្តីសម្រេចផ្នែកគ្រប់គ្រងសវនាការ ដែលលោក លោកស្រីចៅក្រមបានសម្រេចជាពិសេសទាក់ទងទៅនឹងការកំណត់ពេលវេលាសម្រាប់សួរសាក្សី ហើយការពីប្រជុំកាលពីថ្ងៃព្រហស្បតិ៍មុន គឺខាងសហព្រះរាជអាជ្ញា បានស្នើឡើងនៅការបែងចែកពេលវេលាដូច្នេះ ដើម្បីឱ្យសវនាការនេះ បានបញ្ចប់នៅពេលវេលាសមរម្យណាមួយ ។

ដូច្នេះ គឺនេះមិនមែនជាកំហុសរបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលបានគ្រាន់តែចង់សួរសំណួរដើម្បីសួរសំណួរតែប៉ុណ្ណោះ ។ គឺពួកយើងចង់ផ្តល់ជាជំនួយដល់អង្គជំនុំជម្រះដើម្បីឱ្យបង្ហាញនូវការពិត ហើយយើងមិនទទួលយកនូវមតិរបស់មេធាវីការពារក្តីនោះទេ ។

ចំណុចទីពីរ ខ្ញុំនឹងនិយាយដោយសង្ខេប សហព្រះរាជអាជ្ញានៅក្នុងប្រព័ន្ធស៊ីវិល គឺមានតួនាទីផ្សេងគ្នា គឺគាត់មិនចាំបាច់មានតួនាទីបង្ហាញភស្តុតាង ឱ្យហួសពីវិមតិសង្ស័យទេ ប៉ុន្តែ គឺខាងសហព្រះរាជអាជ្ញា មានតួនាទីបែបនេះ ។ ដូច្នេះ ដើម្បីនិយាយថា ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធនេះ គឺគ្រាន់តែជាជំនួយបន្ថែមទៅដល់ខាងសហព្រះរាជអាជ្ញា ហើយខាងមេធាវីការពារក្តីយល់ថា នេះគួរបដិបក្ខនោះ នេះគឺជាចំណុចមួយផ្សេង ។ គឺខាងសហព្រះរាជអាជ្ញាមានតួនាទីដែលកំណត់ដោយច្បាប់ជាតួនាទីឯករាជ្យផ្ទុយគ្នា ឬក៏ផ្សេងគ្នាពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

[០៩:៣៥:០០]

**លោកស្រី វ៉ាបេសាន់ដ្រាតាណា៖**

លោកប្រធានសូមអរគុណ។ ខ្ញុំសូមធ្វើការបញ្ជាក់បន្តិចក្នុងនាមជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

គឺយើងមិនមែនមានតួនាទីចម្លងដូចជាតួនាទីរបស់សហព្រះរាជអាជ្ញានោះ គឺយើងមានតួនាទីជាក់លាក់មួយ ជាតួនាទីឯករាជ្យ ហើយតួនាទីរបស់យើងគឺដើម្បីធ្វើការពន្យល់ និងសង្កត់បញ្ជាក់នូវទស្សនៈរបស់ជនរងគ្រោះ ដែលផ្ទុយគ្នាទាំងស្រុងពីតួនាទីរបស់សហព្រះរាជអាជ្ញា ។ ហើយយើងមិនមែនជាអ្នកជំនួសសហព្រះរាជអាជ្ញានោះទេ ។ ក៏ប៉ុន្តែគឺថា ខ្ញុំជឿថា យើងបានផ្តល់ព័ត៌មានដែលយើងទទួលបានពីខាងក្រៅ ដែលជាព័ត៌មានបន្ថែម ដែលអាចជួយដល់ការវិភាគ ដើម្បីស្វែងរកការពិតបាន ។ នេះគឺជាអ្វីដែលខ្ញុំចង់ពន្យល់ប្រាប់លោក លោកស្រីចៅក្រមទាក់ទងទៅនឹងតួនាទីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលសូមកុំឲមានការភាន់ច្រឡំគ្នាទៅនឹងតួនាទីរបស់ខាងសហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន សូមអរគុណ សូមគោរពលោក លោកស្រី ចៅក្រម ដែលបានអនុញ្ញាតឲ្យខ្ញុំលើក ។ ខ្ញុំសូមលើកពីចំណុចសំខាន់ៗទាក់ទងទៅនឹងសិទ្ធិរបស់ភាគី គឺថាលោកមេធាវីគាត់បានលើកឡើងហើយខាងការពារក្តី គាត់បានគិតគូរដ៏សំខាន់ដល់សិទ្ធិកូនក្តីរបស់គាត់ គឺថាត្រូវតែមានសិទ្ធិ អ៊ីចឹងហើយគាត់ត្រូវការការពារ ។ ក៏ប៉ុន្តែ ខាងខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវតែគិតអំពីសិទ្ធិរបស់កូនក្តីរបស់ខ្ញុំបាទដែរ ។ ហើយគាត់មិនអាចយកការបូកបញ្ចូលម៉ោងដែលព្រះរាជអាជ្ញាជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី បូកចូលគ្នាហើយទៅប្រៀបធៀបជាមួយនឹងគាត់ទេ ។ នេះបើយើងគិតពីភាគី ។ ភាគីគាត់គឺជាភាគីខាងការពារខាងជនជាប់ចោទ គឺជាភាគីមួយ ។ ឯព្រះរាជអាជ្ញាគឺគាត់មានតួនាទី គាត់បានបញ្ជាក់ហើយថា ការបង្ហាញភស្តុតាង ។ ឯខាងខ្ញុំគឺជាភាគីមួយដាច់ដោយឡែក គឺជាដើមបណ្តឹងរដ្ឋប្បវេណី ដូចជាបានលើកឡើងហើយថា ចង់បង្ហាញទស្សនៈរបស់កូនក្តីរបស់ខ្លួន ។

ដូច្នេះគឺថា ការបែងចែកនេះគឺថាដាច់ដោយឡែកពីគ្នា មិនអាចយកពេលវេលារបស់ព្រះរាជអាជ្ញាមកបូកជាមួយពេលវេលារបស់ខាងដើមបណ្តឹងរដ្ឋប្បវេណី ហើយទៅប្រៀបធៀបជាមួយគាត់ទេគឺថាដាច់ដោយឡែក ។ បើសិនណាជាគិតឲ្យដាច់ដោយឡែកទៅគឺថា ខាងភាគីដើមបណ្តឹងរដ្ឋប្បវេណីនេះមានតិចជាងគាត់មួយម៉ោងទៅទៀត គាត់មានដល់ពេលបួនម៉ោង ហើយយើងមានតែពេលវេលាតែបីម៉ោងទេ ។ នេះសូមបញ្ជាក់ជូនអង្គជំនុំជម្រះ ។ សូមអរគុណ ។

[០៩:៣៨:១៩]

**ប្រធានអង្គជំនុំ៖**

អរគុណនូវការកត់សម្គាល់របស់លោកមេធាវី ។ ឥឡូវនេះ យើងមិនអនុញ្ញាតឲ្យធ្វើការជជែកវែកញែកអំពីបញ្ហានេះទៀតទេ ខាតម៉ោងអស់កន្លះម៉ោងហើយ ។ ឥឡូវនេះ ឈានដល់ការសួរដេញដោលទាក់ទិនជាមួយអង្គហេតុនៃការសួរចម្លើយ ហើយនិងការធ្វើទារុណកម្ម នៅក្នុងមន្ទីរស-២១ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក កាំង ហ្គេកអ៊ាវ តើលោកអាចនិយាយរៀបរាប់ប្រាប់អំពីវិធីសាស្ត្រទាំងឡាយ ដែលលោក និងអនុប្រធានរបស់លោកចាត់ចែងរៀបចំអ្នកសួរចម្លើយនៅមន្ទីរស-២១ យ៉ាងដូចម្ដេចទៅដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការសួរចម្លើយជនដែលត្រូវចាប់ខ្លួនដែលមានចំនួនច្រើនសន្ធឹកសន្ធាប់រហូតដល់ជាងមួយម៉ឺននាក់ឯណោះ? តើលោកអាចរៀបរាប់ពីចំណាត់ការ ការចាត់ចែងអ្នកសួរចម្លើយនៅមន្ទីរស-២១ បានដែរឬទេ? សូមអញ្ជើញ ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មន្ទីរស-២១ នេះ ខ្ញុំបាទបានបញ្ជាក់ហូរហែមកហើយថា វាជាការរួមផ្សំនៃអង្គភាពពីរបញ្ចូលគ្នា ទីមួយគឺមន្ទីរនគរបាលរបស់កងពល៧០៣ ដែលពេលខ្លះគាត់ ណាត គាត់ហៅថាមន្ទីរ០៣ ។ គេមានកិច្ចដំណើរការរបស់គេ ។ គុកធម្មតានៅពេទ្យឆ្កួតតាខ្មៅ ហើយគុកពិសេសនៅភូមិគ្រឹះស្ដេចក្រុមព្រះ ស៊ីសុវត្ថិ មុន្នីរ៉េត ។ ដូច្នេះ គេដំណើរការវាហូរហែរបស់គេមកហើយ ដល់ខែដប់ខ្ញុំត្រូវច្របាច់បញ្ចូលជាមួយនឹងគេ ។ ពេលនោះ ណាត គេឲ្យខ្ញុំចាប់ផ្ដើមបង្រៀនកម្មាភិបាលខាងកងពល៧០៣ អំពីវិធីសួរចម្លើយ ឯចំណែកកម្មាភិបាលមកពីខាងមន្ទីរ១៣ គេឲ្យប្រតិបត្តិការនៅក្នុងអង្គភាពមួយដែលមានគេ មានខ្ញុំ ជាមួយគ្នា ។ បន្ទាប់មកក៏កិច្ចដំណើរការនេះវាដើរទៅជារលូនជាមួយនឹងគ្នាទាំងអស់ហើយ ។ កិច្ចការប្រគល់អ្នកណា ឲ្យអ្នកណាសួរ គឺស្រេចនៅលើ ណាត ទេ ដំបូង ។ ដល់ ណាត គេចេញទៅកិច្ចការប្រគល់អ្នកណា ឲ្យអ្នកណាសួរនេះ ខ្ញុំក៏ចាត់ចែងឲ្យវាធូរកម្លាំងបន្តិច ប្រគល់ទៅឲ្យ មិត្តហ៊ី ។ ឯចំណែកដោយឡែក អ្នកពិសេស ដែលមេយកចិត្តទុកដាក់មែនទែនគឺខ្ញុំប្រគល់ឲ្យ មិត្តប៊ុន នេះវាចាប់ផ្ដើមបែងចែកហើយ ។

[០៩:៤១:៣០]

សរុបមក នៅក្នុងរយៈកាលដែល ណាត គាត់ធ្វើជាប្រធាន ខ្ញុំធ្វើជាអ្នកកសាងពួកសួរចម្លើយចេញពីកម្មាភិបាល៧០៣ ផង មើលឯកសារសួរចម្លើយពីរយៈកាលដំបូងដែលខ្ញុំមិនទាន់មកកាន់កាប់ផង មនុស្សសំខាន់ម្នាក់ ឯកសារនៅមានសល់ហើយ គឺ សរ ភន នេះទីពីរ ។ ហើយដល់ក្រោយមកក៏

កិច្ចការសួរចម្លើយ ឯកសារវាធ្លាក់មកលើខ្ញុំពិនិត្យ។ ឯកសារណាខ្ញុំមិនពេញចិត្ត រុញទៅលេខាធិការដ្ឋានរបស់គាត់វិញ ដែលគាត់ដាក់ឈ្មោះថា មន្ទីរម-២១ នោះ ។ ដូច្នេះ កិច្ចដំណើរការវាទៅអ៊ីចឹង ។ ដល់គាត់ចេញផុតទៅបានកិច្ចដំណើរការវានៅជារបស់ខ្ញុំពេញលេញ ។

ក្នុងពេលសួរម្ដងៗ នេះខ្ញុំសូមនិយាយពីយុទ្ធវិធីសួរ មុននឹងចូលទារុណកម្មគឺខ្ញុំបង្គាប់ឲ្យកម្មាភិបាលសួរចម្លើយប្រើនយោបាយស្ទាបស្ទង់ឲ្យយល់សភាពការណ៍ ស្ទាបស្ទង់ឲ្យយល់បញ្ហា សួរពីនាយពីអាយ ។ យើងប្រើទារុណកម្មនៅពេលណាចាំបាច់ ជាពេលណាដែលយើងទាល់ច្រក ប្រើតែវិធីត្រជាក់ទៅមិនរួច ។ នេះគឺកិច្ចដំណើរការវាទៅអ៊ីចឹង ។ ឯចំណែកយុទ្ធវិធីធ្វើទារុណកម្ម ខ្ញុំសូមជម្រាបដោយខ្លីថា ខ្ញុំបានអនុញ្ញាតឲ្យធ្វើបួនយ៉ាង ។ ទីមួយគឺវ៉ៃ វ៉ៃនេះមិនកំណត់វ៉ៃនឹងរំពាត់ វ៉ៃនឹងអីៗទេ កំណត់ថាវ៉ៃមួយម៉ាត់ ។ ទីពីរ ដូចខ្ញុំបានជម្រាបអ៊ីចឹង គឺអនុញ្ញាតឲ្យឆក់ខ្សែភ្លើង ដោយប្រើទូរស័ព្ទដៃ (អាទូរស័ព្ទរវៃបួនជ្រុងនោះ) ។ ទីបី ឲ្យច្រកទឹកតាមច្រមុះ ។ ហើយទីបួន ស្អីទៀតទេ ភ្លេចបាត់ទៅហើយ ។ មានបួនយ៉ាងនុ៎ង ដែលខ្ញុំកំណត់ ។ ក៏ប៉ុន្តែជាទូទៅ នៅក្នុងអង្គភាពនោះ --

**សៈ** ស្ដាប់សំណួរឲ្យបាន សំណួរយើងសួរនេះ គឺពាក់ព័ន្ធនឹងការរៀបចំនូវអ្នកសួរចម្លើយនៅក្នុងមន្ទីរស-២១ នោះ ដើម្បីចាត់ចែងសួរចម្លើយមនុស្សដែលមានចំនួនច្រើន ត្រូវបញ្ជូនមកដែលលោកបានឆ្លើយពីម្សិលមិញ គឺយ៉ាងតិចបំផុត យ៉ាងតិចគឺមួយម៉ឺនពីរពាន់បីរយប៉ែតនាក់ ដោយមិនគិតអ្នកដែលមានចំនួនមួយរយហុកសិបនាក់មិនទាន់បញ្ចូល ហើយនិងមានមនុស្សមួយចំនួនទៀតដែលឯកសារត្រូវបាត់បង់ ដែលមិនបានបញ្ចូលនៅក្នុងបញ្ជីនេះទេ ។ ថាតើលោករៀបចំអ្នកផ្នែកក្រុមសួរចម្លើយហ្នឹងរបៀបម៉េច? អ៊ីចឹងមិនទាន់ដល់ពាក់ព័ន្ធទៅនឹងទារុណកម្មទេ គឺសួរកម្រិតត្រឹមតែការចាត់ចែងរៀបចំខាងផ្នែកសួរចម្លើយប៉ុណ្ណោះ ។

[០៩:៤៤:៥៤]

**ឆៈ** សូមអរគុណលោកប្រធានដែលបានកែតម្រូវខ្ញុំ ។ ផ្នែកខាងសួរចម្លើយ ចាប់តាំងពី ណាត គាត់នៅម្ល៉េះ ចែកជាបីក្រុម ។ ក្រុមត្រជាក់, ក្រុមក្ដៅ និងក្រុមអង្កៀម ។ ក្រុមត្រជាក់ និយាយឲ្យចំ គឺមិនប្រើទារុណកម្ម ។ ក្រុមក្ដៅ គឺដែកក្ដៅតែម្ដង សួរបានមួយរយៈហ្នឹងទៅ មើលទៅមិនកើតទេ គេវ៉ៃ។ នេះក្រុមក្ដៅ ។ ឯចំណែកក្រុមអង្កៀម គេប្រើពេលវេលាយូរ ចំពោះអ្នកទោសណាដែលគេត្រូវការចម្លើយ គេសួរហើយសួរទៀត មួយលើកហើយ មួយលើកទៀត សួរហើយគេយកទៅទុកទៅ គេយកអ្នកផ្សេងមួយទៀតមកសួរ ។ ដូច្នេះ អង្កៀមយូរខែ ទើបបានគេចប់ ។ ដូច្នេះក្រុមមានបី មានក្រុម

អង្កៀម មានក្រុមត្រជាក់ មានក្រុមក្តៅ ។ ដល់ពេល ណាត គាត់ចេញទៅខ្ញុំថែមមួយពីរទៀត គឺថែមក្រុមពិសេស ចំពោះអ្នកទោសណាដែលមានសារសំខាន់ ដែលខាងលើចង់ដឹងមែនទែន ខ្ញុំឲ្យមិត្តប៉ុន ជាមនុស្សដែលខ្ញុំបានអប់រំឲ្យចេះរបៀបសួរតាំងពីអង្គាល់នៅម-១៣ ម្ល៉េះ ។ ឯចំណែកបង ម៉ម ណៃ នេះ ខ្ញុំប្រើជាជំនួយការទេ សួរក៏សួរ ចាត់ចែងកិច្ចការផ្សេងទៀត ក៏ចាត់ចែងទៅ ។ ដូច្នេះ មិនច្បាស់ជាអ្នកសួរចម្លើយនៅក្នុងក្រុមណាមួយប្រាកដប្រជាទេ ។ ដូច្នេះ មានបួនក្រុម ក្រុមសួរចម្លើយពិសេស ក្រុមធម្មតានោះវាមានបីក្រុម ។ នេះខ្ញុំសូមរាយការណ៍បញ្ជាក់ជូនប៉ុណ្ណេះ ។ សូមអរគុណ ។

**ស៖** លោកគិតមើល ក្រុមមានបីក្រុម តើក្នុងក្រុមនីមួយៗហ្នឹងមានមនុស្សប៉ុន្មាននាក់ ហើយមានការបែងចែកជាពួក បានន័យថា នៅក្នុងត្រជាក់ ឬក៏ក្រុមក្តៅ ក្រុមអង្កៀមហ្នឹងមានធ្វើការបែងចែកជាក្រុម ជាពួកតូចៗនៅក្នុងក្រុមហ្នឹងទៀតដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! កាលតាំងពី ណាត គាត់នៅម្ល៉េះ ខ្ញុំអត់ជាក់ស្តែងក្នុងរឿងល្អិត ក្នុងរឿងច្បាស់លាស់ទៅដល់មួយក្រុមហ្នឹងមានប៉ុន្មាននាក់ អត់ច្បាស់ទេ គ្រាន់តែដឹងថាជារួមៗអ៊ីចឹង ហើយរង់ចាំតែបានឯកសារមក នឹងអាលពិនិត្យ ហើយឲ្យគេសួរសាឡើងវិញ ។ នេះយន្តការហ្នឹងវាដើរទៅរបៀបហ្នឹង ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណឹង ។

**ស៖** តាមធម្មតាលោកដឹងទេថា ក្រុម ឧបមាថា ក្រុមត្រជាក់អ៊ីចឹង ក្នុងក្រុមត្រជាក់ហ្នឹងមានមនុស្សប៉ុន្មាននាក់ អ្នកសួរចម្លើយ ក្រុមក្តៅហ្នឹងមានមនុស្សប្រហែលប៉ុន្មាននាក់? ព្រោះអាចមានការប្រែប្រួល ដកចេញ ឬក៏អីអ៊ីចឹង ។ ប្រហែលទៅបានហើយ ថាមានប៉ុន្មាននាក់ ហើយក្រុមអង្កៀមមានប្រហែលប៉ុន្មាននាក់?

[០៩:៤៨:០៨]

**ឆ៖** ពិបាកប៉ាន់ប្រមាណណាស់លោកប្រធាន ខ្ញុំជម្រាបដោយស្មោះត្រង់ទៅ អត់បានគិតគូរដល់រឿងហ្នឹងទេ គិតតែខ្លឹមសារនៃចម្លើយសារភាព មកដល់ដៃខ្ញុំ ខ្ញុំវិភាគ ត្រូវឲ្យសួរវិញ ឬយ៉ាងម៉េច? ដូច្នេះជាក់ស្តែងក្នុងក្រុមណាមួយមានប៉ុន្មាន គឺក្តាប់មិនបាន ។ បើសិនជាតាមប៉ាន់ប្រមាណ ក្រុមត្រជាក់មានគ្នាតិចទេ មិនដល់ដប់នាក់ទេ ប្រាំ-ប្រាំមួយនាក់ប៉ុននុ៎ង ។ ឯចំណែកក្រុមក្តៅក៏មានតិចដែរ ។ អ្នកក្តៅមែនទែន ដែលខ្ញុំស្គាល់មុខច្បាស់ ហើយនៅចាំច្បាស់ គឺមិត្ត ទុយ ។ ឯចំណែក ក្រុមអង្កៀម មានមាន មិត្តទិត ជាប្រធានមួយទៅ ហើយក្រៅពីនោះមិនដឹងជាមានអ្នកណាទៀតទេ ។ រឿងនេះខ្ញុំសូមជម្រាបជូនដោយស្មោះប៉ុណ្ណេះ ។

**ស៖** លោកធ្លាប់បានឆ្លើយកាលពីលើកមុនអាចថាជាច្រើនដងដែរ ប៉ុន្តែ ដោយសារមិនទាន់មានការពាក់ព័ន្ធជាមួយនឹងអង្គហេតុ ឥឡូវនេះយើងសួរបញ្ជាក់ម្តងទៀតថា នៅមន្ទីរសន្តិសុខស-២១ នេះ មានចាត់តាំងជាក្រុមអ្នកសួរចម្លើយជាស្ត្រីភេទដែរទេ? ហើយបើមាន មានចាប់ពីពេលណាមក? ហើយរហូតដល់ពេលណាទៅ ទើបមានការបាត់បង់ទៅវិញ ឬក៏លុបចេញនូវប្រព័ន្ធនៃការមានបង្កើតជាក្រុមសួរចម្លើយជាស្ត្រីភេទ?

[០៩:៤៩:៤៥]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ក្រុមសួរចម្លើយស្ត្រីភេទនេះ វាកើតឡើងដោយសារមានសកម្មភាពល្មើសលើរូបរាងកាយទៅលើស្ត្រីម្នាក់ ដោយអ្នកសួរប្រុសម្នាក់ ។ ពេលនុំងខ្ញុំសូមអនុញ្ញាតមេខ្ញុំ បញ្ចូលប្រពន្ធកម្មាភិបាលស-២១ មកចូលក្នុងស-២១ ដើម្បីរៀបចំទៅជាក្រុមសួរចម្លើយស្រី ។ កកើតដំបូងមានគ្នាប្រាំនាក់ ដោយឲ្យមិត្តម៉ុត ប្រពន្ធ មិត្តហ៊ អនុលេខាខ្ញុំនេះធ្វើជាប្រធានក្រុមសួរចម្លើយស្រី ។ ហើយសូមជម្រាបបញ្ជាក់ថាមិត្តម៉ុត ខ្លួនគាត់នេះក៏ជាកម្មាភិបាល នៃអនុសេនាធិការតូចនៃមន្ទីរកាត់ដេររបស់សេនាធិការដែរ ។ ដូច្នេះ ខាងលើយល់ស្របការចាត់តាំងនេះ ។ ក្រុមនេះដំណើរការរហូតមក នៅពេលដែលខាងលើសម្រេចឲ្យយើងខ្ញុំចាប់ មិត្តម៉េង អ្នកការិយាល័យម្នាក់នៅមន្ទីរ ស-២១ មិត្ត ពឿន ប្រពន្ធមិត្ត ម៉េង ក៏ត្រូវចាប់ចងទៅជាមួយនោះដែរ កម្ទេចជាមួយគ្នាហ្នឹង នេះមួយលើកទៅ ។ ដល់លើកក្រោយមកចាប់មិត្ត នន ហ៊ុយ សមាជិកគណៈកម្មាធិការស-២១ ទទួលភារកិច្ចមជ្ឈមណ្ឌលព្រៃស នៃស-២១ នេះ ក៏ដោយទាំងមិត្តខឿន, ប្រុក ខឿន ទៅទៀត ទាំងកូនតូចមួយផង ។

ដូច្នេះ អស់ពីរនាក់ហ្នឹងក្នុងកម្មាភិបាលសួរចម្លើយស្រី ហើយកម្មាភិបាលសួរចម្លើយបីនាក់ទៀតនៅសល់រហូត គឺទីមួយ ប្រធានគេហ្នឹងមិត្តម៉ុត ប្រពន្ធមិត្តហ៊ ទីពីរ មិត្ត នី ប្រពន្ធមិត្ត ប៉ុន ហើយទីបីមិត្តរ៉ន ប្រពន្ធមិត្ត ត្រូវ នៅរហូតៗ ដល់ថ្ងៃរត់ ទី០៧ មករា នេះ អត់មានទៅណាទេ នៅសួរចម្លើយស្រីៗរហូត ។ នេះសូមបញ្ជាក់ជូនលោកប្រធានប៉ុណ្ណេះ ។

**ស៖** អរគុណ ។ លោកតែងតែបានលើកឡើងច្រើនលើកច្រើនសាហើយ អំពីវិធីសាស្ត្រនៃការសួរចម្លើយ ដែលមានវិធីសាស្ត្រត្រជាក់ វិធីសាស្ត្រក្តៅ និងវិធីសាស្ត្រអង្កៀម ហើយវិធីសាស្ត្រនេះគឺហាក់ដូចជាឆ្លើយទៅនឹងបែងចែកក្រុមអ្នកសួរចម្លើយ ។ អ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ការបែងចែកក្រុម ហើយនិងវិធីសាស្ត្រសួរចម្លើយហ្នឹង វាពាក់ព័ន្ធគ្នា ។ ការបែងចែកក្រុមវាស្របទៅវិធីសាស្ត្រសួរចម្លើយ ដូចលោកប្រធានមានប្រសាសន៍អំមិញ

អ៊ីចឹង សូមគោរព ។

**ស៖** លោកបាននិយាយញឹកញាប់ដែរពីបញ្ហានេះ ប៉ុន្តែ ថ្ងៃនេះក៏ភាពចង់ច្បាស់លាស់បញ្ជាក់អំពីវិធីសាស្ត្រទាំងបីនេះ តើលោកអាចនិយាយជម្រាបប្រាប់អង្គសវនាការបានទេ ភាពលម្អិតច្បាស់លាស់អំពីវិធីសាស្ត្រនីមួយៗ? វិធីសាស្ត្រត្រជាក់ គេធ្វើយ៉ាងដូចម្តេចទៅ? ហើយនៅក្នុងករណីណាខ្លះ វិធីសាស្ត្រក្តៅ គេធ្វើយ៉ាងដូចម្តេច? ហើយក្នុងករណីណា ហើយនិងវិធីសាស្ត្រអង្កៀមក៏ដូចគ្នា ថាប្រព្រឹត្តទៅនៅក្នុងយ៉ាងម៉េច? ហើយនៅក្នុងករណីណាខ្លះ?

[០៩:៥៣:១០]

**ឆ៖** វិធីសាស្ត្រទាំងបីនេះ វាដំណើរការតាមមាគ៌ាសកម្មភាពឯកភាពគ្នា ។ ជាទូទៅចាប់ផ្តើមសួរដំបូង គឺអត់ប៉ាានមាត់កអីខ្លាំងទេ គេចាប់ផ្តើមរកយល់អំពីអ្នកដែលត្រូវឆ្លើយ អ្នកដែលនៅចំពោះមុខយើង ។ កាលណាយល់ហើយ បានគេចាប់ផ្តើមសួរស្លូតធម្មតា អាចនរក្សាពាក្យធម្មតាជាមួយគ្នាបានដល់ក្រោយមកបាន បានគេដោះស្រាយមិនរួចតាមវិធីត្រជាក់ បានគេចូលវិធីក្តៅ ។ នេះជាទូទៅ គឺវាស្ថិតនៅក្នុងក្របខ័ណ្ឌបែបនេះ ។ សៀវភៅមួយ ដែលនៅសល់រហូតទល់សព្វថ្ងៃនេះ ដែលមិត្តយើងអ្នកសួរចម្លើយម្នាក់ គេចងក្រង វាបញ្ជាក់បញ្ហានេះច្បាស់ហើយ ។

សរុបមកវិញវិធីត្រជាក់សុទ្ធ ខ្ញុំឃើញអាចធ្វើបានតែខ្ញុំម្នាក់ឯង សួរចម្លើយ កុយ ធួន ពីរលើក ហើយនិងវិធីដែលបង ម៉ម ណៃ គាត់សួរ មនុស្សគ្រាន់តែសួរឲ្យតែដឹងដំបូងនោះ បានតែប៉ុនន៉ុង ។ ឯចំណែកក្រៅពីនោះ ដូចមិត្ត ប៉ុន អី អត់រក្សាវិធីត្រជាក់នេះបានទេ ត្រូវការប្រើវិធីអង្កៀម ។ ឯចំណែកមិត្តទុយ កន្លែងណាដែលប្រើវិធីអង្កៀមហើយទៅមិនរួចទេ រុញទៅឲ្យគាត់ គាត់លេងធម៏ក្តៅហើយ ។ នេះក្នុងកិច្ចដំណើរការជាក់ស្តែងវាមានទិដ្ឋភាពប្លែកទៅអ៊ីចឹង ។ មិត្តទុយ ជាមនុស្សដែលចូលជាទារុណកម្ម ម្លោះហើយពេលណាទាល់ច្រកមែនទែន ក្រុមពីរទៀតដោះស្រាយមិនចេញ រុញទៅឲ្យគាត់ ។ នេះគឺសូមបញ្ជាក់ប៉ុណ្ណោះ ក្នុងវិធីអនុវត្តជាក់ស្តែង ។ សូមជម្រាបលោកប្រធាន ។

**ស៖** កាលដែលលោកនិងអនុប្រធានរបស់លោក ធ្វើការបែងចែកអ្នកសួរចម្លើយជាច្រើនក្រុម ហើយនិងមានវិធីសាស្ត្រក្នុងការសួរចម្លើយជាក់លាក់ ដូចលោកបាននិយាយអ៊ីចឹង ។ អ្នកជាប់ឃុំឃាំងនៅ-- តើយើងអាចនិយាយបានទេថាអ្នកជាប់ឃុំឃាំងនៅមន្ទីរស-២១ ហ្នឹងត្រូវបានគេសួរចម្លើយមានលក្ខណៈជាប្រព័ន្ធ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គេពិតជាអាចនិយាយបានថាការសួរចម្លើយនៅស-២១ មានលក្ខណៈជាប្រព័ន្ធ ។ ព្រោះអី ចូលមកដល់ដំបូង មិត្តហ៊ី គាត់ជ្រើសរើសហើយ អ្នកណាគួរសួរចម្លើយមុន អ្នកណាគួរសួរចម្លើយក្រោយ ការងារនេះខ្ញុំប្រគល់ឲ្យគាត់ជួយ ។

ដូច្នេះបន្ទាប់មក គេបែងចែកហើយអ្នកណាត្រូវយកចេញឆាប់ អ្នកណាត្រូវមិនទាន់យកចេញ ។ ដូច្នេះសរុបមកអ្នកទុកយូរ អ្នកណាអី អាស្រ័យនៅលើខាងលើជួយមតិពីលើមកទៀត ។ ដូច្នេះ វាពពាក់ពពូនគ្នា វាប្រចាក់ក្រឡាគ្នារវាងអ្នកប្រតិបត្តិ ហើយនិងអ្នកដឹកនាំរួមពីលើមកនោះ ។ ដូច្នេះ វាពិតជាប្រព័ន្ធហើយ ដែលខ្ញុំបានពន្យល់ប៉ុណ្ណេះ ដោយត្រួសៗ នេះមិនទាន់គ្រប់ទេ ។ សូមជម្រាបថាវាពិតជាប្រព័ន្ធ ។

[០៩:៥៦:៣៨]

**ស៖** អរគុណ ។ ដោយនៅមន្ទីរស-២១ មានការបែងចែកអ្នកសួរចម្លើយហ្នឹងជាច្រើនក្រុម លោកឆ្លើយហើយថាមានបីក្រុម ហើយក្រុមនីមួយៗ គឺអាចមានមនុស្សពីប្រាំ ទៅប្រាំមួយនាក់ ។ ហើយចុះរបៀបគ្រប់គ្រងចាត់ចែងអ្នកជាប់ឃុំឃាំងដែលត្រូវសួរចម្លើយហ្នឹង ត្រូវធ្វើដូចម្ដេចទៅ? ត្រូវធ្វើវិលជុំ ឧទាហរណ៍ក្រុមមួយ មកដល់អីចឹង ក្រុមមួយត្រូវទទួលបន្ទុកសួរ រួចហើយទៅបន្ទាប់មនុស្សមកមួយក្រុម ទៅដល់ក្រុមពីរ ឬក៏វុញទៅក្រុមបីអីចឹងតាមលំដាប់វិលជុំអីចឹង ឬក៏មានចែកតាមវេនដែលថាត្រូវថ្ងៃច័ន្ទ ឬក៏ថ្ងៃអង្គារ៍ ថ្ងៃពុធ អីចឹង ដែលដើម្បីក្នុងការចាប់ ទទួលសួរនោះ ពីព្រោះចែកចេញជាបីក្រុមផ្សេងគ្នា ។ តើវិធីសាស្ត្រក្នុងការបែងចែកអ្នកជាប់ឃុំឃាំងដើម្បីសួរចម្លើយនោះ យើងនៅក្នុងមន្ទីរ ស-២១ ប្រព្រឹត្តទៅយ៉ាងដូចម្ដេច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ការសួរចម្លើយនៅក្នុងមន្ទីរស-២១ គេមានហៅ មានក្រុមមួយ យើងហៅថាក្រុមត្រជាក់ក៏ថាបាន ក៏ប៉ុន្តែខ្ញុំចូលចិត្តហៅថា ពួកសួរបឋម ឬក្រុមសួរបឋម ។ មកដល់អត់វាយទេ ពួកហ្នឹង សួរ គិតតែពីសួរ ហើយសរុប ដើម្បីយកសារសំខាន់ ។ ដល់យកសារសំខាន់របស់ជនដែលត្រូវសួរហ្នឹងហើយ បាន មិត្តហ៊ី គាត់សម្រេចដោយពិគ្រោះនឹងខ្ញុំ ឬក៏មិនបាច់ពិគ្រោះគាត់សម្រេចរុញទៅឲ្យក្រុមណា? ក្រុមត្រជាក់ ឬក្រុមក្ដៅ ឬក៏ក្រុមអង្កៀម?

នេះវាបែងចែកអីចឹងហើយស្រេច ដូច្នេះម្នាក់ៗរុញហើយ គេរុញទៅ ។ ដល់គេរុញទៅបើក្រុមត្រជាក់វាពុះពារមិនរួចទេ គេរុញទៅឲ្យក្រុងអង្កៀម ឬក៏រុញទៅឲ្យក្រុមក្ដៅលមើលសិន ។ បើក្រុមក្ដៅវាពុះពារទៅរុញ ល្មមរុញទៅឲ្យក្រុមអង្កៀម គេរុញៗអីចឹង ស្រេចហ្នឹងចាត់ចែង ។ ដោយឡែកមនុស្ស

សំខាន់អ្នកដែលត្រូវសួរ អ្នកដែលត្រូវឆ្លើយសំខាន់ អ្នកទោសសំខាន់នោះ ស្ថិតនៅលើកណ្ដាប់ដៃមិត្ត ប៊ុន ហើយខ្ញុំចាត់ចែងក្រោមសេចក្ដីសម្រេចពីខាងលើ ។ អាហ្នឹងមានពិសេសមួយនុ៎ង ខាងលើថាអានុ៎ង ពិសេស ខ្ញុំរុញទៅឲ្យមិត្ត ប៊ុន ហើយ ។ ចៀសមិនរួចទេ នេះគឺសូមជម្រាបប្រសាសន៍លោកប្រធាន អ៊ីចឹង ។

[០៩:៥៩:០៧]

**ស៖** លោកអាចនិយាយប្រាប់ដល់អង្គជំនុំជម្រះ ដល់អង្គសវនាការទាំងមូលបានទេ អំពីស្ថានភាព នៃអ្នកសួរចម្លើយក្នុងការនាំជនជាប់ឃុំឃាំងនៅសួរចម្លើយ ដោយចេញពីបន្ទប់ឃុំឃាំងទៅកាន់បន្ទប់ សួរចម្លើយនោះ តើគេប្រព្រឹត្តទៅដូចម្ដេចដែរនៅមន្ទីរស-២១?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងនេះខ្ញុំមិនឃើញនឹងភ្នែកជាក់ស្ដែងទេ ក៏ប៉ុន្តែ តាម សន្និដ្ឋាន កាលដែលធ្លាប់នៅម-១៣ គេត្រូវចងដៃទៅក្រោយ ចងខាងលើកែងនេះ ភ្ជាប់ទៅក្រោយ បណ្ដើរទៅ អត់ចងមុខទេ ។ ទៅដល់កន្លែងសួរចម្លើយ គេដាក់ខ្នោះជើង គេឲ្យអង្គុយ ហើយគេដាក់ខ្នោះ ជើងហើយៗបានគេដោះដៃៗ ។ នេះជាក្រិត្យក្រមធម្មតា ដែលយើងខ្ញុំធ្លាប់ឲ្យគេប្រព្រឹត្តនៅម-១៣ ។ ដូច្នេះនៅ ស-២១ ខ្ញុំយល់ថាមិនប្លែកពីនោះប៉ុន្មានទេ ថ្វីត្បិតតែការងារនេះគេរត់របត់ មុនខ្ញុំចូលទៅកាន់ កាប់កិច្ចការនុ៎ងក៏ដោយ ។ នេះសូមជម្រាបប្រសាសន៍លោកប្រធានដោយវិភាគ និងសន្និដ្ឋានបែបនេះ ។

**ស៖** លោកបាននិយាយពីម្សិលមិញ ថាប្រតិបត្តិការនៅមន្ទីរស-២១ មានការបែងចែកច្បាស់ រវាងកងពិសេសដែលការពារខាងក្រៅ ហើយនិងកងការពារខាងក្នុង បានន័យផ្ទាល់ជាមួយនឹងអ្នកជាប់ ឃុំឃាំង មើលការខុសត្រូវឃុំគ្រងផ្ទាល់ជាមួយនឹងអ្នកជាប់ឃុំឃាំង ។ សួរថានៅក្នុងនីតិវិធី នៃការទៅ សួរនាំអ្នកដែលត្រូវជាប់ឃុំឃាំងពីបន្ទប់ឃុំឃាំង គឺបន្ទប់ដើម្បីសួរចម្លើយនេះ សួរថាតើអ្នកសួរចម្លើយ ហ្នឹងជាអ្នកចូលទៅយកមុខសញ្ញា ឬក៏ជនជាប់ឃុំឃាំងដែលត្រូវសួរនុ៎ងដោយខ្លួនឯង? ឬក៏កិច្ចការនេះ មានយន្តការមួយថា អ្នកសួរចម្លើយនេះមិនអាចចូលទៅក្នុងអគារឃុំខ្លួនរបស់ជនទាំងនោះបានទេ វាត្រូវ តែមានបែបបទមួយថា អ្នកខាងក្នុង អ្នកយាមខាងក្នុងហ្នឹងជាអ្នកប្រតិបត្តិការក្នុងការនាំយកមនុស្សដោះ ខ្នោះចេញ នាំយកមនុស្សពីខាងក្នុងមកប្រគល់ឲ្យអ្នកសួរចម្លើយអីជាដើម ឬក៏អ្នកសួរចម្លើយចូលទៅ យកមនុស្សហ្នឹងដោយខ្លួនឯង?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងនេះក៏ខ្ញុំនៅតែមិនបានទៅឃើញនឹងភ្នែកជាក់ស្ដែង ក៏ ប៉ុន្តែគ្រាន់តែសូមវិភាគនិងសន្និដ្ឋានជូនថា អ្នកសួរចម្លើយទៅដល់មាត់ទ្វារបន្ទប់ ព្រោះនៅក្នុងបន្ទប់ឃុំ

ឃាំង វាជាសិទ្ធិអំណាចរបស់កងការពារ យើងចូលទៅមិនបានទ ។ ដូច្នេះ គេយកមកប្រគល់ឲ្យយើងនៅនឹងមាត់ទ្វារបន្ទប់ ប្រគល់ឲ្យអ្នកសួរនៅមាត់ទ្វារបន្ទប់ ហើយបានអ្នកសួរនាំមកដល់កន្លែងរបស់ខ្លួន។ នេះតាមការវិភាគ និងសន្និដ្ឋានរបស់ខ្ញុំ ។ សូមរាយការណ៍ជូនប៉ុណ្ណោះ ។

**ស៖** អំមិញលោកបាននិយាយខ្លះហើយ ប៉ុន្តែ ដូចជាលឿនពេក អ៊ីចឹងគឺអង្គជំនុំជម្រះចង់បានច្បាស់លាស់ថា នៅពេលនាំជនត្រូវសួរចម្លើយនោះ ទៅដល់កន្លែងសួរចម្លើយ តើមានការរៀបចំឲ្យមានការអ្នកជាប់ឃុំឃាំងនុំងយ៉ាងដូចម្តេចដែរមុននឹងចាប់ផ្តើមសួរចម្លើយ?

[១០:០៣:០៧]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ជាក្រិត្យក្រមធ្វើម៉េចកុំឲ្យតែអ្នកសួរចម្លើយហ្នឹងតដៃបានហើយរត់រួច ។ ដូច្នេះ ខ្ញុំគិតថា ហើយជឿ សន្និដ្ឋានថា ទៅដល់គេដាក់ខ្នោះជើងសិន បានគេស្រាយដៃបើអ្នកឃុំឃាំងនោះ សារភាពគេហើយ សុខចិត្តសរសេរ គេដាក់ខ្នោះជើង ឲ្យអង្គុយកៅអីបានគេដាក់ខ្នោះជើង ហើយបានៗគេស្រាយដៃ គេប្រគល់ស្លាបប៉ាកាអីឲ្យសរសេរនៅនឹងតុនុំង ។ ហើយបើមិនទាន់នេះទេ គេឲ្យអង្គុយនឹងការ៉ូឥដ្ឋហ្នឹង គេដាក់ខ្នោះជើង ហើយគេសួរ ។ នេះរបៀបសួរ ហ្នឹងខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**ស៖** ជាធម្មតានៅកន្លែងសួរចម្លើយនេះ មានឧបករណ៍សម្រាប់ធ្វើទារុណកម្មរៀបចំស្រេច ជាស្រេចដែរឬទេដូចជា ដំបង ឬក៏ខ្សែ ប្រដាប់ឆក់ខ្សែភ្លើងអីជាដើម ។ តើយើងត្រៀមអ្នកសួរចម្លើយនៅក្នុងតុរបស់អ្នកសួរចម្លើយហ្នឹង យើងបានចាត់ចែងរៀបចំជាមុនទេ នូវឧបករណ៍សម្រាប់ធ្វើទារុណកម្មទាំងនោះ ដើម្បីជាមធ្យោបាយមួយបន្លាចដល់អ្នកដែលត្រូវចម្លើយ?

[១០:០៤:៣៩]

**ឆ៖** រឿងនេះវាច្បាស់មែនទែននៅសម័យដែលទៅបង្ហាញទីតាំង ស-២១ នៅថ្ងៃទី២៨ កុម្ភៈ ២០០៨ ពួកអ្នកសួរខ្លះ គេថា អ្ហែ! ដាក់គ្រាន់តែបន្លាចទេ ។ ដូច្នេះ ប្រដាប់ដែលត្រៀម ខ្ញុំជឿថា មានគ្រប់គ្នា គឺដំបង ឬរំពាត់សម្រាប់ធ្វើទារុណកម្ម ។ ឯចំណែកអាទូរស័ព្ទប្អូនជ្រុងសម្រាប់វេវែឆក់ខ្សែភ្លើងក៏អាចមានគ្រប់គ្នាដែរ ។ ចំណែក ស្បោងប្លាស្ទិក ខ្ញុំមើលទៅកម្រមានអ្នកណាប្រើៗ ហើយអាចច្រកទឹកនោះ ក៏កម្រមានអ្នកណាប្រើ ។ ដូច្នេះ ប្រហែលជាអាចមានជាទូទៅ គឺរំពាត់ ហើយអ្នកខ្លះមានរំពាត់ហើយមានប្រដាប់នេះទៅទៀត ប្រដាប់វេវែឆក់អគ្គិសនីទៅទៀត ។ ដោយឡែក ប្រដាប់ខ្លះដាក់សម្រាប់កំហ៊ើញ ដូចជាដាវធំ ប្រថៅធំអីហ្នឹង គ្រាន់តែកំហ៊ើញទេ ហ្នឹងមាន ។ នេះខ្ញុំសូមជម្រាបជូន

ប៉ុណ្ណេះ ។

**ស៖** លោកគិតថាម៉េចដែរអំពីរបៀបរបបដែលលោកបានរៀបរាប់អំមិញ អំពីបែបបទនៃការប្រគល់ ទទួលមនុស្សយកពីបន្ទប់ឃុំឃាំងហើយប្រគល់មកឲ្យអ្នកសួរចម្លើយ ហើយធ្វើចម្លើយត្រូវបានចង ឬក៏ដាក់ខ្នោះដៃចំពោះអ្នកដែលត្រូវ ជនជាប់ឃុំឃាំងទាំងអស់បណ្តើរទៅកន្លែងសួរចម្លើយ រហូតដល់ពេលកន្លែងធ្វើចម្លើយហើយមុននឹងចាប់ផ្តើមសួរនោះ គឺមានការដាក់ខ្នោះជើងជាប់ជាមុនសិន មុននឹងដាក់ដោះខ្នោះដៃអីអ៊ីចឹង គឺទម្រង់បែបបទនេះ គឺមានលក្ខណៈជាទូទៅ ។

សំណួរសួរថា បែបបទនេះ អ្នកណាជាបង្រៀនដល់បុគ្គលិកទាំងអស់ អ្នកសួរចម្លើយឲ្យចាត់ចែងធ្វើរបៀបនេះ? ឬក៏គេយល់ដោយឯកឯងតែម្តង អំពីវិធីនេះដោយគ្មានអ្នកណាបង្ហាត់បង្រៀន ឬក៏បង្ហាញណែនាំឲ្យគេធ្វើដូច្នេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំសូមឆ្លើយក្នុងករណីទូទៅ មិនមែន មិននិយាយដល់ គុកពិសេសនោះទេ ។ ក្នុងករណីទូទៅ កិច្ចដំណើរការបែបនេះវាហូរហែមកតាំងពីនៅម-១៣ នេះខាងខ្ញុំ ឯចំណែក មន្ទីរសន្តិសុខកងពល៧០៣ នេះវាមានហូរហែតាំងពីកកើតសន្តិសុខ៧០៣ មក ។ ហើយវាយកតាមគ្នីគ្នារហូតអ៊ីចឹងមក ។ ដូច្នេះ ថាឲ្យវាចេញជាមេរៀន ជាបទបញ្ជាច្បាស់លាស់ វាមករត់របត់ទៅអ៊ីចឹងហើយ វាអត់ទាន់មាន វាអត់ឯកសារសរសេរណាសម្រាប់ទុកជាភស្តុតាងឲ្យយើងដល់ថ្ងៃនេះទេ ។ ក៏ប៉ុន្តែ ការប្រតិបត្តិហ្នឹង វាហូរហែ វារត់របត់តាំងពីយូរមកហើយ ។ ដូច្នេះ ការរត់របត់ជាយូរមកហើយនៅក្នុងមន្ទីរនគរបាលទាំងអស់រួមទាំងស-២១ ផង គឺដំណើរការបែបនេះឯង ។ សូមបញ្ជាក់ថា ខាងលើក៏សុខចិត្ត ខ្ញុំផ្ទាល់ដែលជាអ្នកដឹកនាំអង្គភាពនេះ ក៏សុខចិត្តឲ្យធ្វើអ៊ីចឹង ហើយខាងក្រោមក៏គេត្រូវតែធ្វើអ៊ីចឹងតាមបទបញ្ជា ។ នេះ គឺសូមជម្រាបបញ្ជាក់ប៉ុណ្ណេះ ។

[១០:០៨:២៩]

**ស៖** លោក កាំង ហ្គេកអ៊ាវ តើលោកតែម្នាក់គត់ដែលជាអ្នកបង្រៀនអំពីបច្ចេកទេសសួរចម្លើយដលអ្នកសួរចម្លើយនៅក្នុងមន្ទីរស-២១ ជាការពិតដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ចាប់តាំងពីថ្ងៃដែលខ្ញុំចូលទៅធ្វើជាអនុប្រធាន គឺមានតែខ្ញុំម្នាក់គត់ដែលបង្រៀនបច្ចេកទេសសួរចម្លើយដល់អ្នកសួរចម្លើយ ។

**ស៖** ការបង្រៀនរបស់លោកហ្នឹងធ្វើជាញឹកញាប់ ធ្វើច្រើនដងទេ តាំងពីកកើតឡើងនូវមន្ទីរសន្តិសុខ ស-២១ រហូតដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! បើនិយាយអំពីបច្ចេកទេសសួរចម្លើយ ខ្ញុំបង្រៀនប្រហែលជាបានមួយខែ ឬក៏ពីរ-បីអាទិត្យប៉ុណ្ណោះទេ ដោយគិតមួយថ្ងៃពីរម៉ោង ហើយនិងដើរពិនិត្យមើលគេសួរចម្លើយជាមួយ ណាត ដល់ក្រោយមកលែងបានបង្រៀនទៅ ហើយនៅចុងបញ្ចប់ដែលខ្ញុំបង្រៀនជាប់លាប់អំពីទិសនៃការសួរចម្លើយ ហើយទិសនៃការសួរចម្លើយ ទាំងអស់នេះវាមាននៅក្នុងកំណត់ដូចដែលខ្ញុំនិយាយច្រំដែលៗ ដដែលជាដដែល កំណត់ដែលបង ម៉ម ណៃ គាត់សរសេរ ខ្ញុំបង្រៀនអីគាត់សរសេរនុ៎ង នៅពេលនុ៎ង ។ ដូច្នេះ នៅពេលដែលខ្ញុំបង្រៀនអ្នកសួរជាដំបូង វាមានកំណត់របស់មិត្តយើងម្នាក់ ហើយឯចំណែកខ្ញុំសួរលើកក្រោយដែលទាក់ទងដល់នយោបាយផង ទាក់ទងដល់ទិសនៃការស្រាវជ្រាវរកខ្មាំងនៃការសួរចម្លើយដែលខាងប្រគល់មកឱ្យផង វាមាននៅក្នុងកំណត់របស់បង ម៉ម ណៃ ។ នេះខ្ញុំសូមសរុបប៉ុណ្ណឹង ការបង្រៀនវាហូរហែអ៊ីចឹង វាមានរបត់វាពីរធំនេះ ខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** លោកជាអ្នកបង្រៀននូវបច្ចេកទេសសួរចម្លើយ អ្នកសួរចម្លើយនៅក្នុងមន្ទីរស-២១ ហើយតាមដែលលោកបានឆ្លើយនៅក្នុងអំឡុងពេលធ្វើសវនាការពីមុនៗមក ក៏លោកបានបញ្ជាក់ផងដែរថាលោកជាមនុស្សតែម្នាក់គត់ដែលទទួលពិនិត្យអាន វិភាគ នូវខ្លឹមសារនៃចម្លើយសារភាពទាំងនោះ ហើយនិងរាយការណ៍ជូនទៅថ្នាក់លើ ។ តើលោកអាចនិយាយប្រាប់ដល់អង្គសវនាការបានដែរឬទេថា អំពីទម្រង់ឬប្លង់នៃការសួរចម្លើយហ្នឹង មានបែងចែកជាផ្នែកៗ ដូចជាអំពីតួនាទីឋានៈអ្នកសួរចម្លើយ អំពីជីវប្រវត្តិរបស់អ្នកឃុំឃាំង សកម្មភាពពួកគេ នាំឱ្យមានការចាប់ខ្លួន ឬក៏ខ្សែបញ្ជើខ្សែក្បត់ ឬក៏បក្សពួកអ្នកជាប់ឃុំឃាំងជាដើម ។ តើលោកមានបានគិតគូរ ឬមានបានណែនាំដល់កម្រិតនៃបច្ចេកទេសក្នុងការសួរចម្លើយរបៀបនេះដែរឬទេ?

[១០:១១:៥៩]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ទីមួយ ក្នុងការអប់រំអ្នកសួរ សំខាន់ណាស់ហើយ ជាគន្លឹះគឺត្រូវតែឱ្យអ្នកសួរមានជំហរមួយដាច់ខាត ។ មនុស្សដែលចាប់មកហើយ ត្រូវចាត់ទុកជាខ្មាំង បើមិត្តឯងមិនចាត់ទុកជាខ្មាំង មិត្តឯងសួរចម្លើយមិនចេញទេ នេះបញ្ហាធំ ។ បញ្ហាទីពីរ កាលណាគេសុខចិត្តឆ្លើយហើយកម្មាភិបាលសួរចម្លើយត្រូវឱ្យសរសេរប្រវត្តិរូបហូរហែមក ចាប់ផ្តើមរួមចលនាក្បត់ពីថ្ងៃណា ខែណា ឆ្នាំណា អ្នកណា ហើយនិយាយអំពីសកម្មភាពក្បត់ហូរហែមក ។ ដូច្នេះ កាលណាគេរាប់សកម្មហូរហែមកឱ្យដកស្រង់ខ្លួនគេ ពីចម្លើយរបស់គេ តើអ្នកណាខ្លះដែលគេឆ្លើយដាក់?

ជាទូទៅ មិត្តយើងចេះសរសេរ គេសរសេរ ។ អ្នកណាដែលមិនចេះសរសេរទេ យើងខ្ញុំឲ្យថត នឹងម៉ាញ៉េ ហើយឲ្យអ្នកផ្សេងទៀតគេចម្លង ។ នេះជារបៀបសួរចម្លើយ បាន១ការសួរចម្លើយវាមាន ប្រវត្តិក្បត់ ប្រវត្តិសកម្មភាពផ្ទាល់ខ្លួនដែលធ្វើសកម្មភាពក្បត់នោះ ហើយនិងមនុស្សដែលគេឆ្លើយដាក់ ដែលជាតារាង ។ នេះចម្លើយបែបណាក៏ចេញមករបៀបតែមួយហ្នឹង ។ នេះសូមជម្រាបប្រាប់លោក ប្រធានប៉ុណ្ណឹង ។

**ស៖** ក្នុងសួរចម្លើយអ្នកជនជាប់ឃុំឃាំងម្នាក់ ហើយក្នុងអំឡុងពេលតែមួយ តើមនុស្សអ្នកសួរ ចម្លើយហ្នឹង ត្រូវការមានប៉ុន្មាននាក់? មានតែម្នាក់ ឬក៏ពីរនាក់ ឬក៏លើសពីពីរនាក់?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ជាគោលការណ៍មិនដែលមានពីរនាក់ទៅសួរចម្លើយម្នាក់ ទេ គឺម្នាក់ នេះជារឿងពិត ។ ក៏ប៉ុន្តែ បើម្នាក់សួរចម្លើយច្រើន អាហ្នឹងមែន ។ ឧទាហរណ៍សួរចម្លើយ ម្នាក់នេះ អក្សរ “ក” សួរមិនទាន់ចេញយកទៅទុក ទៅយកមួយមកទៀតមកសួរ តាមការដែលសម្រេច ពីមិត្តហ៊ី ។ ដល់អ៊ីចឹងវាអាចមនុស្សម្នាក់ អាចសួរចម្លើយពីរបីនាក់ឆ្លាស់គ្នារបៀបហ្នឹង ក៏ប៉ុន្តែមនុស្សពីរ នាក់ បីនាក់មិនសួរចម្លើយមនុស្សម្នាក់ទេ តែមួយ ។

**ស៖** លោកបាននិយាយអម្បាញ់មិញថា ការសួរចម្លើយប្រសិនបើគេព្រមព្រាងក្នុងការទទួលសារ ភាពដោយសរសេរខ្លួនគេ គឺអ្នកសួរចម្លើយឲ្យអ្នកដែលត្រូវសួរចម្លើយ អ្នកជាប់ឃុំឃាំងនោះសរសេរ១ ចម្លើយដោយខ្លួនគេ ។ នៅក្នុងការកំណត់ឲ្យគាត់សរសេរដោយខ្លួនគាត់ដូច្នេះ តើតម្រូវអ្នកសួរចម្លើយ ណែនាំគាត់ទៅអំពីប្លង់ដែលយើងបានលើក ដែលលោកបានឆ្លើយអម្បាញ់មិញ អំពីជីវប្រវត្តិ អំពីសកម្ម-ភាពក្បត់ អំពីខ្សែក្បត់អីអ៊ីចឹង ប្រាប់ឲ្យគេសរសេររបៀបអ៊ីចឹងដែរទេ? ឬក៏សរសេរស្រេចតែចិត្តរបស់ គេ របស់អ្នកដែលត្រូវសួរចម្លើយនោះ?

[១០:១៥:១៥]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! សកម្មភាពក្បត់ដែលគេត្រូវសារភាពសរសេរសារភាព ហ្នឹង ត្រូវតាមលំដាប់ពេលវេលា មុន ក្រោយច្បាស់លាស់ ។ ដូច្នេះ គ្មានប្លង់មួយជាកំណត់ថា យ៉ាង ម៉េច១ទេ គឺត្រូវប្លង់ដែលកំណត់គឺលំដាប់ពេលវេលានៃសកម្មភាពក្បត់របស់គេ ។ នេះសូមបញ្ជាក់ជូន ប៉ុណ្ណោះ ។

**ស៖** មានដែលជួបករណីអ្នកដែលជាប់ឃុំឃាំងនៅទីនោះ ហើយយកទៅសួរគាត់អត់ចេះអក្សរ គាត់មិនអាចមានសមត្ថភាពអាចសរសេរដោយខ្លួនឯងបានមានដែលជួបករណីដូច្នេះដែរឬទេ? ហើយបើ

ជួបធ្វើយ៉ាងដូចម្ដេច?

**ឆ៖** រឿងនេះមានជាហូរហែ ប៉ុន្តែបើតាមខ្ញុំចាំ គឺកាលណាបើជួបករណីនេះ ត្រូវឲ្យអ្នកសារ-ភាពនិយាយដាក់ខ្សែអាត់ ហើយអ្នកការិយាល័យហ្នឹង ចម្លងសំឡេងនេះពីខ្សែអាត់ផ្ញើទៅខាងលើ ។នេះសូមបញ្ជាក់ជូនលោកប្រធានប៉ុណ្ណេះ ។

**ស៖** ចុះអំពីពេលវេលាវិញ ពេលវេលានៃការប្រតិបត្តិការក្នុងការសួរចម្លើយជនជាប់ឃុំឃាំងប្រព្រឹត្តនៅក្នុងមន្ទីរស-២១ ហ្នឹង ប្រព្រឹត្តទៅយ៉ាងដូចម្ដេចទៅ? ពេលវេលាដែលកំណត់ថា ធ្វើការងារសួរចម្លើយអ្នកទាំងនោះ តើអ្នកសួរចម្លើយហ្នឹងគេប្រតិបត្តិការនៅពេលណាខ្លះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ជាកម្មវិធីប្រចាំថ្ងៃរបស់កម្មាភិបាលសួរចម្លើយ គឺត្រូវចាប់ផ្ដើមពីពេលព្រឹកពីម៉ោងប្រាំពីរព្រឹក រហូតដល់ម៉ោងដប់មួយថ្ងៃត្រង់ នេះបើតាមខ្ញុំចាំ ។ ហើយល្ងាចពីម៉ោងពីររហូតដល់ម៉ោងបួន ម៉ោងប្រាំ ម៉ោងបួន ។ ហើយយប់តទៅទៀតពីម៉ោងប្រាំពីរ ដល់ម៉ោងដប់ររល់ជាប់អ៊ីចឹង ។ នេះកម្មវិធីប្រចាំថ្ងៃរបស់កម្មាភិបាលសួរចម្លើយ សូមគោរពជម្រាបប៉ុណ្ណេះ ។

**ស៖** តាមធម្មតានៅក្នុងការសួរចម្លើយបុគ្គលម្នាក់ តើអ្នកសួរចម្លើយនៅមន្ទីរសន្តិសុខស-២១មានកំណត់ទេ? ឧបមាថា សួរចម្លើយបុគ្គលម្នាក់ហ្នឹង មានចំនួនពីរដង ឬក៏បីដងយ៉ាងច្រើន មានកំណត់ដូច្នេះទេ ឬក៏អត់កំណត់ទេ? វាអាស្រ័យលើលទ្ធផលនៃការធ្វើចម្លើយហ្នឹងបានឬមិនបាន ឬក៏ស្ថានភាពនៃការពាក់ព័ន្ធវាមានទំហំធំ គឺអាចសួរច្រើនមិនកំណត់?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ! ចំនួនដែលត្រូវសួរនេះ ច្រើនលើក ឬតិចលើក យូរឆាប់ប៉ុនណា វាស្រ័យលើសេចក្ដីសារភាពរបស់គេ ។ ទីមួយ បើសេចក្ដីសារភាពនេះផ្ទាល់ខ្ញុំបាទមើលទៅសមរម្យគ្រប់គ្រាន់ហើយ ក៏បញ្ចប់ការសួរចម្លើយនោះទៅ ។ ក៏ប៉ុន្តែ មនុស្សខ្លះដែលមានសារសំខាន់ខ្លាំងពេក ដូច កុយ ធួន អ៊ីចឹង ។ សួរចម្លើយដល់ទៅប្រាំលើក បើតាមខ្ញុំចាំ ។ ខ្ញុំសួរអស់ពីរលើកនេះហើយខាងលើឲ្យប្រគល់ទៅឲ្យមិត្តប៉ុន សួរ ។ ដូច្នេះ សួរចម្លើយ កុយ ធួន ប្រាំលើក ដូច្នេះវាអាស្រ័យនឹងគេឆ្លើយពេញចិត្តយើង ពេញចិត្តខាងលើ ឬមិនពេញចិត្ត ។ វាអាស្រ័យនៅរឿងឯណោះទៅវិញទេនេះសូមជម្រាបលោកប្រធាន ។

[១០:១៩:២៥]

**ស៖** អ៊ីចឹងអាចសរុបមកវិញ គឺមានន័យថា ទៅតាមមុខសញ្ញានៃអ្នកដែលត្រូវសួរចម្លើយនោះសំខាន់ ឬមិនសំខាន់ ហើយបានលទ្ធផលមក គឺបញ្ជូនទៅលោក លោកវិភាគហើយបញ្ជូនទៅថ្នាក់លើ

ហើយបើថ្នាក់លើហ្នឹង ត្រូវការតម្រូវឲ្យមានការសួរបន្ថែមនូវចំណុចណាខ្លះទៀតតាមការចង្អុលបង្ហាញនោះ គឺប្រតិបត្តិការនៃអ្នកសួរចម្លើយនឹងប្រព្រឹត្តទៅជាបន្តទៀត តាមការចង្អុលបង្ហាញរបស់ថ្នាក់លើអ៊ីចឹងមែនទេ?

**ឌ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! គឺពិតជាអ៊ីចឹងមែន ។

[១០:២០:០៩]

**ស៖** តើមានករណីសួរចម្លើយអ្នកជាប់ឃុំឃាំងហ្នឹង សួរច្រំដែលៗ ច្រើនលើកច្រើនសា និងមានការបង្ខិតបង្ខំឲ្យអ្នកត្រូវសួរចម្លើយនោះ ឲ្យធ្វើការសរសេរនូវសេចក្ដីព្រាងចម្លើយសារភាពជាច្រើនលើកច្រើនសាដែរឬទេ មុននឹងយកជាការបាននោះ?

**ឌ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងនេះមាន មានហួរមានហែ ដូច្នេះមុននឹងយកជាការជូនអ៊ីមកត្រឹម មិត្តហ៊ី ទេ ហើយភាគច្រើនធ្លាក់មកដល់ខ្ញុំ ។ ខ្ញុំឲ្យសួរត្រង់នេះថែមទៀត ត្រង់នោះថែមទៀត ដូច្នេះមិនយកជាស្ថាពរ ចម្លើយជាសាពរ វាមានសាចុះសាឡើងច្រើន នៅក្នុងក្របខ័ណ្ឌស-២១ ហ្នឹងឯងហើយ ជាអ្នកសម្រេច ។ នេះសូមជម្រាបប្រសាសន៍លោកប្រធានប៉ុណ្ណឹង ។

**ស៖** តាមការយល់ឃើញរបស់លោកនៅពេលនោះ តើលោកជឿដែរទេថាចម្លើយសារភាពដែលទទួលបាននៅពីការសួរចម្លើយនៅមន្ទីរ ស-២១ហ្នឹង វាឆ្លុះបញ្ចាំងពីការពិតដែរឬទេ?

**ឌ៖** ជម្រាបប្រសាសន៍លោកប្រធាន! ការសួរចម្លើយទាំងអស់ ខ្ញុំមិនដែលទទួលស្គាល់ថា វាជាការពិតទេ ។ កាលដែលខ្ញុំជាប់គុក ខ្ញុំឆ្លើយក៏ខ្ញុំមិនដែលបានជាឆ្លើយការពិតឲ្យគេទាំងអស់ឲ្យគេដែរ ។ ហើយនៅម-១៣ មានមនុស្សម្នាក់ដែលខ្ញុំខំសួរចម្លើយដោយផ្ទាល់ខ្លួន ចុងបញ្ចប់ ខ្ញុំអាចសរុបបានថាសាច់រឿងដែលគេនិយាយអាចពិតយ៉ាងច្រើនណាស់ហាសិបភាគរយ ។ ឯចំណែក មនុស្សដែលគេឆ្លើយដាក់ ពិតមិនដល់ម្ភៃភាគរយទេ ។ នេះជាការសន្និដ្ឋានរបស់ខ្ញុំ ។

ឯចំណែកខាងលើវិញ ក៏ខ្ញុំជឿថា យល់មិនខុសពីខ្ញុំប៉ុន្មាន ។ គេមិនជឿថា ពិតទាំងអស់ទេ ។ ខ្ញុំសូមជូនឧទាហរណ៍មួយដែលខ្ញុំនៅចាំមិនភ្លេច ចម្លើយ កុយ ធួន ឆ្លើយដាក់កម្មាភិបាលម្នាក់ ដែលខ្ញុំស្គាល់ ខ្ញុំចង់សុំអង្វរកចេញមតិតវ៉ាកុំឲ្យគាត់ចាប់ ។ នេះអង្គាល់លោកគ្រូ សុន សេន នៅធ្វើមេខ្ញុំ ។ ខ្ញុំទូរស័ព្ទទៅជម្រាបគាត់ថា “អ្ហែ! មនុស្សនេះ ដូចជាមិនអីទេបង” គាត់ឆ្លើយមកខ្ញុំវិញផ្ទួងថា “ឌុច ណ៎ាចម្លើយអាឃួន” ។ ឥឡូវ ខ្ញុំសូមលើកពាក្យថា ចម្លើយអាឃួន ណ៎ាមួយម៉ាត់នេះ មកជូនអង្គជំនុំជម្រះយើងពិចារណា ។ មានន័យថា អ្នកណាឆ្លើយគ្រាន់បើ បើ កុយ ធួន ឆ្លើយហើយមិត្តឯងទប់មិនជាប់ទេ

ទោះពិតក៏ដោយ មិនពិតក៏ដោយ នេះមានន័យអ៊ីចឹង ។

សរុបមក អ្នកណាក៏មិនដែលទទួលស្គាល់ថា ចម្លើយរបស់នគរបាលពិតដែរ ។ នេះគឺជាច្បាស់លាស់អ៊ីចឹង ផ្ទាល់ខ្លួនខ្ញុំក៏មិនជឿថាពិត លោកគ្រូ សុន សេន មេខ្ញុំក៏ជឿថា មិនពិត ប៉ុល ពត ខ្លួនគាត់ហ្នឹងក៏ជឿថា មិនពិត មានសំណល់នៅឯកសារថ្ងៃ៩ តុលា ១៩៧៥ ថែមទៀត ជាភស្តុតាងបញ្ជាក់ ។ ខ្ញុំសូមសរុបប៉ុណ្ណេះ ។ សូមជម្រាបប្រសាសន៍លោកប្រធាន សូមចប់សំណួរនេះ ។

[១០:២៤:០០]

**ស៖** លោក កាំង ហ្កេកអ៊ាវ នៅក្នុងប្រតិបត្តិការនៃការសួរចម្លើយអ្នកដែលជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ តើមានករណីណាខ្លះ ដែលលោកបានចូលរួមសួរចម្លើយដោយផ្ទាល់? សួរចម្លើយអ្នកជាប់ឃុំឃាំងនៅទីនោះ ដោយផ្ទាល់ ដោយខ្លួនឯងដែរឬទេ? បើមាន មានប៉ុន្មានករណីដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! កាលដែលខ្ញុំនៅធ្វើជាអនុប្រធាន ខ្ញុំដើរជាមួយណាត ។ ពេលហ្នឹងមានប្រតិកម្មពី ឈិត អ៊ីវ ធ្វើឲ្យខ្ញុំទ្រាំមិនបាន ក៏ចូលទៅសួរចម្លើយជំនួសមិត្តម៉ុន ឈ្មោះដើម ម៉ា ម៉េងឃាង នៅនឹងមុខ ណាត ហ្នឹង ។ អាហ្នឹងម្តង ។ អានោះសួរផ្ទាល់ហើយ វាអស់ពីចិត្ត ពីចង់រហូតដល់ ឈិត អ៊ីវ គាត់សុទ្ធចិត្តចុះចាញ់ខ្ញុំ មិនព្រមប៊ានជជែកតទៅទៀត សុទ្ធចិត្តឆ្លើយជាមួយ ម៉ា ម៉េងឃាង បានខ្ញុំដើរចេញទៅ ។ មុនៗនឹងបានដើរចេញទៅហ្នឹង នេះពេលឃើញ ណាត គាត់ចង់វ៉ៃខ្លាំងពេកទេ ហើយខ្ញុំក៏មិនឲ្យគាត់វ៉ៃដែរ ព្រោះឋានៈគាត់ វាលេខាកងពល មានឋានៈ បើតាមនិយាយអំពីមានឋានៈមកនគរបាលជាតិវិញ មានឋានៈស្មើនឹងអភិបាលនគរបាលជាតិ ។ ខ្ញុំមិនចង់ឲ្យគាត់យកដៃទៅប្រឡាក់វ៉ៃទេ ឯចំណែកខ្ញុំតាំងខ្លួនខ្ញុំត្រឹមតែស្នងការ ដូច្នេះខ្ញុំសុទ្ធចិត្តទះកំផ្លៀង ឈិត អ៊ីវ មួយដៃពីរល្មមៗទេ ។ ក្រោយពីមក ឈិត អ៊ីវ បាក់ប៉កខ្លបខ្លាចសម្តីខ្ញុំហើយ ។ ជាទ្រឹស្តីខ្ញុំ សូមនិយាយវែងលើសបន្តិចចុះ ជាទ្រឹស្តីខ្ញុំ កាលណាគេមិនទាន់ទទួលខ្ញុំខ្លួនថាគេខុស យើងវ៉ៃគេច្រឡោត បើកាលណាគេទទួលស្គាល់ថាគេខុសហើយ យើងវ៉ៃបន្តិចបន្តួច គេខ្លាចយើងកាន់តែខ្លាំងថែមទៀត ។ នេះជាទ្រឹស្តីខ្ញុំដែលខ្ញុំធ្លាប់អនុវត្ត ។

ខ្ញុំសូមតទៅទៀត ជាមួយនឹង កុយ ធួន ខ្ញុំសួរផ្ទាល់។ លើកទីមួយក៏ខ្ញុំ លើកទីពីរក៏ខ្ញុំ ខ្ញុំសួររឿង កុយ ធួន នេះ ខ្ញុំនិយាយច្រើនដងហើយ ខ្ញុំសូមមិននិយាយលម្អិតជូនលោកប្រធានអំពីរបៀបសួររបស់ខ្ញុំតទៅទៀតទេ ។ ប៉ុន្តែ លើកទីមួយនិងលើកទីពីរខ្ញុំ ។ ដល់បានពីរលើកហ្នឹងហើយ មេឲ្យខ្ញុំប្រគល់ កុយ ធួន ឲ្យទៅ មិត្តប៉ុន សួរចម្លើយ ។ ខ្ញុំប្រគល់ ។ ខ្ញុំលែងសួរអីនេះហើយ ។ មែនខ្ញុំស៊ីញ៉េ ខ្ញុំចារស្អីៗ មាន

លើសិទ្ធិចម្លើយនៃការសួរចម្លើយ ម៉ែន សាន ហៅ យ៉ា ។ ទូរស័ព្ទមេបញ្ជាមកជាប់ ម៉ែន សាន ហៅយ៉ា នេះមួយ ។ សៀត ឆែ ហៅ ទុំ នេះពីរ មេចារមក ជួនទាំងសរសេរសំបុត្រមកក្រើនរំឭក សៀត ឆែ ហៅ ទុំ ហ្នឹងទៅទៀត ។ ដូច្នេះ ពេលនោះ ខ្ញុំអត់ចុះទៅផ្ទាល់ទេ ពេលដែលខ្ញុំចុះទៅផ្ទាល់ គ្មានអ្នកណាចុះទេ គឺមានតែខ្ញុំម្នាក់ឯង ។

ដូច្នេះ សរុបមកការសួរចម្លើយផ្ទាល់មានតែមួយ គឺ កុយ ធួន ។ ការសួរចម្លើយឆក់កណ្តៀតនៅពេលដែលខ្ញុំជាអនុប្រធាន មានជាមួយ ឈិត អ៊ីវ ។ ឯចំណែកខ្ញុំគ្រប់គ្រងពីលើ ហើយមេមកពីលើទៀត គឺមាន បើតាមខ្ញុំចាំមានតែពីរទេ គឺសួរចម្លើយ ម៉ែន សាន ហៅ យ៉ា ហើយនិងសួរចម្លើយសៀត ឆែ ហៅ ទុំ ។ នេះសូមជូនលោកប្រធានលម្អិត បញ្ហានេះប៉ុណ្ណេះ។

**ស៖** វាមានលក្ខណៈសំខាន់យ៉ាងម៉េចទៅ ឈ្មោះ កុយ ធួន នេះ ទើបលោកមានការយកចិត្តទុកដាក់រហូតដល់មានការសួរចម្លើយដោយខ្លួនឯងផ្ទាល់ ហើយមានច្រើនលើកច្រើនសា? តើគាត់មានតួនាទីឋានៈយ៉ាងដូចម្តេចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ឬនិងក្នុងរដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! តួនាទីរបស់ កុយ ធួន ក្នុងបក្ស ។ គាត់និយាយខ្លួនគាត់នៅក្នុងសេចក្តីសារភាពហ្នឹង ឬក៏ ម៉ែន សាន និយាយក៏មិនដឹងទេ គាត់ជាបុគ្គលទីប្រាំបួននៃបក្សកុម្មុយនីស្តកម្ពុជា។ ដូច្នេះ គាត់ជាសមាជិកមជ្ឈិមបក្សពេញសិទ្ធិ ជាបុគ្គលទីប្រាំបួននៃបក្សកុម្មុយនីស្តកម្ពុជា។ តួនាទីក្នុងរដ្ឋាភិបាលមុនដំបូង មុន១៧មេសា ហើយនិងក្រោយ ១៧មេសា បន្តិច គាត់ជាលេខាភូមិភាគឧត្តរ ។ ក្រោយមកគាត់ជាលេខាគណៈកម្មាធិការក្រសួងពាណិជ្ជកម្មរដ្ឋ ។ ដល់គាត់មានកំហុស ដូចខ្ញុំបានរាយការណ៍ជម្រាបលោកប្រធានហើយ--

**អ្នកបកប្រែ៖**

សូមទោសលោកចៅក្រមប្រធាន! សូមឲ្យជនជាប់ចោទ សាឡើងបន្តិចទាន! កន្លែងចុងក្រោយនេះ អ្នកបកប្រែស្តាប់មិនទាន់ទេទាន ។

**ប្រធានអង្គជំនុំ៖**

សូមលោក កាំង ហ្កេកអ៊ាវ ឆ្លើយសាឡើងវិញករណីចុងក្រោយនេះ ព្រោះអ្នកបកប្រែបកមិនទាន់ទេ ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន!កុយ ធួន នេះ តួនាទីក្នុងបក្ស គាត់ជាសមាជិកមជ្ឈិមពេញសិទ្ធិ ។ បើរាប់ពី ប៉ុល ពត មកដល់ កុយ ធួន ជាទីប្រាំបួន ។ មុន១៧មេសា និងក្រោយ១៧មេសាបន្តិច

កុយ ធួន ជាលេខាគណៈកម្មាធិការបក្សភូមិភាគឧត្តរចាស់ ។ ដល់ក្រោយ១៧មេសា បន្តិចមក បក្សឧទ្ទេសនាមគាត់ ចាត់តាំងគាត់ជាលេខាគណៈកម្មាធិការពាណិជ្ជកម្មរដ្ឋ ។ នេះសារសំខាន់របស់គាត់គឺអ៊ីចឹង ។ ក៏ប៉ុន្តែ រឿងដែលគាត់ធ្វើឲ្យបក្សបែកមុខខ្មាសសាកលលោក ក៏ដូចជាខ្មាសប្រជាជនកម្ពុជា គឺដោយសារតែគាត់ទៅសម្លាប់ប្រុសម្នាក់ ឈ្មោះ មិត្តឡុង ដែលគេប្រពន្ធ មិត្តឡុង ត្រូវគាត់ខូចកាចជាមួយ ហើយមិត្តឡុង គាត់ឡូឡា គាត់សម្លាប់ដោយដៃឯង ហើយនិងកូនចៅគាត់ប៉ុន្មាននាក់នោះ ។ បក្សដកសិទ្ធិគាត់យកទៅទុកនៅថ្ងៃ៨ មេសា ១៩៧៦ ។ ដូច្នេះ អំពើសកម្មភាពរបស់ កុយ ធួន គេតាមដានយូរហើយ ។ ដូច្នេះ ហើយបានជាដល់ថ្ងៃ២៥ ធ្នូ ១៩៧៦ នេះ គេចាប់ កុយ ធួន ប្រគល់ទៅឲ្យស-២១ មេខ្ញុំត្រៀមៗឲ្យខ្ញុំចាំសួរចម្លើយ កុយ ធួន តាំងពីមុនមកទៀត ប្រហែលជាតាំងថ្ងៃម្ភៃ ត្រៀមមតិ ត្រៀមទស្សនៈខ្ញុំកុំឲ្យចាញ់ប្រាប កុយ ធួន អ៊ីចេះមួយ អ៊ីចុះពីរត្រៀម ។ ដូច្នេះ សារសំខាន់គាត់ គឺអ៊ីចឹង បានៗគេប្រគល់មកឲ្យខ្ញុំដាច់មុខ មិនឲ្យអ្នកណាប៉ះពាល់ ។ នេះសារសំខាន់ បើតាមខ្ញុំមើលទៅអ៊ីចឹង ។

ឯចំណែកចម្លើយសារភាពរបស់ កុយ ធួន ខ្ញុំសូមជម្រាបម្តងហើយ ម្តងទៀត គាត់សរសេរបានបួនប្រាំទំព័រ ខ្ញុំហ្វូតូកូពី អង្កាល់នោះហ្វូតូកូពីនៅក្រផង ហ្វូតូកូពីភ្លាមៗ ហៅមិត្ត ផន នីរសារលោកគ្រូសុន សេន ឲ្យយកភ្លាម ។ ដូច្នេះ ខ្ញុំគ្មានបានមើល គ្មានបានចុចសួរអីថែមទៀត នៅលើគាត់ ដូច្នេះ សារសំខាន់របស់គាត់យ៉ាងម៉េច ខ្ញុំគ្រាន់តែសូមជូនអំពីបាតុភាពដែលកើតមានតាំងពីគាត់នៅខាងក្រៅរហូតដល់ពេលសួរចម្លើយនេះ មេអនុវត្តបែបនេះជាមួយនឹងគាត់ ។ សូមរាយការណ៍ជូនប៉ុណ្ណេះ ។

**ស៖** ចុះមនុស្សពីរនាក់ទៀត ដូច សៀត ឆែ ហៅ ទុំ មានឋានៈតួនាទីយ៉ាងម៉េចដែរ បានជាខាងថ្នាក់លើមានការយកទៅដាក់រហូតដល់លោក មានការត្រួតពិនិត្យមើលផ្ទាល់ លើការសួរចម្លើយក្រុមសួរចម្លើយករណីនេះ ករណី ម៉ែន សាន ហៅ យ៉ា ដូចគ្នា ។ មិនបាច់និយាយអំពីសកម្មភាពទេ ចង់ដឹងថាឋានៈតួនាទីរបស់គាត់យ៉ាងម៉េច? បានជាមានការយកចិត្តទុកដាក់ពីថ្នាក់លើខ្លាំងយ៉ាងនេះ រហូតដល់បង្គាប់បញ្ជាលោកធ្វើការផ្ទាល់ ឬក៏ធ្វើការត្រួតពិនិត្យលើអ្នកសួរចម្លើយហ្នឹងយ៉ាងយកចិត្តទុកដាក់ទៀតផងនោះ ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ម៉ែន សាន ហៅយ៉ា នេះ គាត់សមាជិកមជ្ឈិមពេញសិទ្ធិជាបុគ្គលទីដប់ ។ កុយ ធួន ទីប្រាំបួន គាត់ទីដប់ ។ មុន១៧មេសា ១៩៧៥ គាត់ជាសមាជិកអ្នកដឹកជញ្ជូនអាវុធឆ្លងកាត់វៀតណាម ក្រោយមកត្រូវឧទ្ទេសនាមជាអនុលេខាសេនាធិការ ។ ដល់ក្រោយមក

ទៀតបានប៉ុន្មានខែឧទ្ទេសនាមគាត់ជាលេខាភូមិភាគព្រៃសាន ។ ដូច្នេះហើយ បានជាខាងលើចាប់អារម្មណ៍ពីរឿងបង ម៉ែន សាន ហៅ យ៉ា មានការជិតស្និតជាមួយនឹងបក្សពលករវៀតណាម ដែលក្រោយមកប្រែឈ្មោះជាបក្សកុម្មុយនីស្តវៀតណាមនេះ ។ នេះជាការចាប់អារម្មណ៍យូរហើយរបស់បក្សកុម្មុយនីស្តទៅលើបង ម៉ែន សាន ហៅយ៉ា នេះ នេះទីមួយ ។

ទីពីរ សៀត ឆែ ហៅទុំ ៗ គាត់ជាសមាជិកមជ្ឈិមត្រៀម។ ត្រៀមតាំងពីសន្និបាតមុនម្ល៉េះ ។ ដល់សន្និបាតឆ្នាំ១៩៧៦ បក្សមិនទាន់ឲ្យគាត់ឡើងជាសមាជិកមជ្ឈិមពេញសិទ្ធិទេ ដោយសង្ស័យគាត់ទាក់ទងជាមួយរឿងយួនហ្នឹងឯង ។ ក៏ប៉ុន្តែ ឧទ្ទេសនាមគាត់ឲ្យកាន់កាប់ខាងព័ស្តុភារដំបូង ។ ដល់ក្រោយមក បានយកគាត់មកធ្វើអនុលេខាគណៈកម្មាធិការសេនាធិការវិញ ។ ដូច្នេះ គាត់ជាសមាជិកមជ្ឈិមត្រៀម ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណឹង ។

[១០:៣៤:១១]

**ស៖** អរគុណ ។ លោក កាំង ហ្គេកអ៊ាវ តើលោកនិយាយបានយ៉ាងម៉េចដែរអំពីការកំណត់អត្តសញ្ញាណនៅក្នុងឯកសារមួយនៃកំណត់ហេតុចម្លើយសារភាពរបស់ លី ផែល ដែលនៅក្នុងកំណត់ហេតុនោះ គឺដាក់ថា អ្នកសួរចម្លើយទីមួយគឺ ឌុច? នៅក្នុងចម្លើយរបស់សារភាពរបស់ លី ផែល ដែលមានលេខERN ជាភាសាខ្មែរ 001726 ម្តងទៀត 00172688 ដល់ 00172771 ។ ជាភាសាអង់គ្លេស ERN 00223138 ដល់ 00223141 ។ ជាភាសាបារាំង ERN 00296036 រហូតដល់ 00296036 ដដែល ។ ហើយនៅក្នុងនេះគឺយើងយកតែទំព័រមួយគឺត្រង់ ERN 00172738 ។

ក្រឡាបញ្ជីមានឯកសារថតចម្លងទេ? ជូនទៅជនជាប់ចោទ នូវទំព័រចុងក្រោយគឺ 00172738 ។ ខាងសហព្រះរាជអាជ្ញា តើអាចបញ្ចាំងនូវឯកសារនេះបានដែរឬទេ?

លោកអាចពន្យល់បានទេ ពីព្រោះអំមិញ គឺយើងមានការចាប់អារម្មណ៍មួយគឺថា នៅក្នុងប្រតិបត្តិការរបស់លោក ក្នុងនាមលោកជាអនុប្រធាន ហើយនិងក្រោយមកលោកជាប្រធាន ការសួរចម្លើយគឺមានការពាក់ព័ន្ធ ទីមួយកាលពីលោកជាអនុប្រធាន គឺមានការធ្វើអន្តរាគមន៍នៅក្នុងករណីក្នុងការសួរចម្លើយ ឈិត អ៊ីវ ជាមួយនឹងឈ្មោះ ណាត នៅក្នុងការសួរចម្លើយដែលមិនបានលទ្ធផលនោះ ។ ហើយបន្ទាប់មកគឺ លោកបានឆ្លើយថា មានតែមនុស្សម្នាក់គត់គឺ កុយ ធួន ដែលលោកទទួលបន្ទុកក្នុងការសួរចម្លើយដោយផ្ទាល់ខ្លួនឯង តាមការបង្គាប់បញ្ជារបស់ថ្នាក់លើ ហើយបន្ទាប់មកគឺមានការត្រួតពិនិត្យដោយផ្ទាល់បាន ន័យថាយកទៅដាក់ទៅលើក្រុមអ្នកសួរចម្លើយចំពោះមនុស្សពីរនាក់ទៀត គឺ សៀត ឆែ

ហៅ ទុំ ហើយនិងឈ្មោះ ម៉ែន សាន ។ ដោយឡែកគឺឯកសារនេះ គឺមានចំណារអ្នកសួរហ្នឹង គឺថ្ងៃទី១៧ ខែ០៩ ឆ្នាំ១៩៧៦ ។ អ្នកសួរទីមួយ ឌុច អ្នកសួរទីពីរ ប៉ុន។ លោកអាចបញ្ជាក់ពីចំណុចនេះបានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ឯកសារនេះ បើបញ្ចាំងនៅលើអេក្រង់ អក្សរជាខ្មែរល្អ ពីព្រោះអក្សរជាខ្មែរ វាបង្ហាញឲ្យឃើញថា អក្សរពីរបីម៉ាត់នេះ ជាអក្សរខ្ញុំសុទ្ធសាធ ។

**ស៖** សូមសហព្រះរាជអាជ្ញា អាចបញ្ចាំងចំណុចទំព័រ ដែលយើងនឹងប្រាប់គឺយកតែមួយទំព័រទេ ERN ជាភាសាខ្មែរគឺ 00172738 នៅក្នុងចម្លើយសារភាពរបស់ លី ផែល ។

**លោក វីលៀម ស្មីត៖**

លោកប្រធាន គឺយើងមានឯកសារហ្នឹងនៅលើអេក្រង់កុំព្យូទ័រ របស់សហព្រះរាជអាជ្ញា សូមលោកប្រធានប្រាប់ខាងផ្នែកសោតទស្សន៍ ឲ្យបញ្ចាំងអេក្រង់នៅលើអេក្រង់ធំ ។

**ប្រធានអង្គជំនុំ៖**

ខាងសោតទស្សន៍ សូមភ្ជាប់ប្រព័ន្ធរូបភាពមកកុំព្យូទ័ររបស់សហព្រះរាជអាជ្ញា ។

[១០:៤០:២០]

សូមជនជាប់ចោទពិនិត្យមើលលើអក្សរនេះ អក្សរចុងក្រោយនេះមានប៉ុន្មានពាក្យទេ យើងយកតែទំព័រចុងក្រោយ ដែលវាមានបញ្ហា ដែលយកមកពិភាក្សាដេញដោលនាពេលនេះ ពីព្រោះដូចខ្ញុំបានជម្រាបអ៊ីចឹង គឺតាមចម្លើយរបស់លោកគឺមានការពាក់ព័ន្ធក្នុងការសួរផ្ទាល់ហ្នឹង គឺមានមនុស្សតិចតួច ហើយមិនមានឈ្មោះនេះទេ ។ ប៉ុន្តែកំណត់ហេតុនៃការចម្លើយសារភាពអ្នកនេះ បែរជាមានឈ្មោះអ្នកសួរចម្លើយហ្នឹង គឺលោកទីមួយ អ្នកសួរចម្លើយទីមួយគឺ ឌុច ។ តើលោកបកស្រាយសម្រាប់អង្គសវនាការយ៉ាងដូចម្តេចទៅវាងចម្លើយដែលលោកបានឆ្លើយកន្លងមកនេះ ហើយនិងចំណារនៅក្នុងឯកសារនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ចំណារខ្ញុំនេះ នៅលើច្បាប់វាយអង្គុលីលេខ ។ បានជាខ្ញុំបានិយាយអ៊ីចឹង មិត្តហ៊ុយ នេះ ទទួលភារៈខាងវាយអង្គុលីលេខ ។ ហើយខ្ញុំនៅតែនិយាយថា ចំណារខ្ញុំនេះធ្វើឡើងក្រោមបញ្ជាមេ ពីព្រោះខាងបូព៌ាគេចូលចិត្តណាស់ សួរឲ្យមានគ្នាច្រើនអ៊ីចឹង ឧទាហរណ៍កំណត់សួរចម្លើយរបស់មន្ទីរសន្តិសុខតំបន់២១ ដែលសួរចម្លើយ លី ផែល ខ្លួនឯងនេះ មុននឹងបញ្ជូនសាមីខ្លួននេះមកស-២១ ខាងតំបន់២១ គេសួរគ្នាគេប្រាំបួននាក់ ។ នេះគេសួរចម្លើយ លី ផែល។ ឯកសារនេះខ្ញុំទើបនឹងឃើញអង្កាល់ ដែលនៅក្នុងការិយាល័យស៊ើបអង្កេតដែរ ។ ខ្ញុំសូមត្រឡប់មកឯកសារ ខ្ញុំវិញនេះ ។ ឯកសារនេះមិត្តប៉ុន សួរមែន តែវាចេញពីដៃមិត្តប៉ុន មកដល់ខ្ញុំហើយ មេថា ឥឡូវដាក់ពីរ

នាក់ទៅ មិត្តឯងមួយ មិត្តប៉ុនមួយ។ ដូច្នេះហើយបានជាអក្សរខ្ញុំទាំងអស់ ។ សួរនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦ អ្នកសួរទីមួយ ខ្ញុំស៊ីញ៉េ ហើយខ្ញុំដាក់ឈ្មោះខ្ញុំទៀត។ ទីពីរ ខ្ញុំអត់មានស៊ីញ៉េកើតទេ ស៊ីញ៉េរបស់គេ ខ្ញុំដាក់ឈ្មោះ ប៉ុន ។ ដូច្នេះ ជាអក្សរដៃខ្ញុំទាំងអស់ មិនមែនអក្សរមិត្ត ប៉ុន ទេ ។ ប្រសិនបើ មិត្តប៉ុន គាត់សួរជាទីពីរ ហើយខ្ញុំសួរជាទីមួយ ត្រូវតែមិត្តប៉ុន សរសេរទាំងអស់ ខ្ញុំចាំតែស៊ីញ៉េទេ ព្រោះខ្ញុំធ្វើធំជាងមិត្តប៉ុន ត្រូវតែមិត្តប៉ុន គាត់សរសេរសព្វគ្រប់ឲ្យខ្ញុំទាំងអស់ ខ្ញុំស៊ីញ៉េ ។ ឯចំណែក ខ្ញុំសរសេរ គឺដើម្បីបង្គ្រប់កិច្ច និងបញ្ជូនឯកសារហ្នឹង ទៅបូព៌ាតាមបញ្ជារបស់មេ ។ ដូច្នេះ ខ្ញុំនៅតែបញ្ជាក់ថាទីមួយ អក្សរនេះពិតជាអក្សរខ្ញុំ ។ ទីពីរ ខ្ញុំសរសេររបៀបនេះ តាមបញ្ជាមេ ។ ទីបី ដើម្បីឲ្យវាមានរូបភាពមួយថាសួរគ្នាច្រើនដូចខាងបូព៌ាដែរ ។ នេះគឺខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ។ ឯចំណែក ឯកសារជាបារាំងអីគ្មានអក្សរដៃខ្ញុំនៅហ្នឹង ដូច្នេះពិបាកយល់ ។ ដូច្នេះ ខ្ញុំសូមយកអក្សរខ្មែរហ្នឹងដើម្បីស្រួលយល់ ។

សូមរាយការណ៍ ជម្រាបលោកប្រធានប៉ុណ្ណោះ ។ សូមចប់ ។

[១០:៤៣:៣៩]

**ស៖** សូមអរគុណ។ ឥឡូវនេះ ដោយសារដល់ពេលត្រូវឈប់សម្រាកផង ហើយឌីវីឌី ក៏អស់ដែរ ។ អ៊ីចឹង អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងដប់មួយ ទើបបន្តដំណើរការនីតិវិធីសវនាការតទៀត ។

*[សវនាការសម្រាកពីម៉ោង ១០:៤៤នាទី ដល់ម៉ោង ១១:០៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការសវនាការដេញដោល ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក កាំង ហ្គេកអ៊ាវ ការអនុវត្តនៅមន្ទីរស-២១ ក្នុងការសួរចម្លើយដល់អ្នកជាប់ឃុំឃាំង តើសុទ្ធតែត្រូវប្រើទារុណកម្មគ្រប់ករណីទាំងអស់ដែរឬទេ ឬក៏មានករណីលើកលែងដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ភាគច្រើនលើសលប់ ស្ទើរតែទាំងអស់សុទ្ធតែត្រូវការធ្វើទារុណកម្ម លើកលែងដែលខ្ញុំបានដឹងច្បាស់ ហើយធានាចំពោះមុខអង្គសវនាការយើងនេះមាន កុយ ធួន មួយគឺអត់ ។ ដោយឡែកតាមឯកសារនៅសល់ ហើយខ្ញុំសន្និដ្ឋានចម្លើយប៉ុន្មានដែល ណាត គាត់ឲ្យបង

ម៉ម ណៃ សួរដើម្បីផ្ទៀងកសារក្លែងបន្លំថា ដោះលែងនុំង ក៏ខ្ញុំជឿថា អត់ទារុណកម្ម ។ ចំពោះដោយឡែក ខ្ញុំនិយាយនេះវាចំមុខពេកអ៊ីចឹង ពិបាក ប្រហែលជា មិនប្រហែលទេច្បាស់ ករណីលោកសាស្ត្រាចារ្យ ភីង តុន គឺអត់ទារុណកម្ម ព្រោះបុគ្គលនុំង សួរមិនធ្វើទារុណកម្មទេ ហើយចម្លើយប៉ុណ្ណេះ មិនមានទារុណកម្មទេ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** ជនជាប់ចោទសុំតាំងស្មារតីឲ្យបានរឹងពឹងឡើងវិញ ។

ការធ្វើទារុណកម្មចំពោះជនសាមញ្ញនិងការធ្វើទារុណកម្មចំពោះបុគ្គលដែលមានឋានៈតួនាទីសំខាន់ៗក្នុងជួរបក្ស និងរដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យហ្នឹង តើមានស្ថានភាពខុសគ្នាដែរឬទេ ឬក៏ប្រព្រឹត្តទៅប្រហាក់ប្រហែលគ្នាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ជាទូទៅ គឺប្រហែលគ្នា ក៏ប៉ុន្តែករណីខ្លះ ក៏មានការយោគយល់ដែរ ។ ឧទាហរណ៍ ដូចជាមួយ វ៉ន វេត ។ នេះ មិត្តប៉ុន គេយោគយល់ខ្ញុំ ម្ល៉ោះហើយ គេជ្រើសរើសរកវិធានការមួយធ្វើទារុណកម្ម ដោយយកទឹកកក ទៅមុជឲ្យគាត់ ហើយដាក់ *វ៉ងទីឡាទ័រ* ពីរបីទៅឲ្យគាត់រងារ នេះទារុណកម្មចំពោះ វ៉ន វេត ខ្ញុំដឹង គេបានធ្វើត្រឹមប៉ុណ្ណឹង ។

**ស៖** តាមការស្តាប់របស់យើងៗយល់ថា លោកបានពិតជាបានអាន នូវឯកសារសៀវភៅកំណត់ដៃចំនួនបីក្បាលរបស់អ្នកសួរចម្លើយនៅមន្ទីរស-២១ មានដូចជា បញ្ជីស្ថិតិ នៃមន្ទីរសន្តិបាលស-២១ នយោបាយ មនោគមវិជ្ជា និងអង្គការចាត់តាំង ។ សៀវភៅកំណត់ដៃរបស់ ម៉ម ណៃ ហៅ ចាន់, សៀវភៅកំណត់ដៃរបស់ ប៉ុន និងរបស់ ទុយ ដែលបានកត់ត្រាទុកនូវសេចក្តីណែនាំ ដែលពួកគេបានទទួលពាក់ព័ន្ធនឹងការសួរចម្លើយ និងការធ្វើទារុណកម្មនៅមន្ទីរស-២១ ។

បញ្ជីស្ថិតិមានការណែនាំផ្នែកនយោបាយ និងការសួរចម្លើយ ដែលបង្រៀនដល់អ្នកសួរចម្លើយដោយលោកដូចជា ឲ្យបំបាក់ស្មារតីអ្នកទោស ដោយអប់រំសតិអារម្មណ៍ ឬការធ្វើទារុណកម្ម និងប្រសិនបើអង្គការប្រាប់ថា "កុំឲ្យវាយ កុំវាយដាច់ខាត ប្រសិនបើបក្សបញ្ជាឲ្យយើងវាយ យើងត្រូវវាយដោយម្ចាស់ការ វាយពួកវាឲ្យទាល់តែនិយាយកុំឲ្យរួចខ្លួនដោយសេចក្តីស្លាប់ កុំឲ្យពួកវាអស់កម្លាំងដល់ធ្លាក់ខ្លួនឈឺ ហើយស្លាប់" ។

[១១:១២:២៨]

ការណែនាំ និងមនោគមវិជ្ជាដែលបានសរសេរក្នុងសៀវភៅកំណត់ដៃរបស់ ចាន់ និងបញ្ជីស្ថិតិទាំងអស់ ដែលយើងបានដកស្រង់នេះ តើវាបានឆ្លុះបញ្ចាំងយ៉ាងពិតប្រាកដ អំពីការបង្រៀន និងការណែ

នាំរបស់លោកដែរឬទេ នៅមន្ទីរស-២១នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ពិតជាខ្លឹមសារដែលខ្ញុំបង្រៀនគេមែន ។ បើជាកំណត់ដៃរបស់បង ម៉ម ណៃ គាត់កត់ត្រាបានច្រើនណាស់នូវពាក្យសម្ដីរបស់ខ្ញុំ ។ ឯចំណែក សៀវភៅសង្ខេបរបស់មិត្តយើងម្នាក់ បើតាមខ្ញុំស្មានឈ្មោះពួកមិត្ត ឈ្មោះមិត្ត គឺជារបស់មិត្ត ពូល ផល្លី គេសង្ខេបគំនិតខ្ញុំបានត្រឹមត្រូវ ។ នេះឯកសារទាំងពីរនេះ គឺអ៊ីចឹង ខ្ញុំសូមជម្រាបលោកប្រធាន ។

**ស៖** គោលបំណងនៃការធ្វើទារុណកម្ម នៅមន្ទីរស-២១ គឺដើម្បីទទួលបាននូវចម្លើយពេញលេញមួយដែលរួមមានអំពើរបស់អ្នកទោសត្រូវបានគេចោទ និងកំណត់ឈ្មោះមនុស្សដែលគេអះអាងថា ជាខ្មាំងនៃរបបនោះ ។ ការយល់ឃើញដូច្នេះ ជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ត្រឹមត្រូវហើយ ។

**ស៖** គោលបំណងពិតប្រាកដនៃការសួរចម្លើយឈ្លើយសឹក និងជនស៊ីវិលវៀតណាម តើចង់បានអ្វីទៅ? និងដើម្បីធ្វើអ្វីពិតប្រាកដ?

**ឆ៖** ចាប់តាំងពីថ្ងៃ០៦ មករា ១៩៧៨ មក ការសួរចម្លើយឈ្លើយសឹកវៀតណាម ក៏ដូចជាជនស៊ីវិលវៀតណាម គឺចង់បានតែសំឡេងរបស់គេ យកទៅផ្សាយវិទ្យុ នេះជាទិសដៅធំបំផុតនៃការសួរចម្លើយ ។

**ស៖** នៅក្នុងអំឡុងពេលនៃការសួរចម្លើយជនជាប់ឃុំឃាំងនៅ ដោយអ្នកសួរចម្លើយនៅមន្ទីរស-២១ តើលោកខ្លួនឯងផ្ទាល់ហ្នឹង ដែលបានធ្វើ ចូលធ្វើអន្តរាគមន៍ ឬក៏បានប្រើហិង្សា ឬក៏ទារុណកម្មទៅលើអ្នកដែលត្រូវគេ កំពុងតែសួរចម្លើយនោះដែរឬទេ?

[១១:១៥:២៣]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំមិនទាំងដែលចូលកន្លែងសួរចម្លើយផង ដូច្នេះខ្ញុំមិនដែលបានអន្តរាគមន៍អីជាអំពើហិង្សាទេ ។ ដោយឡែកតែ ករណី ឈិត អ៊ីវ មួយប៉ុណ្ណោះ ដែលមាន ណាត ខ្ញុំចង់ស្រោចស្រង់មុខមាត់របស់គាត់តែប៉ុណ្ណឹង បានជាខ្ញុំទៅទះកំផ្លៀង ឈិត អ៊ីវ ។

**ស៖** មានសាក្សីមួយចំនួន ព្រមទាំងគាំទ្រដោយឯកសារមួយចំនួនផង បានបង្ហាញឲ្យឃើញថាលោកធ្លាប់បានប្រព្រឹត្តនូវអំពើប្រើហឹង្សាមួយចំនួន បានទាត់អ្នកទោសម្នាក់ បានវាយបុរសម្នាក់នឹងរំពាត់ផ្ដៅ ហើយបានវាយអ្នកទោសម្នាក់នឹងដៃ និងបានវាយអ្នកទោសម្នាក់ទៀតនៅមុខមន្ទីរស-២១ ។ តើរឿងនេះជាការពិតទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មិនពិតទេ ។

**ស៖** មានអង្គហេតុមួយ រឿងហេតុមួយបានកើតឡើង គួរឲ្យកត់សម្គាល់នៅមន្ទីរស-២១ គឺមានអ្នកសួរចម្លើយចំនួនប្រាំ ឬ ប្រាំមួយនាក់ បានធ្វើទារុណកម្មលើស្ត្រីម្នាក់ ចាប់ពីម៉ោងប្រាំបួន រហូតដល់ម៉ោងបីជិតភ្លឺ ហើយបានបន្តធ្វើទារុណកម្មនារីនោះរហូតដល់នាងសន្លប់ ដោយបានឆក់ខ្សែភ្លើង បានដោះសម្លៀកបំពាក់នារីនោះចេញ ទុកតែឲ្យនាងស្លៀកតែខោទ្រនាប់តែប៉ុណ្ណោះ ហើយនិងបានវាយធ្វើបាបនារីនោះរហូតដល់អស់កម្លាំង ។ នៅក្នុងនោះគឺមានការបង្ហាញថា លោកបានចូលរួមនៅក្នុងក្រុមនៃការធ្វើទារុណកម្មលើនារីនោះដែរ តើរឿងហេតុនេះជាការពិតទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មិនពិតទេរឿងនេះ ។

**ស៖** មិនពិត រឿងលោកមិនបានចូលរួមនៅក្នុងការដែលធ្វើទារុណកម្មទៅលើស្ត្រីម្នាក់នោះ ឬក៏រឿងហ្នឹង គឺគ្មានកើតឡើងទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងនេះខ្ញុំមិនជឿថាវាកើតឡើងសោះ ប្រមូលផ្តុំគ្នាប្រមាណប្រាំ-ប្រាមួយនាក់ទៅសួរចម្លើយស្រីម្នាក់ ។ ហើយសារសំខាន់របស់ស្រីនេះ ខាងនយោបាយ ខាងសម្ងាត់ ខាងខ្សែចារកម្ម ខ្ញុំមើលទៅមិនធំដុំ អ្ហឺ! ដូចជាអត់សោះ មិនដឹងទេ មិនដឹងជាសំដៅអ្នកណាមួយផង ។ ក៏ប៉ុន្តែ ភាគច្រើនស្រីដែលចូលទៅមន្ទីរស-២១ គ្មានសារសំខាន់អី ខាងខ្សែសម្ងាត់ទេ នាំឲ្យខ្ញុំអំពល់រវល់ទៅក្នុងនុំងទេ ។ នេះសូមជម្រាបលោកប្រធានអ៊ីចឹង ។

[១១:១៨:៥០]

**ស៖** មានថ្ងៃមួយនោះ នៅក្នុងបន្ទប់ជាងគំនូរ លោកបានបញ្ជា ប៊ូ ម៉េង ឲ្យវាយគ្នាជាមួយនឹងជាងម្នាក់ទៀតឈ្មោះ អៀម ចាន់ ដោយឲ្យវាយគ្នាទៅវិញ ទៅមកនឹងទុយោកៅស៊ូ ។ តើលោកនៅចងចាំទេ អំពីរឿងហេតុនោះ? ហើយលោកអាចនិយាយប្រាប់អង្គសវនាការបានយ៉ាងម៉េចខ្លះទៅ?

**ឆ៖** រឿងនេះ ខ្ញុំជម្រាបដោយត្រង់ វាភ្លេចទៅហើយ ដល់ ប៊ូ ម៉េង គេនិយាយអ៊ីចឹងមក ខ្ញុំនឹកឃើញ ខ្ញុំបានឲ្យគេវាយគ្នាមែន ។ ហើយមូលហេតុដែលឲ្យវាយគ្នា ខ្ញុំភ្លេចហើយ មិនដឹងជារឿងស្អីទេ ឬមួយខ្ញុំចង់ប្រឡែងលេង ឲ្យគេវាយគ្នាលេងទៅក៏មិនដឹង យ៉ាងម៉េចក៏មិនដឹង ។ នេះពិតជាបានបញ្ជាឲ្យគេវាយគ្នាមែន ។

**ស៖** ក្នុងឋានៈលោកជាប្រធានមន្ទីរស-២១ តើលោកបញ្ជាទៅអ្នកក្រោមបង្គាប់ របស់លោកឲ្យធ្វើទារុណកម្មអ្នកទោសតាមមធ្យោបាយយ៉ាងម៉េចដែរ?

[១១:២០:១៦]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! វិធីធ្វើទារុណកម្ម ខ្ញុំបានជម្រាបហើយ មានបួនបែប ។ ទីមួយហៅថាលក្ខណៈជាទូទៅ គឺវ៉ៃ ។ ខ្ញុំមិនបានកំណត់ថាឲ្យវ៉ៃនឹងស្អី មិនឲ្យ--

**សៈ** យើងអត់ចង់ដឹងអ៊ីចឹងទេ ។ ចង់ដឹងថា និយាយរួមគឺលោកមានដែលចេញបញ្ជាផ្ទាល់ខ្លួនទៅអ្នកក្រោមឱវាទដើម្បីឲ្យអ្នកសួរចម្លើយទាំងអស់ហ្នឹងធ្វើទារុណកម្មជាក់លាក់ទៅលើបុគ្គលដែលត្រូវសួរចម្លើយដែរឬទេ? ហើយបើមាន តើការបញ្ជារបស់លោកហ្នឹង ធ្វើតាមវិធីណា? ឧទាហរណ៍ទៅផ្ទាល់ ឬក៏ទូរស័ព្ទ ឬក៏ប្រើមនុស្សទៅប្រាប់? ពីព្រោះមានហេតុផលជាច្រើនដែលបញ្ជាក់ថា មនុស្សមួយចំនួនត្រូវធ្វើទារុណកម្ម ។ អាចធ្វើទារុណកម្មដោយបុគ្គលិកអ្នកដែលប្រតិបត្តិការផ្ទាល់ ដោយមានការបញ្ជាពីរូបលោក ឬក៏មានបានបញ្ជាពីលើមកទៀត តម្រូវឲ្យធ្វើទារុណកម្មដើម្បីយកព័ត៌មាន យកចម្លើយជាក់លាក់ណាមួយក្នុងករណីសមស្របដើម្បីបានចម្លើយហ្នឹងសមតាមបំណងនៃអ្នកចង់សួរ ឬក៏អ្នកចង់បាននូវលទ្ធផលស្ដីពីការចម្លើយសារភាពនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ឯកសារដែលនៅសល់មានច្រើនស្ដីអំពីបញ្ហានេះ ។ បញ្ហានេះមានអន្តរាគមន៍មេខ្ញុំពីលើមក មាន ។ បើតាមខ្ញុំចាំយ៉ាងតិចណាស់ករណីពីរនាក់ដែរ គឺពេលសួរចម្លើយ ម៉ែន សាន ហៅ យ៉ា ហើយនិងសួរចម្លើយ សៀត ឆែ ហៅ ទុំ ។ ខ្ញុំសរសេរសំបុត្រវែង ខ្ពីទៅកំញើញ ទៅពន្យល់ របៀបកៀប ។ នេះដោយមានការត្រូវវ៉ូវគ្នា នេះយើងថាត្រូវវ៉ូវគ្នាទៅចុះ ដោយមានការលើកជាមតិណែនាំពីខាងលើមក ។ នេះមានពិត ។ យ៉ាងតិចក៏ពីរនាក់ហ្នឹងដែរ ហើយខ្ញុំមិននិយាយអ្នកផ្សេងទៀតទេ ។

ឯចំណែក អ្នកផ្សេងទៀតខ្ញុំចារមួយម៉ាត់មួយក តាមខ្ញុំចាំមានចំណារមួយថា វ៉ៃនាង ដាញ់ ស៊ីយ៉េន នេះឲ្យឆ្លើយឲ្យត្រង់ ។ កុំឆ្លើយថាខ្លួនទៅវៀតណាមដើម្បីទៅមើលជំងឺរាំងខែថ្ងៃ (សូមទោស) នេះមានលំនាំរបៀបហ្នឹង ខ្ញុំមិនច្បាស់ទេ ។ រួចជូនអីអ្នកខ្លះខ្ញុំថា មិនទាន់ឆ្លើយ ទារុណកម្មមធ្យមមាន ។

ដូច្នេះ គឺមានចារ ទីមួយមានជាសំបុត្រហូរហែវែងចំពោះកម្មាភិបាលសំខាន់ពីរនាក់ ។ ទីពីរគឺមានចារនូវជាសេចក្ដីណែនាំទៅលើឯកសារជាច្រើន ។ ទារុណកម្មមធ្យម ទារុណយ៉ាងម៉េច? មាន ក៏ប៉ុន្តែបើនិយាយថាខ្ញុំណែនាំគេតាមទូរស័ព្ទពីរឿងវ៉ៃអត់មានទេ ។ ទូរស័ព្ទខ្ញុំនៅក្នុងស-២១ នេះអត់ទាក់ទងជាមួយនឹងអ្នកណាទេ ទាក់ទងតែជាមួយនឹងមិត្តហ៊ី ហៅគាត់មកជួបដើម្បីពិគ្រោះគ្នា ។ នេះប្រើជាសំខាន់អ៊ីចឹង ។ រួចក្រោយពីនុ៎ងបុគ្គលិកទាំងអស់របស់ស-២១ គ្មានអ្នកណាប៊ានផ្ដើមគំនិតហៅទូរស័ព្ទ

មកខ្ញុំទេ សូម្បី មិត្តហ៊ ក៏ដោយមានការអីជាមួយនឹងខ្ញុំ គាត់មកជួបខ្ញុំ ។ បង ម៉ម ណៃ ក៏ដោយ មិត្តប៉ុន ក៏ដោយមានការអីគាត់មកហៅមកជួបខ្ញុំ ។

សរុបមកការណែនាំតាមទូរស័ព្ទគ្មានទេ ការមកសូមសេចក្ដីសម្រេចចិត្តរបស់ខ្ញុំ ពេលធ្វើទារុណកម្មតាមទូរស័ព្ទក៏គ្មានដែរ ។ មានតែខ្ញុំចារនៅលើក្រដាសបង្គាប់បញ្ជាគេ ហ្នឹងមាន ឯកសារនៅសល់ជាភស្តុតាងស្រាប់ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១១:២៤:៣០]

**ស៖** លោកតែងតែនិយាយជាញឹកញាប់ដល់មនុស្សម្នាក់គឺឈ្មោះ ទុយ គឺជាបុគ្គលិកនៃផ្នែកខាងសួរចម្លើយ ។ ហើយលោកបានលើកឡើងថាមនុស្សម្នាក់នេះចូលចិត្តធ្វើទារុណកម្មណាស់ ។ ហើយក្នុងករណីដែលការសួរចម្លើយបែបវិធីត្រជាក់មិនបានផលទេនោះ គឺអាចតម្រូវប្រគល់ឲ្យទៅមិត្តទុយ ដើម្បីសួរចម្លើយ ។

ការសម្រេចរបៀបនេះ តើលោកជាអ្នកសម្រេចដោយឡែកទៅតាមករណីនីមួយៗ ឬក៏ការសម្រេចហ្នឹងមានលក្ខណៈទូទៅ? ថាប្រសិនបើករណីណាដែលមានការរឹងរូសមិនព្រមឆ្លើយសារភាពដែលប្រើវិធីត្រជាក់មិនបានសម្រេចគឺវិធីចុងក្រោយដែលប្រើវិធីក្ដៅនោះ គឺត្រូវរុញឲ្យទៅឈ្មោះទុយជាអ្នកសួរ ដូច្នេះ ។ តើមានករណីនេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! អ្នកដែលរុញមនុស្សដែលពិបាកសួរ សួរមិនចេញទៅឲ្យទុយ មានសិទ្ធិសម្រេចតែពីរនាក់ទេគឺខ្ញុំហើយនិងមិត្តហ៊ ។ មិត្តហ៊ សម្រេចតិចជាងខ្ញុំ ខ្ញុំសម្រេចច្រើនជាងគេ ។ នេះមែន សូមបញ្ជាក់ ។

**ស៖** លោកប្រគល់ទៅឲ្យ មិត្តទុយ ដើម្បីអនុវត្តក្នុងការសួរចម្លើយតាមវិធីក្ដៅ គឺធ្វើទារុណកម្មក្នុងការសួរចម្លើយនេះ ។ តាមវិធីណាទៅ? ព្រោះលោកបាននិយាយមិញថា កាលដែលលោកមិនដែលទៅផ្ទាល់ដល់កន្លែងនៃការសួរចម្លើយទេ ទីមួយ ។ ទីពីរការទាក់ទងជាមួយនឹងទូរស័ព្ទគឺគ្មានទេ ពីព្រោះទាក់ទងតាមទូរស័ព្ទគឺមានតែលោកជាមួយនឹងអនុប្រធានរបស់លោកតែប៉ុណ្ណោះ ។

ហើយករណីអម្បាញ់មិញនេះ គឺហាក់ដូចជាខុសគ្នា ពីព្រោះថា ការដែលបង្គាប់បញ្ជាឲ្យធ្វើទារុណកម្មឬក៏អនុវត្តនូវវិធីសាស្ត្រនៃការសួរក្ដៅនេះ តាមវិធីសាស្ត្រក្ដៅនេះគឺប្រគល់ឲ្យទុយ គឺមានតែលោកទេ ភាគច្រើនជាអ្នកសម្រេច ដូច្នេះ ។ តើលោកសម្រេចបង្គាប់ទៅ ទុយ នុ៎ងតាមរបៀបណា? តាមវិធីណាទៅ?

[១១:២៦:៥៦]

**ឆ៖** ធាតុពិតរបស់ទុយគឺមនុស្ស មានសរសៃញាក់មួយទៅខាងធ្វើទារុណកម្ម ។ ខ្ញុំសូមនិយាយឲ្យអស់ទៅចុះ មនុស្សនោះប្រហែលជាស្លាប់ទាំងពីរនាក់ទៅហើយ ។ គឺមិត្តប៉ុន ហើយនិង មិត្តទុយ ។ មិត្តប៉ុន ច្បាស់ជាស្លាប់ហើយ មិត្តទុយ ក៏សង្ស័យថាស្លាប់ដែរ ។ មិត្តទុយ នេះគាត់ឃើញមិត្តប៉ុនសួរចម្លើយជាទីគាប់ចិត្តរបស់ខ្ញុំ គាត់ក៏ចង់ប្រណាំងប្រជែងដែរ ម្លោះហើយគាត់ខំ ។ ដោយសារធាតុពិតគាត់មិនធ្លាប់មានពិសោធន៍ គាត់យកទារុណកម្មធ្វើជាគោល ។

ដូច្នេះ ខ្ញុំហើយនិង មិត្តហ៊ ឯកភាពគ្នាឃើញបញ្ហានេះ ។ ចង់ប្តូរមនុស្ស ខ្ញុំមិនទៅខ្លួនឯងទេ ប្រគល់អ្នកណាទៅឲ្យមិត្តទុយ សួរ ខ្ញុំប្រាប់មិត្តហ៊ គាត់ចាត់ចែងហើយ ។ ដូច្នេះ អំណាចពិតប្រាកដគឺវានៅលើខ្ញុំមែន ក៏ប៉ុន្តែ អ្នករត់ការអនុវត្តសេចក្តីសម្រេចចិត្តរបស់ខ្ញុំ ភាគីច្រើនគឺ មិត្តហ៊ ហ្នឹងឯងដែរ ។ នេះសូមជម្រាបលោកប្រធាន ។

**ស៖** ប៉ុន្តែខ្ញុំចង់ដឹងថាបញ្ជា លោកបញ្ជាទៅឲ្យថាឥឡូវត្រូវប្រគល់ទៅឲ្យ ទុយ ហើយនិងប្រើវិធីក្តៅហ្នឹង ។ យើងបញ្ជាយ៉ាងម៉េចទៅ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! យើងប្រគល់មនុស្សទៅឲ្យគេ យើងទុកឲ្យគេចាត់ចែងដោយម្ចាស់ការហើយ ។ គេក្តៅហើយ ក៏ប៉ុន្តែ ភាគច្រើនមិនងាយស្លាប់របស់គាត់ដែរ មិនងាយស្លាប់ដាច់ចម្លើយរបស់គាត់ដែរ ។ ដូច្នេះ យើងប្រគល់ឲ្យគេ ហើយគេចាត់ចែងតាមតម្រិះរបស់គេហើយ ។ នេះគឺសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** បានន័យថា អ្នកទាំងនោះគឺមកជួបលោកផ្ទាល់ ហើយលោកសម្រេចតែម្តង? បង្គាប់ដូច្នេះតែម្តង? ឬក៏លោកបង្គាប់បញ្ជាទៅតាមមិត្ត អនុប្រធានរបស់លោក?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ក្នុងការប្រគល់មនុស្សទៅឲ្យថែមទៀតនេះ គឺខ្ញុំធ្វើទៅតាមមិត្តហ៊ នៅពេលណាដែលឃើញចម្លើយអ្នកផ្សេងទៀតយកមិនបាន ។ ដូច្នេះ ខ្ញុំពិគ្រោះចុះឡើង អ្ហ៊ី! អ៊ីចឹងឲ្យទៅ មិត្តទុយ ទំនេរល្ហម ទទួលម្នាក់នេះទៀតបានទេ? បើគេមានអីបង, បាន ។ ហើយយើងខ្ញុំក៏ប្រគល់អ្នកទោសនុ៎ងទៅឲ្យ មិត្តទុយ ទៅ ។ ដូច្នេះ សុទ្ធតែពិគ្រោះគ្នាហើយឲ្យខាងមិត្តហ៊ គេចាត់ចែង។

[១១:៣០:០០]

**ស៖** តាមឯកសារនៅថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៧៦ លោកបានសរសេរទៅអ្នកសួរចម្លើយឈ្មោះប៉ុន ឲ្យធ្វើទារុណកម្ម ដោយបានសរសេរថាប្រសិនណាការធ្វើទារុណកម្មនេះបណ្តាលឲ្យអ្នកទោសស្លាប់

នោះ ប៉ុន ក៏នឹងមិនត្រូវបានគេផ្តន្ទាទោស ឬក៏ចាប់កំហុសនោះទេ ។ តើមានរឿងហេតុហ្នឹងអ៊ីចឹងទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងនេះវាជារឿងចាស់ ក៏ប៉ុន្តែ ខ្ញុំនឹកឃើញរឿងទាំងអស់ឡើងវិញនៅរយៈកាលស៊ើបអង្កេត ។ សំបុត្រនេះខ្ញុំសរសេរទៅឲ្យ ប៉ុន ជារបៀបកំញើញអ្នកឆ្លើយហ្នឹង គឺបង ម៉ែន សាន ហៅ យ៉ា ហ្នឹងឯង ។ តាមពិតជាឧបាយកលដែលខ្ញុំហើយនិងមេខ្ញុំឯកភាពគ្នាទេសរសេរខ្លឹមសារនេះ ។

ឥឡូវ មិត្តវ៉ៃដាក់ទៅ បើទោះជាស្លាប់ក៏ខ្ញុំមិនយកទោសមិត្តដែរ ដូច្នេះ ឲ្យបង ម៉ែន សាន ហៅ យ៉ា គាត់តក់ស្លុតបន្តិច ។ នេះជាយុទ្ធវិធីដែលយើងខ្ញុំជាមួយនឹងមេប្រើយុទ្ធវិធីមួយហ្នឹង ។ នេះជាសំបុត្រខ្ញុំមួយយ៉ាងវែងគួរសមដែរ សរសេរទៅ ។ ហើយសូមជម្រាបបញ្ចាក់ប៉ុណ្ណេះ ។

**ស៖** ពីព្រឹកមិញលោកបានឆ្លើយប្រាប់ដល់អង្គសវនាការទាំងមូលហើយថា លោកបានពិតជាបានបង្រៀនអំពីបច្ចេកទេសនៅក្នុងការសួរចម្លើយដល់អ្នកសួរចម្លើយស-២១មែន ដែលលោកបានឆ្លើយដំបូងថាមួយខែ ។ ហើយក្រោមកលោកបានកែថា ប្រហែលជាបីសប្តាហ៍ ហើយការបង្រៀននោះក្នុងមួយថ្ងៃគឺចំណាយរយៈពីរម៉ោង ។ សំណួរសួរថា នៅក្នុងអំឡុងពេលនៃការបង្រៀន ឬក៏ណែនាំអ្នកសួរចម្លើយអំពីរបៀបនៃការសួរចម្លើយនោះ តើលោកមានបានធ្វើការបង្រៀនឬក៏ណែនាំអំពីរបៀបធ្វើទារុណកម្មដែរឬទេ ដល់អ្នកសួរចម្លើយទាំងអស់នោះ?

**ឆ៖** របៀបនៃការធ្វើទារុណកម្ម មិនបានបង្រៀនទេ ។ ក៏ប៉ុន្តែ និយាយអំពីសារសំខាន់នៃទារុណកម្មច្បាស់លាស់ឲ្យគេ ដោយកត់សម្គាល់ថាទារុណកម្មវាជំនួយប៉ុននុ៎ងទេ សំខាន់គឺយើងនិយាយ គឺយើងសួរ គឺយើងត្រិះរិះគិត ។ ចំណែក របៀបធ្វើទារុណកម្ម វាឯកភាពគ្នារវាខ្ញុំនិង ណាត ។ កំណត់យកប្អូនរូបភាពហ្នឹង ណាត គាត់ចូលចិត្តណាស់អានឆក់ខ្សែភ្លើងនេះ អាហ្នឹងជារឿងរបស់គាត់ ។ ឯចំណែកច្រកស្បោងប្លាស្ទិកខ្ញុំរំឭកឡើងប្រាប់ណាត អំពី វ៉ន វេត គាត់ណែនាំវិធីហ្នឹង ។ ឯចំណែកទារុណកម្មជាទូទៅទាំងពីរនាក់ ខ្ញុំហើយនិងណាតយល់ឃើញថាឯកភាពដូចគ្នាហ្នឹង គឺវ៉ៃ ។ ដោយឡែក អាច្រកទឹកនេះជាយុទ្ធវិធីដែលនគរបាលរដ្ឋអំណាចចាស់ គឺរដ្ឋអំណាចព្រះនរោត្តម សីហនុ និង លន់ នល់ នេះគេប្រើច្រកទឹកពួកខ្មែរក្រហម ។ នេះដឹងឮទាំងអស់គ្នាទាំងពីរនាក់ ខ្ញុំហើយនិង ណាត ។ ទាំងអស់ក៏ដឹងឮក៏ប៉ុន្តែ ចេញបញ្ជាជាលាយលក្ខណ៍អក្សរអត់មានទេ ។ នេះសូមជម្រាបបញ្ជាក់ប៉ុណ្ណឹង ។

[១១:៣៥:៥០]

**ស៖** នៅក្នុងការដែលលោកបង្រៀនឬក៏ការណែនាំ អំពីរបៀបធ្វើទារុណកម្មដល់អ្នកដែលត្រូវសួរ

ចម្លើយនោះ ។ តើលោកបានបញ្ជាក់ ឬក៏រំឭក ឬក៏ប្រាប់ដល់អ្នកសួរចម្លើយដែរទេថា សូមកុំឲ្យពួកគេហ្នឹងគឺក្នុងអំឡុងពេលនៃការសួរចម្លើយហ្នឹង គឺធ្វើទារុណកម្មរហូតដល់អ្នកទោសស្លាប់នោះ ។ តើមានការរំឭក ឬក៏ការហាមប្រាមករណីនេះដែរទេ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេៗបញ្ហានេះ ។ ក៏ប៉ុន្តែ ដូចជាមាននិយាយដែរៗ ហើយក្នុងការអនុវត្តជាក់ស្តែង នៅពេលដែលគេធ្វើទារុណកម្មជ្រុលដែររហូតដល់ស្លាប់ក៏មានដែរ តែខ្ញុំក៏ខំពុះពាររាយការណ៍ទៅមេដើម្បីឲ្យគាត់យល់ ហើយកុំឲ្យវាមានទោសដល់គ្នាហ្នឹងពេក ។ បើសិនជាយើងមើលទៅ គេមិនមានបំណងវាយឲ្យដាច់ចម្លើយ ។ ឧទាហរណ៍ ដូចជាមិត្តម្នាក់សួរចម្លើយឈ្មោះ ពង គីមសៀ, ពីង គីមស្វ ពីង គីមសៀ ភ្លេចហើយ ខ្ញុំមានសរសេរទៅមេរាយការណ៍ពីបញ្ហានេះ ។

សរុបមក ឲ្យខ្ញុំណែនាំម្តងហើយម្តងទៀតៗ ខ្ញុំមិនហ៊ានអះអាងទេ ។ ក៏ប៉ុន្តែ ប្រហែលជាអាចមាន ។ ក៏ប៉ុន្តែ បើកាលណាមានគ្រោះថ្នាក់ខ្ញុំក៏អាចដោះស្រាយសម្រួលដល់គ្នាអ្នកអនុវត្តដែរ ។ នេះគឺសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** មិញយើងបានសួរសំណួរមួយពាក់ព័ន្ធជាមួយនឹងការបញ្ជាដោយមានលក្ខណៈជាទូទៅនៅក្នុងហ្នឹងគឺជាការបញ្ជារបស់លោកផ្ទាល់ទៅលើអ្នកដែលក្រុមសួរចម្លើយនៅក្រោមឱវាទរបស់លោកដោយមានភ្ជាប់បញ្ហាមួយចំនួន គឺអំពីបញ្ជារបស់ថ្នាក់លើផង ។ ឥឡូវនេះ យើងកាត់ដោយឡែកអំពីថាតើលោកធ្លាប់ដែលបានទទួលបញ្ជាពីថ្នាក់លើដូចជា ណាត ឬក៏ក្រោយមកគឺពេលដែលលោកធ្វើប្រធានគឺ សុន សេន ផងដែរ សូមឲ្យធ្វើទារុណកម្មទៅលើអ្នកទោសណាមួយជាក់លាក់ហើយ តើមានករណីដូច្នេះដែរឬទេ? ករណីស្នើសុំឲ្យមានការធ្វើទារុណកម្មជាក់លាក់ទៅលើអ្នកទោស ដូចជាអ្នកជាប់ឃុំឃាំងនៅក្នុងមន្ទីរស-២១ ដោយថ្នាក់លើរបស់លោកគឺមាន សុន សេន ឬក៏ ណាត ក្នុងអំឡុងពេលដែលណាត ធ្វើប្រធាននោះ?

**ឆ៖** នៅពេលដែល ណាត ធ្វើប្រធាន ខ្ញុំចាំមិនច្បាស់ទេៗ ។ បើមានគឺមានពីគាត់ទៅកម្មាភិបាលសួរចម្លើយ ឯចំណែកខ្ញុំ ខ្ញុំពិនិត្យចម្លើយហើយ ពេលខ្ញុំមិនត្រូវចិត្ត ខ្ញុំត្រឡប់ទៅឲ្យពួកៗការិយាល័យរបស់គាត់ ពួកលេខាធិការដ្ឋានរបស់គាត់គេសួរឲ្យខ្ញុំ អាហ្នឹងមានមែន ។ អានេះតាមឯកសារនៅសល់ឃើញថ្មីៗ ។ ដូច្នេះ រឿងណាតសុំខ្ញុំឲ្យធ្វើអ្នកនេះធ្វើអ្នកនោះអត់មានទេ ព្រោះខ្ញុំអត់ជាប់នឹងការងារសួរចម្លើយដោយផ្ទាល់ គេៗជាប់ដោយផ្ទាល់នោះទៅវិញទេ ។ កាលមុនជាមួយលោកគ្រូ សុន សេន មេខ្ញុំ

ករណីពីរបីហ្នឹង គាត់ជាប់ខ្លាំងណាស់ តាមដានខ្ញុំជាប់ការងារ នេះមានបញ្ហាពីលើមកមែន ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១១:៣៨:៣៣]

**ស៖** ហើយលោកអនុវត្តបទបញ្ជាដោយសារការបញ្ជាផ្ទាល់ បញ្ជាបន្តទៅអ្នកក្រោមឱវាទ អ្នកសួរចម្លើយជាអ្នកអនុវត្តបទបញ្ជានោះ ឬក៏លោកអនុវត្តដោយខ្លួនឯង?

**ឆ៖** នៅពេលដែលខ្ញុំសួរចម្លើយ កុយ ធួន ដំបូង អាហ្នឹងគឺខ្ញុំវាយការណ៍ភ្លាមៗ ថាខ្ញុំធ្វើអ៊ីចេះបង ខ្ញុំធ្វើអ៊ីចេះ គាត់ណែនាំមកកែៗភ្លាម ។ អាហ្នឹងនៅពេលខ្ញុំសួរ ផុតពីដៃខ្ញុំសួរខ្ញុំប្រគល់ទៅឲ្យមិត្តប៉ុន គាត់ណែនាំមកខ្ញុំធ្វើតាមនុ៎ង ។ ដោយឡែក មានតែករណីមួយទេបើតាមខ្ញុំចាំ គឺគាត់ចង់ប្រើវិធីមួយសរសេរសំបុត្រមកណែនាំ សៀត ឆែ ហៅ ទុំ ឲ្យសារភាពទៅ អង្គការនឹងគិតគូរ ។ ដល់និយាយអ៊ីចេះគាត់ថាហ្អេ! សរសេរម៉េច ហៅអាទុំ ឬហៅមិត្តទុំ ឌុច? ខ្ញុំថាមិនដឹងទេបង ខ្ញុំមិនប៉ាននមតិជាមួយបងទេ ។ ដល់ទៅគាត់ក៏សរសេរសំបុត្រទៅ ទុំ នោះមិនកើតដោយផ្ទាល់ខ្លួន គាត់សរសេរសំបុត្រវាងមកខ្ញុំ ។ គាត់ថាជូន មិត្តឌុច ឲ្យទុំសារភាពឲ្យស្រួលបួលទៅអង្គការនឹងគិតគូរ ហើយខ្ញុំក៏ឲ្យសំបុត្រទៅឲ្យមិត្តប៉ុន យកទៅបង្ហាញ ថាន៎ែ! ឥឡូវសំបុត្របងខៀវមក បងឌុច អ៊ីចេះ ។ ដូច្នេះ គឺវាមានដំណាក់គន្លាក់គន្លឹនអ៊ីចឹង ក្នុងរឿងសួរចម្លើយ សៀត ឆែ ហៅ ទុំ មានសំបុត្រ បងខៀវ មកមួយសំបុត្រហ្នឹងបើតាមខ្ញុំចាំមានតែមួយសំបុត្រនោះទេ ក្រៅពីនោះគឺខ្ញុំចេញមុខតំណាងឲ្យគាត់ ។ សំបុត្រ យ៉ា សំបុត្រអី គឺខ្ញុំចេញមុខ តំណាងឲ្យគាត់ក្នុងនាមខ្ញុំ ក៏ប៉ុន្តែមតិគឺគាត់ នេះវាមានមែន ។ សូមជម្រាបអ៊ីចឹង ។

**ស៖** ចុះការសួរចម្លើយពួកជនជាតិបរទេស យើងមិននិយាយអំពីជនជាតិវៀតណាមទេ យើងនិយាយពីជនជាតិបរទេសផ្សេងទៀត ។ ឧទាហរណ៍ ដូចជាពួកបស្ចិមប្រទេស ។ តើអ្នកសួរចម្លើយហ្នឹងប្រព្រឹត្តទៅយ៉ាងម៉េចដែរ ព្រោះមានរបាំងភាសាមួយ តើកិច្ចការនេះមានការអ្នកចាត់ចែងយ៉ាងម៉េចដែរ ក្នុងការសួរចម្លើយជនបរទេសដូចនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ការសួរចម្លើយនេះមានមានពីរលើក ។ លើកដំបូង ខ្ញុំមិនដឹងជាអ្នកបកប្រែដដែល ឬក៏អ្នកបកប្រែមុនផ្សេង ។ ក៏ប៉ុន្តែ អ្នកបកប្រែដែលខ្ញុំបានទៅមើលនៅពេលគេសួរចម្លើយជនអង់គ្លេសនោះ គាត់ឈ្មោះ ឆន មានត្រកូលស្អីទេ ភ្លេចអស់ហើយ ។ យកមកឲ្យធ្វើជាអ្នកបកប្រែឲ្យ មិត្តប៉ុន។ មិត្តប៉ុន អត់ចេះនិយាយអង់គ្លេសមិនកើតទេ ខ្ញុំអត់និយាយអង់គ្លេសមិនកើតដែរគ្មានអ្នកណានិយាយអង់គ្លេសកើតទេ ។ ទាល់តែ មិត្តហ៊ី គាត់ទៅរកពីកន្លែងក្នុងពន្ធនាគារមក ឃើញ

ឈ្មោះ ខិន វណ្ណធន យកមកធ្វើអ្នកបកប្រែ ដូច្នេះសួរចម្លើយជនបរទេសដែលប្រើភាសាអង់គ្លេសយើងខ្ញុំយក ខិន វណ្ណធន យកមកប្រើ សួរចម្លើយវៀតណាមយើងខ្ញុំ ផា ថាចាន់ យកមកប្រើ ។ នេះសូមបញ្ជាក់តែប៉ុណ្ណេះ ។

**ស៖** ចុះជនជាតិបរទេសផ្សេងទៀត បើតាមបញ្ជីឈ្មោះជនជាតិបរទេសដែលមានចំនួនជាងចិតសិបនាក់ ចិតសិបប្រាំបីនាក់ដែលបានបង្ហាញដោយលោកស្រីចៅក្រម ខាតរ៉ាយថ៍ កាលពីសប្តាហ៍មុន គឺនៅក្នុងនោះគឺមានមួយចំនួនផ្សេងទៀតនោះគឺមានទាំងជនជាតិ ថៃ ឡាវ ហើយមានអ្នកកាសែតជប៉ុនផងដែរ ។

ឧទាហរណ៍ ថៃ ឡាវហ្នឹង តើមានអ្នកបកប្រែចេះភាសាថៃ ឬក៏ភាសាឡាវ នៅពន្ធនាគារទេ? ហើយបើអត់មានទេ យើងធ្វើការសួរចម្លើយគាត់ហ្នឹងយ៉ាងដូចម្តេចទៅ?

[១១:៤២:៥៧]

**ឆ៖** ជនជាតិថៃៗ បើតាមខ្ញុំចាំ ខ្ញុំឃើញតែបញ្ជីទេ ។ ឃើញតែបញ្ជីសុទ្ធ ដូច្នេះ មនុស្សនុំងនៅឯណា? ហើយអ្នកណាសួរចម្លើយខ្ញុំអត់ដឹងទេ ។ ខ្ញុំសន្និដ្ឋានដំបូងថាប្រហែលជាបញ្ជីនេះខាង១៦៤ គេរាយការណ៍មកឲ្យសេនាធិការ ក៏ប៉ុន្តែទោះយ៉ាងណាក៏ដោយ ខ្ញុំគ្រាន់តែប៊ានបញ្ជាក់ថាជនជាតិថៃខ្ញុំអត់បានឃើញអ្នកណាសួរចម្លើយទេ ហើយអត់បានជ្រើសរើសអ្នកណាយកទៅឲ្យនោះទេ ។ ដូច្នេះ វាស្ថិតនៅក្នុងរយៈកាលដែល ណាត គាត់ធ្វើប្រធាន ។ សរុបមក រឿងជនជាតិថៃជនជាតិអីនោះ ខ្ញុំអត់ដឹងទេ ហើយឯចំណែកអ្នកធ្វើការឲ្យកាសែតជប៉ុននេះ ក៏ខ្ញុំក្តាប់មិនបានដែរ ។ នេះសូមជម្រាបបញ្ជាក់ជូនលោកប្រធាន ។

**ស៖** អរគុណ ។ គោលបំណងនៃការសួរចម្លើយជាទូទៅពិតប្រាកដគឺដើម្បីអ្វីទៅ? លោកអាចនិយាយប្រាប់ដល់អង្គសវនាការបានដែរទេ អំពីបញ្ហានេះ?

**ឆ៖** សួរចម្លើយ ។ ជម្រាបប្រសាសន៍លោកប្រធាន! ការសួរចម្លើយនៅក្នុងមន្ទីរស-២១ ជាទិសដៅយុត្តិសាស្ត្រគឺចង់ឲ្យសាមីខ្លួននិយាយអំពីសកម្មភាពក្បត់របស់ខ្លួន នេះជាបញ្ហាគ្រឹះ ។ ក៏ប៉ុន្តែ បច្ច័យដែលគេយកទៅប្រើយ៉ាងម៉េច? ខាងលើគេយកចម្លើយនុំងទៅពិនិត្យមើលថា តើវាសមមិនសមហើយអ្នកណាដែលជាប់នឹងចម្លើយនោះខ្លះ គេស្រាវតាមនុំងទៅរកចាប់អ្នកផ្សេងទៀត ។ នេះជាបញ្ហាមួយ ។

ក៏ប៉ុន្តែជាបច្ច័យមួយទៀត ក៏វាសម្របបច្បាប់ យើងថាសម្របនេះវាមិនត្រូវទេ ។ ក៏វាបញ្ជាក់ថា

ខាងលើគេល្អាសវៃ គេចាប់មនុស្សធំ *សេអ៊ីអា* ធំ *កាហ្សេបេ* ធំភ្ញាក់ងារយួនអីនោះអ៊ីចឹង ។ ឧទាហរណ៍ ដូច កុយ ធួន បើសិនជាស-២១ សួរចម្លើយមិនចេញ កុយ ធួន មិនសារភាពទេ ខាងលើក៏វាខ្មាសខ្លួនឯងក្នុងការសម្រេចចាប់នេះដែរ ។ ដូច្នេះ ទីមួយគឺដើម្បីបញ្ជាក់ថាខាងលើគេចាប់ហ្នឹងវាត្រូវ ទីពីរសម្រាប់គេយកទៅប្រើក្នុងការស្រាវជ្រាវរកមនុស្សផ្សេងទៀត នេះខ្ញុំសូមបញ្ជាក់ជូនលោកប្រធានប៉ុណ្ណេះ ។

[១១:៤៦:០២]

**ស៖** លោកបាននិយាយព្រឹកមិញអំពីការបែងចែកក្រុមនៃការសួរចម្លើយនៅស-២១ នេះ គឺមានបង្កើតឱ្យមានស្ត្រី ក្រុមសួរចម្លើយដែលជាស្ត្រីភេទសម្រាប់សួរចម្លើយអ្នកឃុំឃាំងជាស្ត្រី ប៉ុន្តែ ស្ត្រីដែលចាត់តាំងឱ្យធ្វើជាអ្នកសួរចម្លើយនោះត្រូវចាប់ខ្លួនឃុំឃាំង សួរចម្លើយ ទារុណកម្ម និងកម្ទេច ជាបន្តបន្ទាប់ ។ ហើយតាមការដែលការកត់ការចងចាំរបស់យើងរហូតដល់ឆ្នាំ១៩៧៧ គឺបញ្ហានេះក៏បញ្ចប់ទៅ។ យើងចង់បញ្ជាក់សួរថា តើស្ត្រីដែលចាត់ឱ្យសួរចម្លើយហើយស្រាប់តែក្រោយមកខ្លួនឯងហ្នឹងក្លាយទៅជាអ្នកទោសទៅវិញហ្នឹង វាមានហេតុផលឬក៏កំហុសយ៉ាងម៉េចទៅបានជាមានដូច្នេះ? យើងឃើញថាស្ត្រីមានភាគតិច ប៉ុន្តែមានបញ្ហានេះបើធៀបគិតជាភាគរយច្រើនជាងកម្មាភិបាលបុគ្គលិកផ្នែកខាងបុរស ចង់និយាយអំពីក្រុមសួរចម្លើយ ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! កម្មាភិបាលស្រីទាំងប្រាំរូបដែលខ្ញុំបាទចាត់តាំងដោយទទួលបានអនុញ្ញាតពីខាងលើឱ្យទៅជាកម្មាភិបាលសួរចម្លើយស្រីនេះចាប់កំណើតប្រហែលជា១ក្នុងឆ្នាំ១៩៧៤ (សូមទោស) ៧៧ ក្នុងឆ្នាំ១៩៧៧ ក្រោយពីព្រឹត្តការណ៍ដែលមានអ្នកសួរចម្លើយប្រុសម្នាក់រំលោភលើរាងកាយរបស់អ្នកគ្រូ ឌឹម សារឿន ។ ហើយកម្មាភិបាលទាំងប្រាំរូបនេះដំណើរការសួរចម្លើយរហូត ។ ខ្ញុំសូមបញ្ជាក់ឡើងវិញម្តងទៀត មិញខ្ញុំបានរាយការណ៍ជូនលោកប្រធានហើយកម្មាភិបាលស្រីដែលសួរចម្លើយស្រីនេះ អត់មានកំហុសអីទេ មិត្តពឿន ប្រពន្ធមិត្តម៉េង នេះ តែដល់យើងខ្ញុំសម្រេចចាប់ មិត្តម៉េង តាមគោលការណ៍ ដែលខាងលើបញ្ជាជាស្វ័យប្រវត្តិត្រូវតែចាប់ មិត្តពឿន អស់មួយនៅសល់បួន ។ ក្រោយមកនៅថ្ងៃ០៦ ខែធ្នូ នេះបើតាមខ្ញុំចាំទេ ១៩៧៨ ខាងលើសម្រេចឱ្យយើងខ្ញុំចាប់មិត្តហ៊ុយ ដូច្នេះតែកាលណាចាប់មិត្តហ៊ុយ ហើយ ប្រពន្ធមិត្តហ៊ុយ ឈ្មោះ ប្រុក ខឿន នោះក៏ត្រូវតែចាប់តទៅទៀតដែរ ។ នេះអស់ពីរ ។ មិត្តខឿន អត់មានរឿងអីទេ ក៏ប៉ុន្តែ ប្តីគ្នាវាទៅ ប្តីគ្នាវាត្រូវចាប់ហើយជាស្វ័យប្រវត្តិយើងខ្ញុំត្រូវតែចាប់ មិត្តខឿន ទៀត ។ ដូច្នេះ មកដល់ថ្ងៃ០៦ ធ្នូ ១៩៧៨ នេះអស់ម្នាក់ទៀត គឺមិត្តខឿន នៅសល់ មិត្តមុត ប្រធាន ប្រពន្ធមិត្តហ៊ា មិត្តនី អនុប្រធានប្រពន្ធមិត្តប៉ុន-- ថាសមាជិកអ៊ីចេះទៅ

ចុះ ហើយនិងមិត្តរ៉ន សមាជិក ។ នៅសល់បីនាក់ហ្នឹង ។ អត់មានរត់ជាមួយខ្ញុំទាំងអស់គ្នាហ្នឹង ។ នេះសូមបញ្ជាក់ថានៅសល់បី ។ ហើយកម្មាភិបាលស្រីៗពីរនាក់ដែលចាប់អត់មានរឿងផ្ទាល់ខ្លួនទេ គឺចាប់ដោយសាររឿងគ្នាជាប្រពន្ធរបស់គេ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១១:៤៩:៤៨]

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម មានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទរូបនេះដែរឬទេ?

អញ្ជើញលោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** តើលោកអាចជម្រាបប្រាប់យើងខ្ញុំទេ ទៅតាមការយល់ដឹងរបស់លោក តើអ្វីទៅជាការធ្វើទារុណកម្ម? តើការធ្វើទារុណកម្មមានន័យដូចម្តេចចំពោះលោក?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំពិបាកឆ្លើយណាស់សំណួរនេះ ដូចជាពាក់ព័ន្ធនឹងទស្សនវិជ្ជាជ្រាលជ្រៅ។ ពិបាកឆ្លើយ ។ ខ្ញុំសូមលោកប្រធាន លោកចៅក្រមមេត្តាសួរយ៉ាងម៉េចឲ្យខ្ញុំបានឆ្លើយរួចផង ។ នេះជ្រៅ ។

**ស៖** តើអ្វីទៅជាលក្ខណៈសម្បត្តិនៃការធ្វើទារុណកម្ម? តើការធ្វើទារុណកម្មហ្នឹងមានន័យថាដើម្បីបង្កឲ្យមានការឈឺចាប់កម្រិតធ្ងន់ដល់បុគ្គលណាម្នាក់នោះឬ? តើការធ្វើទារុណកម្មហ្នឹងគ្រាន់តែជាការឈឺចាប់ទៅលើរាងកាយទេឬ?

**ឆ៖** នេះពិតជាការធ្វើទុក្ខធ្វើបាបបន្ថែមទៅលើជនរងគ្រោះបង្ខំឲ្យឆ្លើយ ។ ដូច្នេះ វាជាការចាប់បង្ខំទាំងផ្លូវកាយ ដោយមានការឈឺចាប់ខាងសាច់ ខាងឈាម ហើយក៏វារួមផ្សំនឹងការស្តី ការជេរទៅទៀត វាទៅជាការចាប់បង្ខំខាងផ្លូវចិត្ត ខាងផ្លូវគំនិត ឲ្យអ្នកសារភាព គេសុខចិត្តសារភាព ។ ជាគោល-ការណ៍ដែលខ្ញុំបង្រៀនគេ គឺឲ្យគេយកឈ្នះអ្នកទោសខាងផ្លូវសម្តីសិន មុននឹងរត់ទៅរកទារុណកម្មត្រូវឈ្នះអ្នកទោសខាងផ្លូវសម្តីសិន ។ ក៏ប៉ុន្តែ មានអ្នកណាធ្វើងាយកើតទេ គេច្រើនតែគិតរហ័សដល់ទារុណកម្ម ។ ដូច្នេះ វាទៅទាំងព្រមៗ វាទៅទាំងការធ្វើឲ្យឈឺចាប់ខាងរូបរាងកាយ វាធ្វើឲ្យការឈឺចាប់ទាំងខាងផ្លូវចិត្ត ផ្លូវគំនិត ។ សរុបមក គឺវាមានទោសទណ្ឌទាំងសព្វយ៉ាងអ៊ីចឹង ។

**ស៖** ព្រឹកមិញនេះ យើងបាននិយាយអំពីវិធីផ្សេងៗដែលអ្នកជាប់ទោសត្រូវបានគេធ្វើទារុណកម្ម។ តើលោកមានដែលធ្វើការស្រមើស្រមៃ ថាតើអ្នកទោសអស់ទាំងហ្នឹងនឹងមានអារម្មណ៍បែបណា? ឧទា-

ហារណ៍ នៅក្នុងករណីដែលថាប្រើទឹក ពីព្រោះលោកបាននិយាយថា ជួនកាលទឹកហ្នឹងត្រូវបានចាក់បញ្ចូលតាមរន្ធច្រមុះរបស់អ្នកទោស ។ តើការចាក់ទឹកតាមច្រមុះហ្នឹងវាបណ្ដាលឲ្យមានឥទ្ធិពលបែបណាដែរ បើតាមការយល់ដឹងរបស់លោកនោះ?

[១១:៥៥:០៧]

**ឆ៖** ពិសោធន៍នៅប៉ូលិសជំនាន់មុន គេចាក់ទឹកនេះដល់កាលណាពេញក្នុងពោះហើយ គេលើករលាក់ឲ្យក្អួត ដល់ក្អួតមកម្ដងពីរដងមនុស្សនោះសន្លប់បាត់ស្មារតី រួចបានគេទុកឲ្យនៅដឹងស្មារតីឡើងវិញ បានគេចាប់ផ្ដើមសួរម្ដងទៀត ។ នេះជាវិធីដែលគេធ្វើនៅនុ៎ង ។ នៅស-២១ ធ្វើបានចំពោះតែមនុស្សតែម្នាក់ទេ ឈ្មោះ យាង ជួន ។ យាង ជួន នេះល្បីនៅក្នុងជួរ ថាជាមនុស្សដែលប៉ូលិសជំនាន់មុន-- ប៉ូលីសនារដ្ឋការជំនាន់មុន ចាក់ទឹកក្នុងច្រមុះគាត់ គាត់អត់សន្លប់ គាត់ចេះអាម៉េច ទឹកមិនចូល ទឹកមិនចូលច្រមុះ ទឹកមិនចូលដល់ស្លួត ទឹកមិនចូលទៅក្នុងខ្លួនគាត់ ។ នៅពេលដែលមកដល់ស-២១ សួរចម្លើយគ្រប់វិធីមិនចេញ ។ ដល់សួរចម្លើយតាមវិធីណាក៏មិនចេញ ខ្ញុំនិងមិត្តហ៊ី អ្ហេ! ឥឡូវយើងលតាមវិធីនេះមើល តើល្បីថាគាត់ខ្លាំងវាចាក់ទឹកចូលច្រមុះ វាមិនចូលច្រមុះគាត់ តើមែនមិនមែន? ដូច្នេះ យើងខ្ញុំលសម្រេចឲ្យគេលក្នុងវិធីហ្នឹង លចាក់ទឹកមិនចូលមែន ។ ដូច្នេះ បច្ច័យល្អអាក្រក់ក្នុងរឿងចាក់ទឹកចូលច្រមុះនេះ វាមានជាពិសោធន៍របស់ប៉ូលិសជំនាន់មុន ។ ឯចំណែកនៅស-២១ ធ្វើបានតែមួយនេះ ធ្វើមិនបានសម្រេចផលទៀត ។ ដូច្នេះ យើងខ្ញុំធ្វើបានតែមួយហ្នឹងឯង អត់បានធ្វើតទៅទៀតទេ ។ សូមរាយការណ៍ជូនប៉ុណ្ណេះ ។

**ស៖** ដូច្នេះ តាមលោក វាមិនមែនជាវិធីមួយដែលមានប្រសិទ្ធភាព ហើយបន្តអនុវត្តនោះទេ ប៉ុន្តែយ៉ាងណាក៏ដោយ វិធីនេះគឺជាបច្ចេកទេសមួយដែលវាមានលក្ខណៈចាស់គំរិល ដូចដែលលោកបានលើកឡើង ហើយលោកនិយាយថា ទឹកអត់ចូលទៅដល់ស្លួត ។ ប៉ុន្តែ តើលោកគិតដែរទេ នៅពេលដែលបុគ្គលត្រូវបានគេចាក់ទឹកដូច្នោះនោះ អាចមានអារម្មណ៍ថប់ខ្យល់ ឬក៏មានអារម្មណ៍ដូចជាលង់ទឹកអឺចឹងហើយ មានអារម្មណ៍ថាគាត់នឹងស្លាប់? តើលោកជឿថា វិធីនោះគឺវាមិនមានប្រសិទ្ធភាព ហើយមិនមានលំបាក ឬក៏ហេតុផលនៅចុងក្រោយ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ការធ្វើទារុណកម្មបែបនេះ ជនរងគ្រោះពិតជាមានអារម្មណ៍ដូចជាលង់ទឹកស្លាប់អឺចឹងមែន ។ នេះវាជាបញ្ហាធំហើយ យើងខ្ញុំទទួលក្នុងការសាកល្បងធ្វើទារុណកម្មបែបនេះ ។ ក៏ប៉ុន្តែ នៅក្នុងពេលនេះ ចំពោះបុគ្គល យាង ជួន នេះ ចាក់ទៅវាមិនចូល គាត់ចេះព្រួស

អាម៉េច ចាក់មិនចូលស្អួត ។ នេះវាជាបច្ចេកទេសរបស់គាត់ វាឆ្លាតជាងយើង ។ គាត់ត្រៀមខ្លួនតាំងពីមុនខ្មាំងចាប់គាត់នៅសង្គមចាស់ទៅទៀត ។

[១២:០០:៥០]

សរុបមក យើងខ្ញុំមិនបដិសេធទេការដែលសាកល្បងនេះវាពិតជាមានទោសកំហុស តែប្រសិទ្ធភាពរបស់យើងខ្ញុំទៅលើមនុស្សនេះ គ្មាន ។ សូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**ស៖** តើលោកដែលគិតដែរឬទេថា ថាតើគេមានអារម្មណ៍យ៉ាងម៉េចចំពោះបុគ្គលដែលត្រូវបានគេយកថង់មកគ្របលើខ្លួន លើមុខនោះ ថាតើបុគ្គលនោះគាត់មានអារម្មណ៍យ៉ាងម៉េចដែរ?

**ឆ៖** មនុស្សដែលត្រូវគេច្រកស្បោងប្លាស្ទិក ដូចជាគេចាប់ចងដៃ ចងជើង ហើយខ្ទប់ច្រមុះ ខ្ទប់មាត់ ដែលមានអារម្មណ៍ថាប្រកាច់ងាប់ឥឡូវហ្នឹង ។ នេះមនុស្សដែលរងទារុណកម្មបែបនេះ គឺពិតជាមានអារម្មណ៍អ៊ីចឹង ។

**ស៖** ថាតើលោកមានវត្តមានដែរឬទេ នៅពេលដែលមានការធ្វើទារុណកម្មដាក់ថង់ខ្ទប់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អត់បានទៅមើលទេ ហើយចំនួននៃអ្នករងគ្រោះបែបនេះក៏ប្រហែលជាតិចដែរ ។ រូបថតដែលនៅសល់បញ្ជាក់ថា នៅស-២១ មានសាកល្បងធ្វើទារុណកម្ម ក៏ប៉ុន្តែថ្លោះធ្លោយរហូតដល់ស្លាប់ម្នាក់ ។

**ស៖** នៅក្នុងរបាយការណ៍ដាក់ជូនលោក ថាតើគេប្រាប់លោកថាមានការវិវឌ្ឍន៍យ៉ាងម៉េចចំពោះការធ្វើទារុណកម្ម? ហើយបុគ្គលគាត់ទទួលកម្រិតទារុណកម្មនោះត្រឹមកម្រិតណា? ថាតើលោកទទួលបានដំណឹងអំពីការវិវឌ្ឍនៃការធ្វើទារុណកម្មនោះដែរទេ?

**ឆ៖** កម្រិតនៃការធ្វើទារុណកម្ម ភាគច្រើនគេច្រើនដាក់ថា មធ្យម, តិចតួច ។ បើតាមដែលខ្ញុំចាំឃើញមានសេចក្តីរាយការណ៍របស់ មិត្តប៉ុន មួយគាត់និយាយច្បាស់ប៉ុន្មានរំពាត់ ។ នេះគេមានបញ្ជាក់ច្បាស់អ៊ីចឹង ហើយខ្ញុំក៏ចារទៅបញ្ជាគេថែម ឲ្យធ្វើប៉ុនណាទៅទៀត យ៉ាងម៉េចទៅទៀត ។ ដូច្នេះ លង់ខ្លួនទៅដល់ៗធ្វើទារុណកម្មហើយ ឯកសារដែលនៅសល់មិនដែលមានឯកសារណាបញ្ជាក់ឲ្យឃើញថាខ្ញុំបានណែនាំខាងនយោបាយឡើងវិញ ច្រើនតែបញ្ជូនឲ្យគេធ្វើទារុណកម្មថែមទៀត ។ នេះវាមាន បញ្ហានេះ ។ នេះសូមជម្រាបលោកចៅក្រម ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះយើងដល់ពេលត្រូវសម្រាក ត្រូវពិសាអាហារថ្ងៃត្រង់ហើយ ដូច្នេះអង្គជំនុំជម្រះសាលា

ដំបូងប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ។ ហើយអង្គជំនុំជម្រះនឹងបន្តនូវវេលាម៉ោងមួយកន្លះនៅថ្ងៃរសៀលនេះ ។ សូមអញ្ជើញភាគីអញ្ជើញមកចូលរួមនៅក្នុងដំណើរការសវនាការតាមម៉ោងបានកំណត់នេះ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំវិញ ហើយឲ្យនាំគាត់ត្រឡប់មកបន្ទប់សវនាការវិញឲ្យបានមុនម៉ោងមួយកន្លះរសៀលនេះ ។

*[សវនាការសម្រាកពីម៉ោង ១២:០៥នាទី ដល់ម៉ោង ១៣:៣៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោល ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ...និងធ្វើឲ្យថប់ដង្ហើម ប្រសិនបើខ្ញុំយល់ត្រឹមត្រូវនោះ គឺយើងមានវិធីទារុណកម្មពីរទៀតដែលលោកបានទទួលស្គាល់ថាបានប្រើប្រាស់នៅស-២១ ។ គឺទម្រង់ចាស់ ទម្រង់ទារុណកម្មចាស់ៗដូចជាការវាយតប់ផ្សេងៗ ។ ប្រសិនបើខ្ញុំយល់ត្រឹមត្រូវនោះ សូមឲ្យលោកបញ្ជាក់ទៅលើទម្រង់នេះ ។ ហើយការកម្រិតទៅលើការវាយតប់នោះ គឺនៅពេលដែលលក្ខខណ្ឌដែលលោកដាក់ថាកុំអ្នកទោសនោះស្លាប់ អ៊ីចឹងនេះជាលក្ខខណ្ឌកម្រិត ហើយនិងការហាមឃាត់ផ្សេងៗដែលលោកមានការបញ្ជាក់ទៅដល់អ្នកសួរចម្លើយ ឬក៏លោកមានដាក់ការកម្រិតផ្សេងៗទេទៅដល់អ្នកសួរចម្លើយនៅក្នុងការធ្វើទារុណកម្មនេះ?

**ឆ៖** លោកចៅក្រមជាទីគោរព! ទារុណកម្មទាំងអស់សុទ្ធតែមានបំណងយកចម្លើយសារភាព ។ លោកចៅក្រមក៏ជ្រាបហើយថា រូបភាពដែល *ក្លាស្ស៊ិក* បំផុតគឺវាយ ។ រូបភាពនេះក៏ដោយ រូបភាព--ធ្វើម៉េចយកចម្លើយឲ្យបាន ហើយសំខាន់កុំឲ្យទ្រោមខ្លួន សួរតទៅទៀតមិនកើត ។

**ស៖** យើងមិនបានឮនូវអ្វីដែលលោកនិយាយពីដើមដោយតែបញ្ហាចរន្តអគ្គិសនី ។

**ឆ៖** រូបភាពវាយនេះ វាជារូបភាពដែលបូរាណបំផុត *ក្លាស្ស៊ិក* បំផុត ។ វត្ថុបំណង ការសំណូមពរដែលហាមឃាត់មានតែមួយទេ ធ្វើកុំឲ្យស្លាប់ដាច់ចម្លើយ ។ នេះជារូបភាពមូលដ្ឋានដែលយើងខ្ញុំលើកសំណូមពរ ។ តែមានរូបភាពមួយទៀតដែរ គឺធ្វើម៉េចបើយើងវ៉ៃទៅទ្រោមខ្លួន សួរទៅទៀតលែង

កើត ដូច្នេះវាពន្យារការស្ត្របរចម្លើយរបស់យើងកក មិនត្រូវឲ្យមានតទៅទៀត មិនត្រូវឲ្យមានហូរហែដែរ ត្រូវចៀសវាង ។

សរុបមកសំណូមពរមានសំខាន់ពីរនេះឯង តែអាមួយសំខាន់ជាងគេគឺកុំឲ្យស្លាប់ដាច់ចម្លើយ ។

**ស៖** ដូច្នេះ ការផ្តល់ដំបូន្មានដែលលោកធ្វើឡើងនោះគឺដើម្បីអនុវត្តវិធីនេះឲ្យមានប្រសិទ្ធភាព ធ្វើយ៉ាងណាឲ្យមានប្រសិទ្ធភាពពីវិធីសាស្ត្រដែលគេប្រើ ។ លោកបានលើកឡើងថានៅម-១៣ លោកខ្លួនឯងបានអនុវត្តការធ្វើទារុណកម្មបែបនេះ ថាតើវាត្រឹមត្រូវដែរឬទេ?

**ឆ៖** នៅម-១៣ ខ្ញុំបានអនុវត្តការសួរចម្លើយដោយ ដោយមានការធ្វើរបៀបអង្កៀមៗលើបុរសម្នាក់ឈ្មោះ ង៉ែត សំបុន ។

[១៣:៤២:៥៥]

**ស៖** លោកខ្លួនឯងផ្ទាល់មិនដែលធ្វើការវាយអ្នកទោសទេ ឬយ៉ាងម៉េច?

**ឆ៖** ខ្ញុំបើសួរចម្លើយ ង៉ែត សំបុន ខ្ញុំបានវាយផ្ទាល់ដៃដែរ ពិត ។

**ស៖** វាមានលក្ខណៈងាយស្រួលក្នុងការដឹងថា នៅពេលណាដែលលោកគួរបញ្ចប់ការធ្វើទារុណ-កម្មនោះដែរឬទេ?

**ឆ៖** សម្រាប់ខ្ញុំសូមជម្រាបលោកចៅក្រមឲ្យត្រង់ មុននឹងការដែលខ្ញុំវ៉ៃ ទាល់តែខ្ញុំផ្តាញ់គេដោយពាក្យសម្តីឲ្យគេចុះចាញ់សិន ។ ដល់ហើយបានៗខ្ញុំវ៉ៃតិចតួចណាស់ ដូច្នេះខ្ញុំម្ចាស់ការក្នុងរឿងឈប់បាន វាយក៏បានគិត ឈប់ក៏បានគិត ។ ឯចំណែក ក្មេងផ្សេង ទៅមិនរួចទេ ។

សរុបមក ទារុណកម្មវាជារូបភាពមួយ ជាឧក្រិដ្ឋកម្មមួយដែលយើងដោះស្រាយមិនរួចទេ ខ្ញុំទទួល ។ គិតយូរៗកាន់តែតក់ស្លុតចំពោះឧក្រិដ្ឋកម្មបែបនេះកាន់តែខ្លាំង ។ នេះខ្ញុំសូមនិយាយមួយម៉ាត់ប៉ុណ្ណោះ ហើយខ្ញុំមិនឆ្លើយដាក់ខាងលើដែលគេអនុញ្ញាតជាទូទៅទូទាំងប្រទេសទេ ។ អានេះវាជារឿងមួយដែលខ្ញុំធ្វើនៅស-២១ ខ្ញុំពិតជា--។ ដូច្នេះ ខ្ញុំសូមនិយាយខ្លីប៉ុណ្ណោះ ហើយរង់ចាំឆ្លើយនឹងសំណួរលោកចៅក្រមតទៅទៀត ។

**ស៖** ដូច្នេះ ប្រសិនបើខ្ញុំយល់ត្រឹមត្រូវនោះ អ្វីដែលលោកបានរៀបរាប់ប្រាប់យើង លោកបានលើកឡើងថា គឺលោកអាចធ្វើការគ្រប់គ្រងខ្លួនឯងបាន ហើយលោកអាចដឹងអំពីការគ្រប់គ្រងខ្លួនឯងបាន ហើយលោកអាចរក្សាអំពើហិង្សារបស់លោក ហើយការវាយតប់របស់លោកមានលក្ខណៈប្រសិទ្ធភាពដែលមិនអាចហួសដែនកំណត់ ។ ថាតើលោកបានបង្រៀនវិធីសាស្ត្រនេះដូចគ្នាទៅដល់អ្នកដែលនៅ

ក្រោមបង្គាប់របស់លោកដែលកូនក្មេងៗនោះដែរឬទេ ដើម្បីឲ្យគេគ្រប់គ្រងទៅលើភាពហិង្សារបស់ពួកគេ ដែលអំពីទាំងអស់នេះវាអាចអនុវត្តនៅក្នុងស្ថានភាពមួយចំនួន?

**ឆ៖** និយាយនៅក្នុងមន្ទីរ១៣ ខ្ញុំបង្រៀនម្នាក់ដែលខ្លាំងជាងគេ ជាប់ជាងគេ គឺមិត្ត ប៉ុន ។ ដូច្នេះគេអាចម្ចាស់ការបានគួរសម ច្បាស់លាស់គួរសមរបស់គេ ។ ឯចំណែក ក្មេងៗផ្សេងទៀតមិនម្ចាស់ការទេ វាអាស្រ័យទៅតាមចរិតកំណើតរបស់គេ អ្នកខ្លះសាហាវដែរ អ្នកខ្លះកាចដែរ ។

**ស៖** តើលោកគិតដែរឬទេថា វាមានវិធីសាស្ត្រក្នុងការកាចសាហាវក្នុងការអនុវត្តការធ្វើទារុណកម្ម?

[១៣:៤៨:១០]

**ឆ៖** លោកចៅក្រមជាទីគោរព! របៀបវ៉ៃវាឃោរឃៅ វាព្រៃផ្សៃមួយកម្រិតហើយ ។ បើនិយាយអំពីរូបភាពដែលកាន់តែ-- ខ្ញុំគិតពេលនោះ គំនិតខ្ញុំពេលនោះ ដែលកាន់តែឃោរឃៅទៅទៀតគឺឆក់ខ្សែភ្លើង ច្រកស្បោងប្លាស្ទិក ច្រកទឹកតាមច្រមុះ ។ ព្រោះវានាប់នាំឲ្យអ្នកទោសស្លាប់ជាងវ៉ៃ ។ ដូច្នេះហើយបានជាឃើញគេប្រើរូបភាពមួយសំពះរូបឆ្កែ ខ្ញុំក៏ជំរុញឲ្យអនុវត្តបញ្ហានេះថែមទៀត ។ សរុបមករូបភាពវារូបភាពហើយ ប៉ុន្តែ ខ្លឹមសារវាដូចតែគ្នាហ្នឹង សំពះរូបឆ្កែក៏វាជាឧក្រិដ្ឋកម្មមួយបែបខាងផ្លូវចិត្ត ខាងផ្លូវសេចក្តីថ្លៃថ្នូរក្នុងឋានៈជាមនុស្ស ។ ដូច្នេះ ឲ្យតែ--

សរុបមកឲ្យតែទារុណកម្ម ខ្ញុំឥឡូវនេះ សុទ្ធតែទារុណកម្ម ធ្ងន់ឬស្រាលអត់និយាយទេ សុទ្ធតែទារុណកម្ម ដែលខ្ញុំអនុញ្ញាតឲ្យអ្នកសួរចម្លើយសួរ តាមការដែលខាងលើអនុញ្ញាតគ្មានវិធានការអីទប់ទល់ទេ គ្មានវិធានអីបន្ធូរបន្ថយទេ ទទួលឧក្រិដ្ឋកម្មនេះ ។

**ស៖** ប្រហែលជាមានបញ្ហាបន្តិចទាក់ទងនឹងបញ្ហាបកប្រែ ។ លោកបាននិយាយថា លោកបានប្រើនូវវិធីធ្វើទារុណកម្មលើផ្លូវចិត្តដែលជាកាតព្វកិច្ចមួយក្នុងការសំពះដល់រូបសត្វឆ្កែ មិនមែនសត្វទាទេមែនទេ?

**ឆ៖** ខ្ញុំឲ្យសំពះរូបឆ្កែនេះ គូរជារូបការីកាតៀ ជារូបថ្លុក ។ ឆ្កែមួយគូររូបក្បាលហូជីមិញ ឆ្កែមួយទៀតគូររូបក្បាល ជេសុន ។

**ស៖** ដូច្នេះលោកបានពន្យល់ប្រាប់ថា វិធីនេះគឺវាមិនមែនឃើចាប់ដូចឆក់ខ្សែភ្លើងទេ តើលោកដែលមានវត្តមានទេ នៅពេលដែលមានការធ្វើការដោយឆក់ខ្សែភ្លើងនោះ? តើលោកមានដឹងទេថានៅ

ប្រភេទនៃការឈឺចាប់ដែលជនម្នាក់មានអារម្មណ៍នៅពេលដែលចរន្តខ្សែបានឆក់ទៅលើរាងកាយគាត់នោះ តើលោកមានគំនិតថា តើទំហំនៃការឈឺចាប់មានកម្រិតណា?

**ឆ៖** លោកចៅក្រមជាទីគោរព! ខ្ញុំអត់បានទៅមើលឆាកដែលគេធ្វើទារុណដោយឆក់ខ្សែភ្លើងទេ ហើយអ្នកដែលឆក់ខ្សែភ្លើងរហូតដល់ស្លាប់មិនទាន់ដែលព្យាយការណ៍មកដល់ខ្ញុំទេ ។ ក៏ប៉ុន្តែ មានរូបភាពមួយដែលខ្ញុំបានជម្រាបអង្គសវនាការយើងពីមុនរួចមកហើយ ធ្វើឲ្យប្រដាប់ភេទរបស់គ្នាហ្នឹងស្លាប់ វាប្រើការលែងកើត ។

**ស៖** តើមានតែប្រដាប់ភេទទេដែលត្រូវបានឆក់នោះ ឬក៏ការឆក់ខ្សែភ្លើងក៏ត្រូវបានប្រើមកលើដោះ មកលើក្បាលដោះ ឬក៏មកលើត្រចៀកដែរនោះ?

**ឆ៖** ខ្ញុំមិនដែលឮទេៗ ។ ខ្ញុំដែលតែឮការឆក់មនុស្សប្រុសម្នាក់ ហើយធ្វើឲ្យប្រដាប់ភេទរបស់មនុស្សប្រុសនោះស្លាប់ ។

[១៣:៥៥:១៦]

**ស៖** ទៅតាមអ្វីដែលលោកយល់ដឹង តើប្រព័ន្ធនៃការធ្វើទារុណកម្មហ្នឹង ត្រូវបានប្រើមួយពេលទេ ឬក៏ត្រូវបានប្រើជាច្រើនដង?

**ឆ៖** ឆក់ខ្សែភ្លើងនេះ ខ្ញុំបានទទួលសេចក្ដីរាយការណ៍ក្រោយមកហើយទេ ។ នៅពេលដែលរត់គឺក្រោយ ៧មករា ១៩៧៩ ។ សរុបមក ចំពោះរឿងឆក់ខ្សែភ្លើងខ្ញុំមិនហ៊ានធានាថា មានតែម្ដងទេ ឬក៏យ៉ាងម៉េចទេ ក៏ប៉ុន្តែ រឿងគ្រោះថ្នាក់ដែលសាមីខ្លួនអ្នកអនុវត្តទៅលើគេនោះ ចាប់អារម្មណ៍ហើយរាយ-ការណ៍ប្រាប់ខ្ញុំ ក្នុងឋានៈខ្ញុំអ្នកឈឺចាប់អៀនខ្មាស់មានមួយលើកនេះឯង ដែលខ្ញុំបានដឹង ។

**ស៖** តើលោកដែលមានចាប់អារម្មណ៍ទេ ក្នុងការដឹង ចង់ដឹងពីប្រភេទនៃការធ្វើទារុណកម្មដែលអ្នកសួរចម្លើយបានប្រើ ឬមួយក៏លោកចាប់អារម្មណ៍តែការទទួលបាននូវចម្លើយសារភាពប៉ុណ្ណោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំអត់ទាន់បានៗគិតពីរឿងបំណងរបស់អ្នកសួរអីលើសអំពីការចង់បានសេចក្ដីសារភាពនេះទេ ។ មានតែរឿងមួយដែលយើងអាចគិតខុសថា អ្នកសួរចម្លើយគេគិតខុសពីហ្នឹង ។ រឿងមួយដែលអ្នកសួរចម្លើយគេអាចគិតខុសពីហ្នឹង គឺរឿងដែលគេរំលោភលើខ្លួនប្រាណអ្នកគ្រូ ឌឹម សារឿន ។

**ស៖** តើលោកដែលពិចារណាទេថា វិធីនិងមធ្យោបាយនៃការធ្វើទារុណកម្មគឺវាមិនសំខាន់ទេ អ្វីដែលសំខាន់នោះ គឺចុងបញ្ចប់នៃការធ្វើទារុណកម្ម ឬក៏ការសួរចម្លើយនោះ?

**ឆ៖** លោកចៅក្រមជាទីគោរព! សម្ដីលោកដែលសួរខ្ញុំអំមិញ មាននិយាយដាច់ៗ ខ្ញុំស្ដាប់អត់បានមួយកំណាត់ ។

**ស៖** ខ្ញុំកំពុងសួរថា ទៅតាមទស្សនៈរបស់លោក វិធីនិងមធ្យោបាយនៃការធ្វើទារុណកម្មហ្នឹង គឺវាសំខាន់ទេ វាគ្រាន់ជាមធ្យោបាយបន្ទាប់បន្សំតែប៉ុណ្ណោះ អ្វីដែលសំខាន់បំផុតនោះ គោលបំណងៗនៃសួរចម្លើយ ឬក៏ការធ្វើទារុណកម្មនោះ គឺដើម្បីទទួលបាននូវចម្លើយសារភាព ។ តើលោកថា យល់ថានេះគឺជាមធ្យោបាយដែលលោកបានគិតនៅពេលនោះឬ?

ឥឡូវនេះ ខ្ញុំចង់និយាយទៅលើសំណួរមួយទៀតដែលបានសួរទៅរួចហើយកាលពីថ្ងៃ២៧ ខែមេសា មុននេះ ។ សំណួរហ្នឹងគឺមានដូចខាងក្រោមនេះ៖

ខ្ញុំព្យាយាមចង់យល់ថា ហេតុអ្វីបានជាលោកត្រូវបានគេជ្រើសរើសឲ្យធ្វើជាប្រធានស-២១? ហើយ នៅក្នុងអំឡុងពេលនៃសវនាការនោះ លោកបានឆ្លើយថា នោះគឺជាចម្លើយដែលលោកបានផ្ដល់មកឲ្យសហចៅក្រមស៊ើបអង្កេត ។ លោកបាននិយាយឃ្លាដូចខាងក្រោមនេះ៖

"គឺដោយសារតែជាមនុស្សដែលប្រសើរជាងគេ ។ ប្រសើរជាងគេនៅក្នុងការអនុវត្ត ការសួរចម្លើយ គឺប្រសើរជាង ណាត ទៅទៀត ។ ហើយលោកក៏បាននិយាយទៀតថា ខ្ញុំប្រសើរជាង ណាត ទាក់ទងទៅនឹងការសួរចម្លើយ ហើយខ្ញុំថែមទាំងបានបង្រៀនប្រសើរជាងគាត់ទៀត នៅពេលដែលខ្ញុំបានបង្រៀននូវវិធីសាស្ត្រនៃការសួរចម្លើយ ហើយនេះគឺជាការពិត ។ នេះគឺជាចំណុចមួយដែលខ្ញុំមិនប្រកែកទេ ហើយខ្ញុំត្រូវជ្រើសតាំងដោយសារតែបក្សមានទំនុកចិត្តមកលើខ្ញុំ ។ ខ្ញុំជាមនុស្សសុចរិតស្មោះត្រង់ ហើយខ្ញុំនិយាយតែការពិតប្រាប់ទៅបក្សវិញ ។"

ដូច្នេះ សំណួររបស់ខ្ញុំគឺសាមញ្ញបំផុត តើវាមានន័យថាម៉េចៗសម្រាប់លោកដែលលោកជាមនុស្សដែលប្រសើរជាងគេ? តើអ្វីទៅដែលគុណភាពនៃភាពប្រសើរនៅក្នុងស្ថានភាពបែបហ្នឹង?

**ឆ៖** ក្នុងពេលដែលខ្ញុំឆ្លើយពីរឿងដែលខ្ញុំគ្រាន់បើជាង ណាត ដល់ខ្ញុំចេះបង្រៀនគេ ឲ្យចេះសួរសួរដោយមានការពិចារណាច្បាស់លាស់ ។ សំខាន់ គឺចៀសវាងមិនឲ្យសួរដឹកមុខ ។ ជាពិសេស គឺខ្ញុំចេះបង្រៀនមិនឲ្យគេសួរដឹកមុខ ។ មានន័យថា យើងសួរមិនតម្រង់ទិសឲ្យជនជាប់ចោទឆ្លើយតាមចិត្តយើងចង់ ។ នេះ ខ្ញុំគិតពីសមត្ថភាពរបស់ខ្ញុំជំនាន់នុ៎ង បើប្រៀបធៀបនឹង ណាត បានជាខ្ញុំប្រាប់ថា ខ្ញុំគ្រាន់បើជាង ។

**ស៖** ប្រសិនបើសិនជាខ្ញុំយល់អ្វីដែលលោកនិយាយនុ៎ង គឺលោកប្រសើរជាងគេបំផុតទាក់ទងទៅនឹងការងារនគរបាល មែនទេ? មានន័យថា នៅពេលដែលលោកនិយាយថា លោកជាមនុស្សប្រសើរជាងគេបំផុតនោះ គឺលោកប្រសើរជាងគេនៅក្នុងតែកិច្ចការប៉ូលិសទេនោះ ។ មានន័យថា ក្នុងការទទួលយកនូវព័ត៌មាន គឺមានន័យថា ដើម្បីទទួលយកនូវអ្វីដែលជាចម្លើយសារភាពដែលចម្លើយសារភាពនោះមានន័យ មានខ្លឹមសារ ហើយមិនសំដៅទៅលើវិធីនៃការទទួលយកនូវចម្លើយសារភាពនោះទេ គឺសំដៅតែទៅលើអត្ថន័យនៃចម្លើយសារភាពនោះ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! សេចក្តីសន្និដ្ឋានរបស់លោកចៅក្រមត្រឹមត្រូវខ្ញុំសូមទទួល។

[១៤:០៤:៣០]

**ស៖** ដូច្នេះ យើងប្រហែលជាអាចពិនិត្យមើលលើឯកសារ ដែលត្រូវបង្ហាញមើលកាលពីព្រឹកមិញនោះ ទាក់ទងទៅនឹងចម្លើយសារភាពរបស់ លី ផែល ដែលមានចំណារផ្ទាល់ដៃនៅលើនោះ ។ ដោយសារខ្ញុំមិនដឹងថា តើមានបញ្ហានៃការបកប្រែ ឬក៏អត់ទេ ប៉ុន្តែ ចៅក្រមបរទេស មិនអាចយល់ដឹងឲ្យបានច្បាស់លាស់នូវចំណារដែលសរសេរដោយដៃនោះ ។ លោក ប៉ៀល តើលោកអាចធ្វើការបង្ហាញឯកសារនោះនៅលើអេក្រង់បានទេ?

**លោក វីលៀម ស្មីត៖**

តើលោកមានលេខ ERN នៃឯកសារនោះដែរ ឬទេ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំមានលេខ ERN ជាភាសាអង់គ្លេស 00223138 រហូតដល់លេខ 00223141 ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន! នៅពេលដែលសហព្រះរាជអាជ្ញាកំពុងតែរកឯកសារនោះ តើខ្ញុំអាចសុំការអនុញ្ញាតពីលោកប្រធានទេ ដែលខ្ញុំចង់ជម្រាបប្រាប់អង្គជំនុំប្រាប់អង្គជំនុំជម្រះថា មេធាវីការពារក្តី បើសិនជាអាចធ្វើទៅរួចនោះ ចង់ឲ្យធ្វើការបង្ហាញឯកសារនោះ ដោយក្រឡាបញ្ជី ហើយមិនចង់ឲ្យខាងការិយាល័យសហព្រះរាជអាជ្ញាធ្វើការបង្ហាញឯកសារនោះទេ ។ ខ្ញុំយល់ថា នេះជាបញ្ហាមួយដែលធ្វើឲ្យការិយាល័យសហព្រះរាជអាជ្ញាធ្វើការបង្ហាញរាល់ឯកសារនៅពេល ដែលអង្គជំនុំជម្រះសួរចំណួរនោះ។ ដូច្នេះ បើសិនជាអាចធ្វើទៅរួចគឺខ្ញុំចង់ឲ្យខាងក្រឡាបញ្ជើរបស់អង្គជំនុំជម្រះជាការចាត់ចែងបង្ហាញរៀបចំឯកសារនោះ សូមអរគុណ ។

*(ចៅក្រមពិភាក្សាគ្នា)*

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកចៅក្រម ។ ការិយាល័យសហព្រះរាជអាជ្ញានឹងសប្បាយចិត្តក្នុងការបង្ហាញឯកសារណាមួយ ពីព្រោះដោយសារបញ្ហាបច្ចេកទេសនៅក្នុងបន្ទប់សវនាការ ហើយយើងយល់ថា ជាការលំបាកក្នុងការរៀនសូត្រឲ្យបានច្បាស់លាស់ពីបច្ចេកទេសអស់ទាំងហ្នឹង នេះគឺជាបន្ទុកមួយទៀតដល់ការិយាលសហព្រះរាជអាជ្ញា ក៏ប៉ុន្តែបើសិនជាលោកចៅក្រមយល់ថា ពួកយើងអាចយល់បានពួកយើងនឹងជួយ ។

**ប្រធានអង្គជំនុំ៖**

អរគុណដល់ការកត់សម្គាល់របស់លោកមេធាវី ហ្វ្រង់ស្វ័រ រូ ហើយក៏ដូចជាការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែរអំពីបញ្ហានេះ ។ ខ្ញុំសូមជម្រាបដល់ភាគី និងសាធារណជនថា អង្គជំនុំជម្រះក៏មានកង្វល់អំពីបញ្ហានេះដែរ ។ ប៉ុន្តែ មូលហេតុនៃបច្ចេកទេសនៅក្នុងការបង្ហាញនូវឯកសារ នូវរូបភាពនេះ គឺលទ្ធភាពនៃខាងអង្គជំនុំជម្រះមិនទាន់មានលទ្ធភាពដែលអាចធ្វើទៅបានទេផ្នែកខាងបច្ចេកទេស ។ ហេតុដូច្នេះហើយ បានជាយើងមានការបន្តក្នុងការប្រើប្រាស់នូវប្រព័ន្ធដែលបានរៀបចំរួចហើយនៃសហព្រះរាជអាជ្ញា ។ នេះជាការពិគ្រោះយោបល់ដែលយើងធ្វើម្តងហើយម្តងទៀត ហើយកិច្ចការនេះ គឺយើងនឹងប្រឹងប្រែងដើម្បីធ្វើការឲ្យប្រសើរឡើងតាមអ្វីដែលលោកមេធាវី ហ្វ្រង់ស្វ័រ រូ បានលើកឡើង វាជាហេតុផលសមរម្យ ។ ប៉ុន្តែ ចំពោះមុខនេះ គឺដើម្បីឲ្យដំណើរទៅ គឺយើងនៅតែត្រូវការនូវការបង្ហាញដោយសហព្រះរាជអាជ្ញាដែលមានលទ្ធភាពស្រាប់ ហើយរហូតដល់ពេលអំឡុងពេលមួយគឺថាយើងមានបច្ចេកទេសនេះអាចភ្ជាប់ជាមួយកុំព្យូទ័ររបស់ខាងក្រឡាបញ្ជី ឬក៏របស់មន្ត្រីតុលាការនៅទីនេះ ។ នេះជាហេតុផល មិនមែនថា អង្គជំនុំជម្រះមានការព្រងើយកន្តើយលើបញ្ហានេះទេ ជជែកម្តងហើយម្តងទៀត គឺច្រើនលើកច្រើនសាហើយដែរ ។

សូមអញ្ជើញ! ហើយសូមខាងផ្នែកខាងសោតទស្សន៍ធ្វើការភ្ជាប់ប្រព័ន្ធរូបភាពមកប្រពន្ធ័កុំព្យូទ័ររបស់ខាងតំណាងសហព្រះរាជអាជ្ញា ។

មិនឃើញទេ ខាងផ្នែកបច្ចេកទេសយ៉ាងម៉េចទៅ? សូមខាងអ្នកបច្ចេកទេសខាងសហព្រះរាជអាជ្ញា សូមគូសរង្វង់ ឬក៏ដាក់ពណ៌នៅក្នុងក្របខ័ណ្ឌនៃអក្សរដែលមាននៅក្នុងលើទំព័រនេះ ។ បានទេ? អាចដាក់បានទេ?

[១៤:១២:២៤]

**លោក វីលៀម ស្មីត៖**

ថាតើផ្នែកមួយណា ដែលលោកចៅក្រមចង់ឲ្យខ្ញុំគូសពណ៌ក្រហមនោះ?

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ថាតើយើងអាចធ្វើការបញ្ជាំងឲ្យកៀកទៅលើចំណារនេះដែរឬទេ? ដូចដែលអ្វីដែលយើងធ្វើព្រឹកមិញនេះ?

**ស៖** ដូច្នេះចំពោះអត្ថបទនេះ ខ្ញុំឃើញកាលបរិច្ឆេទនៅក្នុងថ្ងៃទី១៧ ខែកញ្ញា ឬក៏ខែមេសា ឆ្នាំ១៩៧៦? ដោយសារតែខ្ញុំមើលទៅអត់ឃើញច្បាស់ ថាតើអ្នកណាជាអ្នកសរសេរ? ហើយលោកសរសេរនៅត្រង់នេះ នៅខាងជ្រុងនេះ លោកសរសេរយ៉ាងម៉េច? ថានៅក្នុងខាងស្តាំនេះ តើលោកសរសេរជាពណ៌ស្វាយ ឬក៏ពណ៌ប្រផេះ? លោកសរសេរដោយប្រើពណ៌ទាំងពីរនេះ ។

[១៤:១៣:៤០]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អក្សរពណ៌ប្រផេះនេះ តាមពិត គឺអក្សរពណ៌ខ្មៅ ជាអក្សររបស់អ្នកចម្លង ជាអ្នកខាងអង្គុលីលេខ ឈ្មោះ មិត្តហួយ ។ ឯចំណែក អក្សរនៅខាងឆ្វេង ផ្នែកខាងឆ្វេងនេះ មានមួយ, ពីរ, បី, បួន, ប្រាំជួរទាំងស៊ីញ៉េផង ជាអក្សរខ្ញុំ ពណ៌ស្វាយ ។ បើតាមខ្ញុំចាំមិនមែនស្វាយទេ ប្រហែលជាក្រហម ។ អក្សរប្រាំជួរនេះ អក្សរខ្ញុំ ។ ខ្ញុំសរសេរថា “សួរនៅថ្ងៃ១៧ ខែកញ្ញា ១៩៧៦” អ្នកសួរទីមួយ ស៊ីញ៉េហើយបាន ឌុច ស៊ីញ៉េខ្ញុំ ហើយបានខ្ញុំស៊ីញ៉េ ឌុច ។ “ទីពីរ ប៉ុន” អត់មានស៊ីញ៉េទេ គឺដាក់ឈ្មោះ ។ អក្សរទាំងអស់នេះ ជាអក្សរខ្ញុំ មិនមែនអក្សរ ណាត ទេ អក្សរខ្ញុំនេះសូមជម្រាបជូនលោកចៅក្រមប៉ុណ្ណោះ ។

**ស៖** ដូច្នេះ នៅក្នុងអក្សរពណ៌ប្រផេះ វាហាក់ដូចជាបង្ហាញអំពីកាលបរិច្ឆេទ ហើយតើតួលេខនេះវាឆ្លើយតបទៅនឹងអ្វីដែរ? ប្រសិនបើលោកអត់ដឹងទេ លោកប្រាប់ថា អត់ដឹង ។

**ឆ៖** លោកចៅក្រម ខ្ញុំសរសេរថា “សួរនៅថ្ងៃទី១៧ ខែ៩ ១៩៧៦” ឯអ្នកចម្លងនេះ គេដាក់ថា “ចម្លងនៅថ្ងៃទី១៩ ខែ៩ ១៩៧៦” ដូច្នេះ អ្នកចម្លងក្រោយអ្នកសួរ នេះយើងសង្កេតមើលទៅឃើញបញ្ហានេះ ។ ឯកសារដែលនៅសល់នាំឲ្យយើងសង្កេត ដល់សង្កេតទៅ ខ្ញុំសង្កេតឃើញបញ្ហានេះ ។ សូមជម្រាបលោកចៅក្រមប៉ុណ្ណោះ ។

**ស៖** ខ្ញុំចង់ត្រឡប់ទៅលើការពន្យល់ដែលលោកបានផ្តល់ជូនយើងខ្ញុំ ប្រហែលជាខ្ញុំមិនសូវយល់ឲ្យច្បាស់លាស់កាលពីព្រឹកមិញ ។ លោកបានរៀបរាប់ថា ប្រសិនបើឈ្មោះរបស់លោកនៅលើឯកសារនេះ គឺដើម្បីបំពេញតម្រូវការ ការពេញចិត្តថ្នាក់លើរបស់លោក និងដើម្បីបញ្ជាក់ឲ្យច្បាស់លាស់ថា មានអ្នកសួរច្រើននៅក្នុងនេះ ។ នេះជាអ្វីដែលលោកបានលើកឡើងកាលពីព្រឹកមិញ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! លោកចៅក្រមយល់ហ្នឹង គឺត្រឹមត្រូវហើយ តាមពិតសួរតែម្នាក់ទេ ប៉ុន្តែ ដើម្បីស្របទៅតាមសំណូមពររបស់មេ ខ្ញុំសរសេរពីរនេះ ។

**ស៖** ដូច្នេះចំណុចនេះ គឺជាការភូតកុហក?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! មេបញ្ជាឲ្យខ្ញុំភូតកុហកអ៊ីចឹង ដើម្បីផ្ញើឯកសារនេះទៅបូព៌ា ដែលគេប្រើមនុស្សច្រើនសម្រាប់សួរមនុស្សម្នាក់ ។ សូមរំឭកថា ឯកសារដែលពួកបូព៌ាគេសួរ លីផែល ដដែលនេះ គេសួរគ្នាប្រាំបួននាក់ៗ ។ ដូច្នេះ ដើម្បីឲ្យវាមានរូបភាពមួយដូចគេ មេឲ្យខ្ញុំធ្វើអ៊ីចឹង ។

[១៤:១៨:១៨]

**ស៖** ដូច្នេះ ការអនុវត្តដែលសំខាន់នៅស-២១ គឺយ៉ាងហោចណាស់មានអ្នកសួរម្នាក់ ដែលគាត់ត្រូវសួរទៅលើអ្នកទោសមួយរូបដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! នៅស-២១ អ្នកសួរតែម្នាក់ទេ ជួនអីសួរមនុស្សពីរនាក់បីនាក់ផ្លាស់វេន ។ ខ្ញុំសូមជូនឧទាហរណ៍អ៊ីចេះ ដូចមិត្ត ប៉ុន អ៊ីចឹង ជួនអីគាត់សួរបង ម៉ែន សាន ហៅ យ៉ា ផង ។ ដល់គាត់សួរហើយ បង ម៉ែន សាន ហៅ យ៉ា សុទ្ធចិត្តឆ្លើយហើយ គាត់ឲ្យបង ម៉ែន សាន ហៅ យ៉ា សរសេរទៅ ។ ហើយនៅពេលដែលបង ម៉ែន សាន ហៅ យ៉ា សរសេរ គាត់ទៅសួរអ្នកណាមួយផ្សេងទៀតទៅ ។ នេះជារបៀបសួរចម្លើយនៅស-២១ អត់មានអ្នកសួរចម្លើយពីរនាក់ទៅសួរមនុស្សម្នាក់អត់មានទេ ។

[១៤:១៩:៥៥]

**ស៖** ចំពោះអ្នកសួរម្នាក់ដែលគាត់ទទួលខុសត្រូវសួរអ្នកទោសម្នាក់នោះ គឺដើម្បីជាប្រសិទ្ធភាពការងារ ឬក៏អត់មានអ្នកសួរចម្លើយគ្រប់គ្រាន់ ឬក៏វាពិបាកក្នុងការបង្ហាត់បង្រៀនអ្នកសួរចម្លើយ ឲ្យមានការបំពេញការងារល្អ?

**ឆ៖** លទ្ធភាពមួយ គឺប្រសិទ្ធភាពមិនដើរតួទេ ។ លទ្ធភាពពីរផ្សេងទៀត វាដើរតួ ។ គឺយើងខ្ញុំខ្វះអ្នកសួរ ដែលមានពិសោធន៍ អ្នកសួរតិច ។

**ស៖** ថាតើមានព្រឹត្តិហេតុ ឧប្បត្តិហេតុ កើតឡើងណាមួយដែរឬទេ ថាតើមានអ្នកទោសណាស្លាប់ក្នុងអំឡុងពេលសួរចម្លើយដែរឬទេ?

**ឆ៖** មានៗ ជាពិសេសមានអ្នកស្លាប់ ដោយសាររឿងរ៉ាំ ។

**ស៖** នាពេលនេះ យើងអាចឈប់បញ្ចាំងទៅលើឯកសារនេះហើយ ។ សូមអរគុណលោកស្ទីត។ ថាតើជំហររបស់លោកយ៉ាងម៉េចដែរ នៅពេលដែលមានព្រឹត្តិហេតុ និងឧប្បត្តិហេតុនោះកើតឡើងថាតើវាមានផលវិបាកអ្វីខ្លះ ក្រោយពីការមានការរំលោភផ្លូវភេទទៅលើអ្នកទោសស្ត្រីដែលត្រូវបានគេសួរចម្លើយនោះ? អ្នកបាននិយាយថា ជាលទ្ធផលក្រុមអ្នកសួរចម្លើយស្រីត្រូវបានរៀបចំនិងបង្កើតឡើងដែលអត់មានកាលពីមុន ហើយថាមានអ្វីកើតឡើងចំពោះអ្នកទោស អ្នកសួរចម្លើយទាំងអស់នោះ តើគេទទួលខុសត្រូវនូវអ្វី ដែលគេធ្វើឡើងនោះដែរឬទេ? ហើយតើលោកមានសុំឲ្យពន្យល់ទៅលើបញ្ហានេះដែរឬទេ? ហើយលោកមានការទណ្ឌកម្មលើបញ្ហានេះដែរឬទេ?

**ឆ៖** រឿងអ្នកសួរប្រុស ទៅមានការប៉ះពាល់លើរូបរាងកាយរបស់អ្នកគ្រូ ធ្វើឲ្យខ្ញុំមានការក្តុកក្តួលខ្លាំង ។ ក៏ប៉ុន្តែ ពេលនោះជំនាន់នោះ ខ្ញុំយល់ថា វាជាការល្មើសនឹងវិន័យសួរចម្លើយ វិន័យនៃការធ្វើទារុណកម្ម ។ ដូច្នេះខ្ញុំរាយការណ៍ជូនមេ រង់ចាំមេសម្រេច ។ ដោយមិនហ៊ានលើកសំណូមពរសុំចាប់ខ្លួនការដែលខ្ញុំមិនហ៊ានលើកសំណូមពរសុំចាប់ខ្លួននេះ ដើម្បីកុំឲ្យមេក៏ដូចជាកូនចៅខ្ញុំ ចាត់ទុកថាខ្ញុំជាមនុស្សបុគ្គល ។ គ្រូរបស់ខ្លួនឯងមកជាប់ទោសហើយ នៅឡូយទៀត គេប៉ះមិនបាន អាហ្នឹងខ្ញុំខ្លាចគេជៀលខ្ញុំអ៊ីចឹងបានជាខ្ញុំអត់ហ៊ានស្នើទៅមេ ។ ដល់មេមិនថាម៉េចខ្ញុំក៏មិនហ៊ានស្នើសុំ ហើយគ្រាន់តែស្នើសុំដេញអាមនុស្សនោះចេញមិនឲ្យសួរចម្លើយស្រីៗ ហើយបង្កើតអ្នកសួរចម្លើយប្រុសជំនួស ។

នេះជាការយល់ដឹង ហើយនិងសកម្មភាពដែលខ្ញុំបានចាត់ចែងនៅពេលនោះ វាស្របគ្នានឹងការយល់ដឹងពេលនោះដែរ ។ សូមជម្រាបលោកចៅក្រមប៉ុណ្ណោះ ។

[១៤:២៦:០០]

**ស៖** ព្រឹកមិញនេះលោកក៏បានរៀបរាប់ថា ពីពេលមួយទៅពេលមួយ លោកបានរៀបរាប់នូវអ្វីដែលលោកបានលើកឡើង គឺលោកជូនដំណឹងទៅដល់ថ្នាក់លើរបស់លោក ។ នៅពេលដែលលទ្ធផលនៃការធ្វើទារុណកម្មនាំឲ្យមានការស្លាប់ ថាតើដូច្នេះដែរឬទេ? លោកមានការបិទបាំង បិទបាំងការស្លាប់អ្នកទោសដូច្នោះ ហើយលោកបានបិទបាំងទៅលើបញ្ហានេះ ដូចដែលលោកបានរៀបរាប់ចំពោះបញ្ហានៃការរំលោភប៉ះពាល់លើរូបរាងកាយនោះផងដែរ?

**ឆ៖** បើយើងមើលរូបភាព លោកចៅក្រមជាទីគោរព! មិនខុសគ្នាប៉ុន្មានទេ។ ខុសតែមិនខុសប៉ុន្មានទេ ។ ក៏ប៉ុន្តែ--

**ស៖** ខ្ញុំអត់ស្តាប់ឮការបកប្រែតាមរយៈកាសទេ ហើយខ្ញុំមិនដឹងថាមានបញ្ហាអ្វីទេ ប្រហែលលោកអាចនិយាយសាឡើងវិញ ប្រហែលវាទាក់ទងទៅនឹងបញ្ហាបច្ចេកទេសតែប៉ុណ្ណោះនៅទីនេះ។ ចម្លើយរបស់លោកមិនទាន់បានបកប្រែជាភាសាបារាំងនោះទេ ហើយខ្ញុំមិនដឹងថាតើបកប្រែជាអង់គ្លេស ហើយឬនៅទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! កំហុសរបស់អ្នកសួរចម្លើយទាំងពីរនេះ បើមើលជារូបភាពមិនខុសគ្នាពេកទេ ។ ក៏ប៉ុន្តែ បើនិយាយពីចិត្តខ្ញុំ ដែលក្តុកក្តួលនៅពេលនោះ ខ្ញុំក្តុកក្តួលជាមួយនឹងអ្នកគ្រូខ្លាំងជាង ។ តែខ្ញុំមិនហ៊ានច្រឡោត ខ្ញុំគ្រាន់តែដកមិនឲ្យសួរអ្នកគ្រូហ្នឹងតទៅទៀត មិនឲ្យសួរស្រីៗតទៅទៀត អាមនុស្សនុ៎ងនោះ ។ ឯចំណែក អ្នកសួរចម្លើយប្រុស ខ្ញុំអត់នេះទេ វាថ្លោះធ្លោយការងារគ្រាន់ តែប្រាប់មួយម៉ាត់ពីរ ហើយឲ្យគេសង្ខេបចម្លើយ ដែលអ្នកស្តាប់ទៅនោះឆ្លើយឲ្យបានស្រួលបួល ហើយខ្ញុំសរសេរសេចក្តីវាយការណ៍មួយទៅលើ ។ ដូច្នេះ មួយដែលថ្លោះធ្លោយវៃស្លាប់ដាច់ចម្លើយ ខ្ញុំបង្ហាញពីភាពអនុគ្រោះរបស់ខ្ញុំដល់គេ ខ្ញុំអនុគ្រោះ ។ ឯចំណែក អ្នកសួរចម្លើយដែលទៅរំលោភលើរាងកាយអ្នកគ្រូ ខ្ញុំច្រឡោត តែខ្ញុំខំទប់ ដើម្បីកុំឲ្យមេគាត់វាយតម្លៃខ្ញុំ កូនចៅខ្ញុំក៏វាយតម្លៃខ្ញុំដូច្នេះខុសគ្នា ។

**ស៖** លោកបាននិយាយអំពីកំហឹង ភាពក្តុកក្តួល ប៉ុន្តែ នៅមុនដំបូង នៅដើមដំបូងនៃសវនាការគឺលោកនិយាយអំពីវិប្បដិសារី ។ ប្រភេទនៃវិប្បដិសារីនោះតើវាកើតឡើងនៅក្នុងទម្រង់បែបណា? តើលោកមានអារម្មណ៍វិប្បដិសារីនៅពេលក្រោយ ហើយនិងលោកមានអារម្មណ៍ខឹងសម្បានៅពេលមុនឬក៏យ៉ាងម៉េច?

**ឆ៖** និយាយអំពីការតូចចិត្ត ឮភ្លាមច្រឡោតភ្លាម ។ ឯចំណែក ការសោកស្តាយវាកើតក្រោយមកថែមទៀតទេ ។ នេះខ្ញុំសូមបញ្ជាក់ជូន តាមការផ្ទុះបញ្ចាំងឡើងវិញនូវសតិអារម្មណ៍ជំនាន់នោះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំអត់មានសំណួរអ្វីទៀត សម្រាប់សួរជនជាប់ចោទទេ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីសួរដល់ជនជាប់ចោទដែរឬទេ?

សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

**ស៖** សូមអរគុណលោកប្រធាន ។ កាំង ហ្កេកអ៊ាវ លោកបានជម្រាបប្រាប់ពួកយើងថា លោកបានបង្រៀនអ្នកសួរចម្លើយនូវរបៀបសួរចម្លើយ ដើម្បីទទួលយកបាននូវចម្លើយសារភាព ។ នៅក្នុងចម្លើយសារភាពជាច្រើន គឺមានការនិយាយយោងទៅលើសមាជិក ដែលជាសមាជិករបស់ *កាហ្សេប* ឬក៏ *សេអ៊ីអា* ហើយនិង អង្គការផ្សេងៗទៀត ។ តើលោកមានបានបង្រៀនអ្នកសួរចម្លើយនូវរបៀបទទួលយកបាននូវចម្លើយសារភាពដែលអ្នកទោសនោះ គឺជាសមាជិករបស់អង្គការប្រភេទនេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ពាក្យ *"សេអ៊ីអា"* នេះ ថាយើងខ្ញុំប្រាប់ក៏ថាបាន ។ មួយរយៈដំបូងយើងខ្ញុំឮអ្នកឆ្លើយហ្នឹង គេឆ្លើយក្បត់បដិវត្តន៍ ប្រឆាំងបដិវត្តន៍ ពេលមួយនោះលោកគ្រូ សុន សេន មេខ្ញុំហៅខ្ញុំទៅធ្វើការទាំងពីរនាក់ ណាត ។ អង្កាល់នោះនៅ ណាត ធ្វើប្រធានទេ។ ទៅដល់គាត់លើកក្រដាសមួយសន្លឹករើកៗ គាត់ថា នគរបាលតំបន់៣២ គេរកឃើញ *សេអ៊ីអា* ណ៎ា ន៎ែគេចារមកគេអត់មានវ៉ើផង ថាគេ អាន៎ុងវាឆ្លើយសារភាពថា *សេអ៊ីអា* ។ ឥឡូវគេរកឃើញ *សេអ៊ីអា* ម៉េចក៏ស-២១ រកមិនឃើញ *សេអ៊ីអា* សោះ វាយ៉ាងម៉េច អ្ហ៎ះ! មើ! និយាយ មើ! ខ្ញុំ ហើយនិង ណាត អត់ហើបមាត់រួចទេ បង្ហាញក្រដាសមក ក៏គាត់មិនបង្ហាញ គាត់ប្រាប់ថា *សេអ៊ីអា* មិនដូចយើងទេណា ចូលម្តងអាយុស ។ ហើយគាត់និយាយតទៅទៀត គាត់ថា *សេអ៊ីអា* តែជ្រមុជទឹកម្តងហើយ ចប់ហើយ វានៅជា *សេអ៊ីអា* បែកគ្នាប៉ុន្មានខែប៉ុន្មានឆ្នាំក៏វានៅតែអ៊ីចឹង ។ ឯចំណែក យើងចូលបក្ស តែដាច់ជីវភាពបក្ស៦ខែគឺដាច់ហើយ បេក្ខភាព សមាជិកភាពរបស់បក្ស ដល់គាត់និយាយអ៊ីចឹងមក ខ្ញុំគិតថា អ្ហ៎! ច្របូកច្របល់ហើយ ប៉ុនឥឡូវគេតម្រូវឲ្យរក *សេអ៊ីអា* ទៅហើយ ច្របូកច្របល់នឹងពួកគ្រឹស្មៀនហើយ ។ ប៉ុនមិនដឹងធ្វើម៉េច បើគេតម្រូវឲ្យឆ្លើយ *សេអ៊ីអា* អ៊ីចឹង ខ្ញុំក៏មកប្រកាសប្រាប់ក្នុងអង្គភាពអ្នកសួរ អំពីមេធ្វើអ៊ីចេះៗៗប្រាប់អ៊ីចេះៗ មែន *សេអ៊ីអា* ព្រោងព្រាត សួន កាសេត ទៅ *សេអ៊ីអា* មេគង្គ ។ សួន កាសេត គាត់នៅគណកម្មាធិការទំនប់មេគង្គ *សេអ៊ីអា* មេគង្គ ។ ហើយអ្នកខ្លះធ្វើការនៅក្នុងអង្គការយែរ ទៅជា *សេអ៊ីអា យែរ* ទប់មួយសារទៅ ឲ្យតែថា *សេអ៊ីអា* ទទេបានហើយ កុំ *សេអ៊ីអា យែរ, សេអ៊ីអា* មេគង្គអី ទប់ទៅ ។ ដល់ក្រោយ ជនជាប់ចោទម្នាក់ឈ្មោះ ជនរងគ្រោះម្នាក់ឈ្មោះ លាវ សុតសុភ័ណ្ឌាថាគាត់ទៅរៀននៅសហភាព ន៎ែៗ (សុំទោស) ជនរងគ្រោះម្នាក់ឈ្មោះ ហាក់ សៀងឡាយនី គាត់ជាវិស្វករនៅសូវៀត ។ មកដល់គាត់ថា គាត់ *សេអ៊ីអា* បណ្តុះបណ្តាលដោយសូវៀត ខ្ញុំរាយការណ៍ទៅ

លើ ។ ទេ! សូវៀត ម៉េច*សេអ៊ីអា* ឌុច! មិត្តឯងសួរវាឲ្យច្បាស់មើលស្អី ។ ដល់ទៅ ហាក់ សៀងឡាយនីណាប្រាប់មថា អ្ហ៎! សូវៀតគេហៅ *កាហ្សេបេ* ហើយគេប្រើអីទៀត *កាហ្សេបេ* បើប្រែមកជាភាសាបារាំង គេហៅថា *កុំមីតេ ហ្គោវែកម៉ង់តាល់ ដឺរ៉ែងសែងម៉ង់* ។ ខ្ញុំក៏ចាំទៅៗដល់ទៅ។ ដូច្នេះ អ្នកណាឲ្យតែរៀននៅសូវៀត *កាហ្សេបេ* ហើយផ្សេងពីនោះ *សេអ៊ីអា* ដល់ក្រោយមកបក្សលើកពាក្យស្លោកមួយ ភ្នាក់ងារយួនលេបទឹកដីប្រល័យពូជសាសន៍ ។ ហ្នឹងចែកសំណុំមនុស្សជាបីចំណែកអ៊ីចឹង តាមគោលការណ៍ដែលបក្សណែនាំ ។ ដូច្នេះ សំណួរទៅថា *សេអ៊ីអា, កាហ្សេបេ*ស្អីៗហ្នឹង គឺជាសំណួរដែលអ្នកសួរនៅស-២១ តម្រង់ទិស ។ នេះសូមជម្រាបលោកជំទាវ ដោយស្មោះត្រង់ប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ ដូច្នេះ លោកបានបញ្ជាក់ថា ជាផ្នែកមួយនៃការណែនាំ ដល់អ្នកសួរចម្លើយនោះ គឺស្នើប្រាប់ពួកគេថា អ្នកទោសអស់ទាំងហ្នឹង គឺជាសមាជិកនៃអង្គការណាមួយក្នុងចំណោមអង្គការអស់ទាំងនេះ ឬក៏អាចជាយួនឈ្លានពានទឹកដី ។ នោះគឺជាអ្វី ដែលគេបានលើកឡើងចំពោះមុខអ្នកជាប់ទោសមែនទេ?

[១៤:៣៨:២៨]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! របៀបសួរ អាហ្នឹងវាអ៊ីចឹង ប៉ុន្តែតម្រង់ទិសយើងខ្ញុំរៀបចំបង្ហាត់បង្រៀនគេឲ្យយល់បញ្ហាអ៊ីចឹង វាប្លែកគ្នា ។ នេះបច្ចេកទេស គេបង្ហាញឲ្យអ្នកទោសឆ្លើយអាម៉េចៗ អាហ្នឹងបច្ចេកទេសរបស់គេម្នាក់ៗ ។ ឯចំណែក ទិសរួមដែលយើងខ្ញុំកំណត់បីប្រភេទហ្នឹង ។

**ស៖** ហើយជាការត្រឹមត្រូវណាស់ឬដែលគួរឲ្យភ្ញាក់ផ្អើលណាស់ ពីព្រោះអីអ្នកទោសភាគច្រើននោះគឺបានសារភាពថា ពួកគេជាសមាជិករបស់ *កាហ្សេបេ* និង ជាសមាជិករបស់ *សេអ៊ីអា* នោះ ?

**ឆ៖** រឿងភ្ញាក់ផ្អើល បើយើងយកសេចក្តីពិតទៅវិភាគច្បាស់ជាភ្ញាក់ផ្អើលហើយ ព្រោះតាមពិតអ្នកដែលហៅថា *សេអ៊ីអា* មែនទែន ទាល់តែភ្នាក់ងាររបស់ *សេអ៊ីអា* ដែលគ្រប់គ្រងដោយការិយាល័យ *សេអ៊ីអា* នៅអាមេរិក ។ ក៏ប៉ុន្តែ នេះអត់ទេ ឲ្យតែឆ្លើយថា *សេអ៊ីអា* គឺ*សេអ៊ីអា* ហើយ នេះគឺវាច្បាស់អ៊ីចឹង ។ នេះសូមជម្រាបបញ្ជាក់លោកជំទាវអ៊ីចឹង ថាវាភ្ញាក់ផ្អើលមែន ចំពោះអ្នកចេះ អ្នកដឹង អ្នកដែលយល់ ឯចំពោះអ្នកមិនយល់ទៅហើយ ទាំងអស់តែគ្នាហ្នឹង ។ ឯចំណែក យើងខ្ញុំដែលកាន់កាប់កិច្ចការហ្នឹង មិនមែនមិនយល់ទេ ក៏ប៉ុន្តែធ្វើម៉េច រឿងនេះ វាត្រូវតែទៅតាមនុ៎ង ។

**ស៖** ហើយពីមុន លោកក៏បាននិយាយដែរថា លោកមិនបានជឿថា ព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពនោះ គឺមិនសូវពិតទេ ។ តើលោកដែលជឿដែរថា អ្នកទោសភាគច្រើននោះ ជាសមា-

ជិករបស់ *កាហ្វេបេ* ឬក៏របស់ *សេអ៊ីអា* ឬ?

**ឆ៖** អ្នកទោសទាំងអស់ហ្នឹង បើតាមខ្ញុំសរុបមើលទៅដូច ស្ងួន កាសេត ដូច លាវ សុតសុភ័ណ្ឌថា អីៗអីចឹង ដែលឆ្លើយថាខ្លួនឯងជា *សេអ៊ីអា* ណាំ ជាពិសេស ជូឡុង រង្សី នេះ ។ មិនមែនទេ ដំបងដាក់គ្នាហើយ គ្នាស្រីផង ទៅហើយ ។ ដូច្នេះ គឺពិតជាខុស ។ ពិតជានិយាយទាំងបង្ខំ ។

**ស៖** នៅពេលដែលលោកនិយាយថា ពួកគេត្រូវបានគេបង្ខំឲ្យនិយាយដូច្នោះ គឺមកពីអ្នកសួរចម្លើយនោះគេបានលើកសំណួរឡើងរបៀបហ្នឹងឬ ហើយមកពីពួកគេត្រូវបានទទួលការធ្វើទារុណកម្មផងនោះមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ ។ រឿងហ្នឹងពិត ។ ក៏ប៉ុន្តែ ទិសតម្រង់ឲ្យដៅ*សេអ៊ីអា* ហ្នឹងមិនមែនត្រឹមខ្ញុំទេ វាតាំងពីលើមក ក៏ប៉ុន្តែការអនុវត្តនៅស-២១ គឺវាពិតអីចឹង ដូចលោកជំទាវមានប្រសាសន៍សួរខ្ញុំអីចឹង ។

[១៤:៤១:៥៥]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោកប្រធាន ខ្ញុំមានសំណួរពីរបីទៀត ក៏ប៉ុន្តែខ្ញុំយល់ថា ឥឡូវនេះប្រហែលជាដល់ពេលដែលយើងត្រូវឈប់សម្រាកបន្តិចហើយ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម ។ ឥឡូវហ្នឹង យើងដល់ម៉ោងត្រូវសម្រាក ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងបី យើងចាប់ផ្ដើមបន្តដំណើរការ នីតិវិធីសវនាការយើងបន្តទៅទៀត ។

*[សវនាការសម្រាកពីម៉ោង ១៤:៤២នាទី ដល់ម៉ោង ១៥:០៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការដេញដោលតទៅទៀត ហើយជាកិច្ចបន្តនេះ សូមជូនភារៈនេះជូនទៅលោកស្រីចៅក្រម ខាតវ៉ាយថ៍ ដើម្បីបន្ត ការតាំងសំណួរដល់ជនជាប់ចោទ ។ សូមអញ្ជើញលោកស្រី ។

**សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយថ៍៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោក កាំង ហ្គេកអ៊ាវ កាលពីម្សិលមិញ យើងបានពិភាក្សាដេញដោលអំពីបញ្ជីកូនក្មេងតូចៗដែលត្រូវបានកំណត់ថា ត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅស-២១ គឺបញ្ជីលេខE68.7 ដែលមានលេខ ERN00331257 ហើយលោកបានយល់ស្របថា ចំនួនភាគច្រើននៃកូនក្មេងទាំងអស់នោះ គឺមានអាយុចាប់ពី១៥ឆ្នាំដល់១៨ឆ្នាំ ។ តើលោកចាំទៅលើចំណុចនេះដែរ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំនៅចាំ ។ សូមអរគុណ ។

**ស៖** លោកក៏បានប្រាប់ខ្ញុំដែរ យ៉ាងហោចណាស់បញ្ជីមួយចំនួននេះ-- កូនក្មេងមួយចំនួននេះត្រូវបានចាប់ដោយសារតែបទល្មើសដែលពួកគេប្រព្រឹត្ត ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវ ។

**ស៖** ដូច្នេះ តើវាជាការត្រឹមត្រូវចំពោះខ្ញុំក្នុងការសន្និដ្ឋានថា ក្មេងៗទាំងអស់នោះក៏ត្រូវបានរងទារុណកម្មដើម្បីធ្វើយ៉ាងណាទាញចម្លើយពីពួកគេផងដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! រឿងនេះពិត រួចខ្លួនតិចណាស់ពីទារុណកម្ម ។ សូមទទួលប៉ុណ្ណឹង ។

**ស៖** ហើយលោកមិនមានការអនុវត្តគោលនយោបាយណាមួយក្នុងនាមលោកជាប្រធានស-២១ ដើម្បីរារាំងកុំឲ្យមានការធ្វើទារុណកម្មដល់កូនក្មេង ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, លោកជំទាវ ខ្ញុំអត់បានរារាំងមែន ។ សូមទទួល ។

**ស៖** កាលពីម្សិល យើងក៏បានធ្វើការពិនិត្យឡើងវិញដោយសង្ខេបលើបញ្ជីទាក់ទងទៅនឹងស្ត្រីដែលត្រូវបានគេឃុំខ្លួននៅស-២១ ដែលមានចំនួនសរុប ១៦៩៨នាក់ ដែលជាស្ត្រី គឺឯកសារលេខE68.6 ដែលចាប់ផ្តើមលេខERN នៅក្នុងលេខ00331192 ។ ហើយលោកបានជម្រាបប្រាប់ខ្ញុំថាចំនួនភាគច្រើននៃស្ត្រីទាំងអស់នោះ ត្រូវបានចាប់ខ្លួនដោយសារតែពួកគេមានទំនាក់ទំនងជាមួយអ្នកទោសប្រុសដែលត្រូវបានចាប់ខ្លួននិងឃុំខ្លួន ។ ហើយស្ត្រីទាំងអស់នោះគឺមិនបានប្រព្រឹត្តិកំហុសអ្វីទេ ។ តើត្រឹមត្រូវដែរឬទេ?

[១៥:០៨:២៧]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវហើយ ។

**ស៖** ផ្អែកទៅលើអ្វីដែលលោកទើបតែបានលើកឡើងនេះថា តើលោកមានការសោកស្តាយចំពោះស្ត្រី ដែលមិនមានការប្រព្រឹត្តិខុសហើយត្រូវបានគេយកមកធ្វើទារុណកម្មដើម្បីទាញយកចម្លើយសារភាព

នោះដែរឬទេ?

**ឆ៖** រឿងវាហួសទៅហើយមិនដឹងធ្វើម៉េចទេ ។ រឿងនិយាយថាសោកស្តាយហ្នឹងវាហួសពីនិយាយទៅហើយ ។ ឧក្រិដ្ឋកម្មទៅលើប្រជាជនរាប់ម៉ឺននាក់ៗនៅស-២១ ខ្ញុំទទួល អត់ប្រកែកទេ ។

**ស៖** ដូច្នេះ លោកយល់ស្របជាមួយនឹងសំណួររបស់ខ្ញុំ ។ តើមានដែរឬទេ? ស្ត្រីទាំងអស់នោះ គឺត្រូវបានរងទារុណកម្មដើម្បីទាញយកចម្លើយពីពួកគេ ។

**ឆ៖** ប្រាកដ ។ ជាពិសេសស្ត្រីណាដែលមានមុខងារក្នុងបក្សកុម្មុយនីស្តកម្ពុជាហើយនិងក្នុងរដ្ឋាភិបាល ហើយចំណែកឯស្ត្រីជាប្រពន្ធច្រើនអាចរួចខ្លួនខ្លះ មានខ្លះអាចរួចខ្លួនមែន ហើយយកទៅកម្ទេចទាំងមិនបានសួរ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។ សូមអរគុណ ។

**ស៖** គ្រូដែលយើងបានលើកឡើងនោះ អ្នកគ្រូដែលយើងបានលើកឡើងនោះគឺ ឌឹម សារឿន ថាតើជាស្ត្រីត្រូវបានគេសង្ស័យថា បានប្រព្រឹត្តការធ្វើខុសអ្វីមួយដែរឬទេ?

**ឆ៖** បើតាមខ្ញុំចាំ អ្នកគ្រូខ្ញុំគាត់ជាបក្ខជនម្នាក់ នេះពិត ។ ដូច្នេះ ខ្ញុំអត់បានមើលសំណុំរឿងនេះទោះបានមើលក៏មិនចាំដែរ ភ្លេចអស់ហើយ ។ ដូច្នេះ ខ្ញុំអាចសន្និដ្ឋានថា គាត់មានការចោទប្រកាន់មួយដាច់ដោយឡែកពីលោកគ្រូ កែ គឹមហួត ។ សូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** លោកបានលើកឡើងព្រឹកមិញថា ជាទូទៅអ្នកសួរចម្លើយម្នាក់តែប៉ុណ្ណោះ ដែលជាអ្នកសួរចម្លើយលើអ្នកទោសនិងធ្វើទារុណកម្មលើអ្នកទោស ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវ ។

[១៥:១១:២៧]

**ស៖** ដូច្នេះ តើលោកអាចពន្យល់ជូនខ្ញុំដែរឬទេ ថាលោកដឹងយ៉ាងម៉េច? ថាលោកដឹងតាមរបៀបណា ដែលថា វិធីសាស្ត្រទារុណកម្មត្រូវបានធ្វើឡើងដោយអ្នកសួរចម្លើយម្នាក់ដើម្បីទាញយកចម្លើយនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! កន្លែងសួរចម្លើយខ្ញុំមិនចុះទៅមែន ក៏ប៉ុន្តែការគ្រប់គ្រងវាទៅតាមខ្សែចាត់តាំង ។ អំណាចទាំងអស់វាប្រមូលផ្តុំមកខ្ញុំ ក៏ប៉ុន្តែខ្ញុំរែកការងារគ្រប់បែបយ៉ាងទៅមិនរួចទេ វាមានអ្នកគេជួយពីក្រោម ។ ជាពិសេស ខ្ញុំសង្ឃឹមលើមិត្តហ៊ី ហ្នឹងឯង ដែលគាត់អាចដើរបានហួរហែមានសិទ្ធិអំណាចពេញពាស ដូច្នេះ ខ្ញុំអាចដឹងតាមនុ៎ង ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ សូមជ្រាប ។

**ស៖** ប្រសិនបើមានអ្នកសួរចម្លើយតែម្នាក់នៅក្នុងបន្ទប់ ដែលអ្នកទោសត្រូវបានយកមកសួរចម្លើយនោះថា តើ ហ៊ី គាត់ដឹងគេប្រើវិធីសាស្ត្រធ្វើទារុណកម្មយ៉ាងម៉េចនៅក្នុងបន្ទប់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! គោលការណ៍មាន បើកដៃឲ្យធ្វើទារុណកម្ម យើងមិនឃាត់ទេ សំណូមពរដូចខ្ញុំជម្រាបជូនលោកចៅក្រម ឡាវែន៍ អម្បាញ់អ៊ីចឹង ។ ក៏ប៉ុន្តែ ធ្វើម៉េចកុំឲ្យតែស្លាប់ ហើយធ្វើម៉េចកុំឲ្យតែទុរន់ទុរាស្សរមិនកើត ។ ដូច្នេះ កាលណាដល់ទៅមើលទៅឃើញយ៉ាងម៉េច អីយ៉ាងម៉េច? គេដើរមើលយូរៗម្តងទៅហើយគេជួយណែនាំទៅតាមនុ៎ង ។ ដូច្នេះ គោលការណ៍គឺម្នាក់សួរម្នាក់ទទួលខុសត្រូវខ្លួនឯង សម្រាប់ចម្លើយត្រូវព្រមានឬយ៉ាងម៉េច? ត្រូវយ៉ាងម៉េច? អាហ្នឹង វាជាគោលការណ៍ ដូច្នេះម្នាក់ៗទទួលខុសត្រូវខ្លួនឯង សមូហភាពត្រួតត្រាពីលើដឹកនាំគ្រប់គ្រងពីលើ ។ នេះប៉ុននុ៎ងសូមជម្រាបបញ្ជាក់ ។

**ស៖** ដូច្នេះ លោកនិងហ៊ី មិនបានដឹងច្បាស់លាស់ថា តើវិធីសាស្ត្រទារុណកម្មមួយណាដែលត្រូវបានគេប្រើនោះទេ លើកលែងតែអ្នកសួរចម្លើយគេពន្យល់ទៅលោកនិងហ៊ី ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ឲ្យដឹងជាក់ស្តែងគ្រប់ពេលវេលាមិនដឹងទេ ក៏ប៉ុន្តែយើងសរុបជារួមបាន ។ គាត់ទៅលើកំពុងតែវ៉ៃ គាត់ទៅឃើញគេកំពុងតែឆក់ខ្សែភ្លើង ឧទាហរណ៍អ៊ីចឹង ។ ដូច្នេះ អាចយើងសន្និដ្ឋានមនុស្សបានប្រភេទទារុណកម្មបាន ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** នៅក្នុងអង្គហេតុដែលបានព្រមព្រៀងគ្នា លោកបានទទួលស្គាល់ថា លោកបានដឹងអំពីការអនុវត្តនៃការយកម្ជុលចាក់និងការដកក្រចកដៃក្រចកជើង ។ នេះគឺជាទម្រង់បន្ថែមមួយទៀតនៃការធ្វើទារុណកម្មលើទម្រង់ចំនួនបួនដែលលោកបានបង្គាប់អ្នកសួរចម្លើយឲ្យអនុវត្ត?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ទម្រង់ធ្វើទារុណកម្មបួនដែលយើងខ្ញុំដាក់នោះមានគេធ្វើលើសច្រើនបែបដែរ ។ ទម្រង់ថ្វាយបង្គំរូបឆ្កែ គេធ្វើលើសទេ ដំបូង ដល់ក្រោយមកយើងខ្ញុំអនុម័តទទួលទម្រង់នេះមួយទៀត ។ ចំណែកទម្រង់ដកក្រចកដៃនេះឮល្បីដល់ខ្ញុំត្រឹមតែថាយកបុាំងទាញក្រចកៗ ។ នេះមិត្តហ៊ី មករាយការណ៍ឲ្យខ្ញុំ ។ ខ្ញុំកំហែង មាននិយាយឲ្យត្រង់ខ្ញុំកំហែងថា ហ្នឹងដកក្រចកគេហើយហ្នឹង ឈប់ឲ្យឆាប់តែមិនឈប់រាយការណ៍ណា! មិត្តហ៊ីថា ទេ! អត់ទេ! ទាញក្រចកទេ! ។ ខ្ញុំជឿថាវាដកក្រចកទៅហើយ ។

ដូច្នេះ រឿងដកក្រចកនេះជាទម្រង់មួយទៀតដែលកើតឡើងមួយភ្លែត ពិតជាកើតឡើងរួចទៅហើយ ។ ខ្ញុំមិនបដិសេធទេ មានជនរងគ្រោះដោយសាររឿងដកក្រចកនេះក៏ពិតជាមាន ។ ក៏ប៉ុន្តែ ជាទម្រង់មួយដែលវាស្ងប់ទៅវិញ ក្រោយមកវាស្ងប់ទៅវិញដោយខ្ញុំកំហែង ។ ដូច្នេះ ទម្រង់ពីរនេះ មួយខ្ញុំអនុគ្រោះគឺថ្វាយបង្គំរូបឆ្កែ មិនមែនគ្រាន់តែអនុគ្រោះទេ គឺអនុញ្ញាតឲ្យធ្វើហើយជំរុញរៀបចំលក្ខណ:

សម្បត្តិឲ្យធ្វើបានស្រួលទៀត ឯទម្រង់ការដកក្រចកនេះ ខ្ញុំបញ្ឈប់ ។

[១៥:១៧:១៧]

**ស៖** សូមអរគុណ ។ នៅក្នុងអង្គហេតុដែលបានព្រមព្រៀងគ្នានៅកថាខណ្ឌ២៣១ លោកបានយល់ស្របមួយផ្នែកទៅនឹងចម្លើយដែលបានលើកឡើងថាមានការប្រព្រឹត្តចំណុចមួយនៅស-២១ ហើយលោកបានពន្យល់ថា មានករណីមួយនោះគឺមានការរំលោភ ។ ថាតើលោកនៅចងចាំទៅលើផ្នែកក្នុងអង្គហេតុដែលបានព្រមព្រៀងគ្នានេះដែរឬទេ?

**ឆ៖** ខ្ញុំមិនចាំទេ ជម្រាបប្រសាសន៍ សូមអ្នកស្រីបញ្ជាក់ឲ្យច្បាស់មករំលោភអាម៉េច?

**ស៖** គឺចម្លើយដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយបានលើកឡើងថាការរំលោភសេពសន្ថវៈបានធ្វើឡើងនិងប្រព្រឹត្តឡើងនៅស-២១ ។ ចម្លើយតបទៅនឹងចំណុចនេះរបស់លោកៗបានលើកឡើងថាលោកយល់ព្រមមួយផ្នែក ។ ហើយលោកបន្តពន្យល់ថា យោងតាមលោកគឺមានករណីនៃការរំលោភសេពសន្ថវៈតែមួយដងតែប៉ុណ្ណោះ ។ តើច្បាស់ទេ ចំពោះករណីនេះចំពោះលោក?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! រឿងនេះគឺរឿងអ្នកគ្រូ ឌឹម សារឿន ហ្នឹងឯង ។ យើងខ្ញុំសូម្បីតែមេធាវីយើងខ្ញុំក៏ប្រើពាក្យខុសគ្នាដែរ ជាពាក្យខ្មែរមេធាវី ការ សាវុត្ថ លោកប្រើថា "*រំលោភលើរូបរាងកាយ មិនមែនរំលោភលើសេពសន្ថវៈទេ*" ព្រោះគ្នាគ្រាន់តែយកឈើទៅស៊កនៅក្នុងប្រដាប់ភេទ ។ ដូច្នេះ សរុបមកវិញ ខ្ញុំមិននិយាយវែងឆ្ងាយទេ ករណីរំលោភបែបនេះមានតែម្តងគត់នៅស-២១ គឺអ្នកសួរចម្លើយប្រុសយកឈើទៅដាក់ក្នុងប្រដាប់ភេទស្ត្រីម្នាក់គឺអ្នកគ្រូ ឌឹម សារឿន មានតែម្តងនុ៎ងគត់ ។ នេះគឺសូមបញ្ជាក់ដោយស្មោះត្រង់ជូនលោកជំទាវប៉ុណ្ណោះ ។

[១៥:១៩:៣៧]

**ស៖** សូមអរគុណ ។ ហើយលោកក៏បានពន្យល់ផងដែរថា មេរបស់លោកហ្នឹងមិនបានដាក់ពិន័យទៅលើអ្នកសួរចម្លើយ ឬក៏បញ្ជាឲ្យដាក់ទណ្ឌកម្មទៅលើអ្នកសួរចម្លើយនោះទេ ។ ហើយតាមពិតអ្នកសួរចម្លើយហ្នឹងគឺកម្រត្រូវបានទទួលពិន័យណាស់បើសិនជាមាននោះ សម្រាប់ការប្រើទម្រង់ផ្សេងៗនៃការធ្វើទារុណកម្ម ។ តើអ្វីដែលលើកឡើងនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! រឿងករណីទូទៅត្រឹមត្រូវ ។ ក៏ប៉ុន្តែរឿងករណីចំពោះអ្នកគ្រូ ឌឹម សារឿន បើសិនជាខ្ញុំបាទយល់ច្បាប់ច្បាស់លាស់ថា បែបនេះជាការរំលោភលើផ្លូវភេទ ខ្ញុំអត់ទុកទេ ខ្ញុំស្នើៗសុំមេចាប់មនុស្សម្នាក់នេះដាក់គុកហើយ ។ ខ្ញុំអត់ទុកទេករណីមួយនេះ ប៉ុន្តែ កាលនោះ

ខ្ញុំអត់យល់ នេះជម្រាបលោកជំទាវដោយស្មោះត្រង់ចុះ ។

**ស៖** ប្រសិនបើមានអ្នកសួរចម្លើយតែម្នាក់នៅក្នុងបន្ទប់ជាមួយនឹងអ្នកទោសដែលត្រូវសួរចម្លើយនោះ ហើយប្រសិនបើអ្នកសួរចម្លើយដែលនឹងមិនត្រូវទទួលទារុណកម្ម ឬក៏ពិន័យចំពោះការធ្វើទារុណកម្មដែលលោកមិនយល់ស្របនោះ ។ តើលោកធ្វើដូចម្តេចនឹងអាចប្រាកដថា មិនមានឧប្បត្តិហេតុបែបនេះកើតមានទេដូចជាការរំលោភរាងកាយ ឬក៏រំការរំលោភផ្លូវភេទនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ការបណ្តោយម្នាក់ទល់នឹងម្នាក់នេះ ខ្ញុំពិតជាបានបណ្តោយមែន មិនស្មានថា រឿងវាទៅដល់ប៉ុននុ៎ង ព្រោះម្នាក់ៗសុទ្ធតែខ្លាចជីវិតស្លាប់បង់ដែរ ។ ដល់រឿងវាទៅដល់ប៉ុននុ៎ង វាត្រូវតែរកវិធានការណាមួយឲ្យសមស្រប។ នៅពេលនោះខ្ញុំបាទយល់ឃើញថាវិធានការដែលសមស្រប គឺដកអាមនុស្សនេះឈប់ឲ្យសួរមនុស្សស្រី មិនមែនសួរត្រឹមអ្នកគ្រូខ្ញុំនុ៎ងទេ គឺឈប់ឲ្យសួរមនុស្សស្រី ហើយរកកម្មាភិបាលស្រីមកជំនួសវិញ ។ នេះវិធានការដែលពេលនោះ ខ្ញុំយល់ត្រឹមកម្រិតនោះ ហើយខ្ញុំយល់ថាជាវិធានការដែលសមស្រប ។ ដូច្នេះសូមសរុបជូនប៉ុណ្ណឹង ។

**ស៖** ប៉ុន្តែ នេះមិនមែនសំណួររបស់ខ្ញុំទេ ។ សំណួររបស់ខ្ញុំគឺថា តើធ្វើម្តេចទៅដែលលោកអាចប្រាកដថាមិនមានរឿងហេតុបែបនេះនៃការរំលោភផ្លូវភេទកើតមាននៅកន្លែងដទៃទៀត ឬក៏ដោយអ្នកសួរចម្លើយដទៃទៀតនោះ?

[១៥:២២:៥៤]

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកជំទាវ! គឺជឿទៅលើការអប់រំ ជឿលើការដែលខ្លួនគេៗដឹងខ្លួនថាបើធ្វើស្លាប់ ។ ដូច្នេះ គេមិនប៊ានធ្វើ ជឿអ៊ីចឹង ។ ហើយអ្នកកន្លែងផ្សេងទៀត វាមិនឮមកដល់ខ្ញុំ ។ រឿងម្នាក់នេះ វាឮមកដល់ខ្ញុំ ដូច្នេះ ខ្ញុំជឿថាមានតែមួយករណីនេះឯង ។ នេះសូមជម្រាបបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** នៅថ្ងៃនេះ នៅក្នុងសវនាការនេះ លោកដូចជាបង្ហាញថាលោកមានការអៀនខ្មាសនិងសោកស្តាយចំពោះអតីតកាលរបស់លោកក្នុងការទទួលយកនូវចម្លើយសារភាព ដោយប្រើការធ្វើទារុណកម្មនោះ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ ! ពិតជាត្រឹមត្រូវហើយ ខ្ញុំអត់ប្រកែកទេ ។

**ស៖** ក៏ប៉ុន្តែ នៅពេលនោះ នៅពេលដែលចម្លើយសារភាពដែលលោកនិយាយថា ជាញឹកញាក់ណាស់គឺជាចម្លើយសារភាពដែលមិនមានការពិតនោះត្រូវទទួលយកបានដោយការធ្វើទារុណកម្ម ។

ហើយនៅពេលនោះលោកមិនមានការបារម្ភអ្វីបន្តិចសោះ ហើយលោកក៏មិនមានការសោកស្តាយអ្វីដែរ ហើយលោកក៏មិនមានការអៀនខ្មាសអ្វីដែរ គឺជាសាមញ្ញ គឺលោកព្យាយាមធ្វើកិច្ចតែប៉ុណ្ណោះ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! បើមើលពីសំបកក្រៅទៅវាឃើញអ៊ីចឹង ។ ក៏ប៉ុន្តែ បើយើងមើលដល់ជម្រៅដូចខ្ញុំបានជម្រាបលោកចៅក្រម ឡាវែន៍ ព្រឹកមិញអ៊ីចឹង ឬក៏ម្សិលមិញ ។ រឿងរ៉ាវរបស់ខ្ញុំវាមិនមែនត្រឹមតែជាកំសាកនោះទេ វាលើសពីកំសាកទៅទៀត គឺក្បត់មិត្ត ក្បត់ភក្តិ ព្រោះខ្លាចខ្លួនឯងស្លាប់ ។ បើសិនជាយើងមិនធ្វើតាមគេ គឺយើងស្លាប់ ដូច្នេះ វាត្រូវតម្រូវឲ្យក្បត់មិត្តភក្តិ ។ មិត្តភក្តិក៏មិនប៉ានជួយ ស្អីក៏មិនប៉ានជួយដែរ មិនប៉ានដោះស្រាយ ។ ដូច្នេះហើយគឺក្បត់ហើយ ក្បត់ការពិត ក្បត់ចិត្តរបស់មិត្តភក្តិដែលធ្លាប់ស្រឡាញ់គ្នាពីក្មេងមក អាហ្នឹងវាទៅអ៊ីចឹង ។ ក៏ព្រោះតែស្អី? ក៏ព្រោះតែយើងខ្លាចស្លាប់ យើងកំសាក នេះសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៏៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំអត់មានសំណួរអីទេទាក់ទងទៅនឹងផ្នែកនៃអង្គហេតុនេះ ។

**សួរដោយប្រធានអង្គជំនុំ៖**

អរគុណលោកស្រីចៅក្រម ។ ឥឡូវនេះ យើងមានសំណួរមួយចំនួនទៀតពាក់ព័ន្ធជាមួយនឹងអង្គហេតុនេះ ។

**ស៖** ឥឡូវនេះ យើងវិលទៅក្រោយបន្តិច លោក កាំង ហ្គេកអ៊ាវ នៅក្នុងអំឡុងពេលនៃការដាក់ឃុំឃាំង ។ តើលោកមានបានដឹងអំពីហេតុការណ៍នៃមន្ទីរស-២១ បានធ្វើវិសោធនវេជ្ជសាស្ត្រលើជនដែលជាប់ឃុំឃាំងដែរឬទេ? ហើយបើមាន គឺមានរូបភាព ឬក៏ទង្វើបែបណាខ្លះទៅនៃការពិសោធន៍វេជ្ជសាស្ត្រទៅលើអ្នកជាប់ឃុំឃាំងទាំងនោះ?

[១៥:២៦:៥៤]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំដឹង២ ។ ទីមួយ គឺយកមនុស្សរស់ទៅវះឲ្យពេទ្យរៀន*អានាតូមី* ។ នេះសម័យដែលយើងខ្ញុំនៅធ្វើអនុប្រធាន ។ ទីពីរ ការបូមឈាមក៏មានពីជំនាន់នោះដែរ ។ ហើយវាតរហូតមកដល់ជំនាន់ខ្ញុំទៀត ។ មានទាំងសល់ឯកសារនៅស-២១ ដែលខ្ញុំណែនាំតាមបញ្ជាពីខាងលើឲ្យគេជ្រើសរើសមនុស្សយកទៅបូមឈាមហ្នឹង ដើម្បីការពារកុំឲ្យវាកើតជំងឺសើស្បែកដល់អ្នកដែលទទួលឈាម នេះប្រភេទទីពីរគឺរឿងបូមឈាម វាកើតតាំងពីសម័យខ្ញុំធ្វើជាអនុប្រធានរហូតមក

ដល់ខ្ញុំធ្វើជាប្រធាន ។ សរុបមក ជនរងគ្រោះដែលស្លាប់ដោយសារបូមឈាមប្រហែលជាមួយរយនាក់ នេះបើតាមខ្ញុំរំលឹកឡើងវិញ នេះទីពីរ ។ ទីបី ថ្នាំដែលស្ល ហើយថ្មីៗ ធម្មតាទេយើងយកទៅពិសោធន៍ ជាមួយអ្នកទោសវាគឺជាឧក្រិដ្ឋកម្ម ។ ក៏ប៉ុន្តែ បើសិនជាអ្នកស្លហ្នឹងហូបខ្លួនឯង ពិសោធន៍ខ្លួនឯងអាហ្នឹង វាជាការហៅថាការស្វែងរកដោយឈានមុខ ក៏ប៉ុន្តែយើងខ្ញុំ នៅក្នុងអង្គភាពហ្នឹងគេយកថ្នាំទៅពិសោធន៍ នៅលើអ្នកទោស ដូច្នេះ វាទៅជាឧក្រិដ្ឋកម្មប្រាកដប្រជា នេះប្រភេទទីបី ។ ប្រភេទពីបួន ពូនួន គាត់ឲ្យ ថ្នាំមកខ្ញុំឲ្យយកទៅពិសោធន៍លើអ្នកទោស ។ ថ្វីត្បិតតែ ខ្ញុំបានប្រាកដក្នុងចិត្តថាយកថ្នាំ យកម្សៅវាប្តូរ នឹងប៉ារ៉ាសេតាម៉ុលក៏ដោយ ក៏ប៉ុន្តែ អ្នកទោសគេមិននេះទេ គេមែនមិនយល់ទេ គេយល់ ។ ដូច្នេះ វាគឺជា ឧក្រិដ្ឋកម្មមួយ ទោះបីជាតិថ្នាំហ្នឹងមិនមែនជាថ្នាំពុលក៏អ្នកទោសគេយល់ថា យើងពិសោធន៍ថ្នាំ ។ អ្នក ណាដែលមើលមកក៏ឃើញថាយើងពិសោធន៍ថ្នាំ ។ នេះគឺជាឧក្រិដ្ឋកម្មមួយទៀត ។ ដូច្នេះ សរុបមក បើ តាមខ្ញុំចាំ មានបួនប្រភេទនេះ ។ សូមជម្រាបលោកប្រធាន ។

**ស៖** អរគុណ ។ លោកអាចបញ្ជាក់បានទេថា កម្រិតនៃការបូមឈាមពីអ្នកជាប់ឃុំឃាំងហ្នឹង ក្នុងម្នាក់ហ្នឹងបូមកម្រិតបូមឈាមយកពីនាក់ ក្នុងម្នាក់ហ្នឹងកម្រិតប៉ុន្មានទៅ? មួយលីត្រ ពីរលីត្រឬក៏ ប្រាំលីត? ព្រោះលោកនិយាយមិញថារហូតដល់បូមគឺរហូតដល់ស្លាប់១០០នាក់ ។ បានន័យថា ក្រោយ ការបូមហ្នឹងស្លាប់រហូតដល់មួយរយនាក់ ឯណោះដែលមានចំនួនច្រើនដូច្នេះ ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ការបូមជំនាន់នោះបើតាមខ្ញុំចាំដូចជាមិនមានបូមតិចទេ ។ បូមអស់ឈាមពីខ្លួនហើយគ្នាស្លាប់បណ្តោយនោះ ។ ដូច្នេះ ប៉ុន្តែ មិនមែនបូមមានខ្សែសង្វាក់ទេ កាល ណាពេទ្យ៩៨ គេរត់មក តាមការអនុញ្ញាត និងតាមកាណែនាំរបស់មេ បើកាលណាពេទ្យ៩៨ គេរត់មក ហើយ ខាងស-២១ ពេទ្យស-២១ ត្រូវតែពុះពារដោះស្រាយហើយ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណឹង ។

[១៥:៣០:៤៧]

**ស៖** អរគុណ ។ នៅក្នុងឯកសារមានករណីអ្នកជនឃុំឃាំងមួយចំនួនគាត់ផ្តាក់ខ្លួនឈឺ ហើយត្រូវ បានទទួលការព្យាបាលដោយការចាក់ថ្នាំតាមសរសៃនៅពេលល្ងាច ហើយពេលបន្ទាប់នោះមកបុគ្គល នោះស្លាប់ ឃើញស្លាប់តែម្តង ។ តើករណីនេះលោកដឹងដែរឬទេ? ហើយវាមានការពាក់ព័ន្ធទៅនឹងការ ពិសោធន៍ថ្នាំដែលលោកបានលើកឡើងអម្បាញ់មិញដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រឿងនេះខ្ញុំមិនដឹងទេ ។ ក៏ប៉ុន្តែបើតាមការវិភាគឥឡូវខ្ញុំជឿ ថា មិនមែនជាការពិសោធន៍ថ្នាំទេ គឺជាការខ្វះបច្ចេកទេសទៅវិញទេ ។ នេះខ្ញុំយល់ហើយសន្និដ្ឋានអ៊ីចឹង

តែមិនដឹងជាខុស ឬត្រូវទេ សូមសន្និដ្ឋានជូនលោកប្រធានប៉ុណ្ណេះ ។

**ស៖** អម្បាញ់មិញនេះ លោកបាននិយាយខ្លះហើយ។ ប៉ុន្តែយើងចង់បញ្ជាក់ថា តើលោកបានចូលរួមនៅក្នុងហេតុការណ៍នៃការធ្វើពិសោធន៍វេជ្ជសាស្ត្រលើអ្នកជាប់ឃុំឃាំងនោះដូចម្តេចដែរ? នៅក្នុងការពិសោធន៍វេជ្ជសាស្ត្រនៅមន្ទីរស-២១ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំធ្វើដោយផ្ទាល់ដៃគ្មានអ្នកណាដឹងទេ មានតែពីរនាក់គត់ដែលដឹង គឺខ្ញុំហើយនិងពូនួន ។ ខ្ញុំធ្វើដោយផ្ទាល់ដៃ ។ មួយថ្ងៃខ្ញុំឲ្យលេបពីរគ្រាប់ ស្អែកឡើងពីរគ្រាប់ទៀតម្នាក់ដូចជាពិសោធហ្នឹងបីថ្ងៃ ។ អ្នកផ្សេងទៀតគេឃើញៗខ្ញុំយកមនុស្សបីនាក់ទេមិនដឹង មកដាក់ឲ្យដេកនៅចន្លោះកន្លែងថតរូប ហើយនិងកន្លែងពួកគូរឆ្លាក់ ហើយខ្ញុំយកថ្នាំទៅឲ្យព្រឹកល្ងាចឲ្យគេលេបនឹងដៃឯងគ្មានអ្នកណាកាន់គ្មានអ្នកណាមើលថ្នាំហ្នឹងទេ ។ ដូច្នេះ ខ្ញុំធ្វើដៃឯង គេគ្រាន់តែយល់ ជាពិសេសជនរងគ្រោះដែលយើងយកគេមកពិសោធថ្នាំ គេដឹកថាយើងពិសោធថ្នាំ ។ នេះខ្ញុំសូមបញ្ជាក់ជូនអំពីឧក្រិដ្ឋកម្មមួយបែបនេះ វាដំណើរការទៅអ៊ីចឹង ។ សូមជម្រាបលោកប្រធាន ។

**ស៖** វិលមកចំណុចមួយទៀត ដោយការសួរហ្នឹងអាចមានការខ្វះចន្លោះយើងនឹងសួរបំពេញនូវកិច្ចការដែលពិនិត្យទៅឃើញថាមិនទាន់គ្រប់ជ្រុងជ្រោយ ។ អំពីការសួរចម្លើយពួកឈ្លើយសឹកវៀត-ណាម តើការសួរហ្នឹងគឺមានគោលបំណងនៃចង់បានព័ត៌មានទាក់ទងទៅនឹងសមរភូមិ ស្ថានភាពនៃការប្រយុទ្ធ ឬក៏ប្រមូលព័ត៌មានសម្ងាត់នៃផ្នែកយោធា ដើម្បីជាការរៀបកម្លាំងវាយលុកទៅប្រទេសវៀត-ណាមដែរឬទេ? ឬក៏មានលក្ខណៈមួយដែលបង្ហាញជាសាធារណៈមតិជាតិ អន្តរជាតិដែលលោកបានឆ្លើយពីព្រឹកហើយថា បំណងគឺបង្ហាញមតិជាតិ អន្តរជាតិថាវៀតណាមឈ្លានពានកម្ពុជា?

[១៥:៣៤:១៤]

**ឆ៖** រឿងនេះខ្ញុំសូមបញ្ជាក់ដដែលឡើងវិញ គឺវាចែកជាពីរសម័យ ។ សម័យមុនសង្គ្រាមប្រកាសចំហ ហើយនិងសម័យដែលការប៉ះទង្គិចគ្នាបន្តិចបន្តួច ។ អ៊ីទៅ ដែលខ្ញុំតែងតែនិយាយថា វាយទៅវាយមក ស៊ីទៅស៊ីមក លូកទៅលូកមក ក្នុងរយៈកាលនេះខ្ញុំនៅចាំតែមួយរឿងទេដែលសំខាន់ជាងគេពេលដែលខ្ញុំនៅធ្វើជាអនុប្រធាន ឬក៏ទើបតែនឹងឡើងធ្វើជាប្រធាន មានផែនការមួយដែលខ្ញុំសួរចម្លើយបាន គេសួរចម្លើយបានហើយយកមកបង្ហាញខ្ញុំ ហើយខ្ញុំក៏សុខចិត្តទទួលដែលថា ផែនការហ្នឹងវាឆ្លើយអ៊ីចឹងមែន គឺវាដាក់ខែនេះវ៉ៃយកខេត្តនេះ ខេត្តកម្ពុជា ។ ពីរបីខែក្រោយមកវ៉ៃយកខេត្តនោះ ខ្ញុំជឿ ។ ហើយខ្ញុំរាយការណ៍ទៅលើ ដល់រាយការណ៍ទៅលើខាងលើមិនជឿ ជាពិសេសមេខ្ញុំលោកគ្រូ សុន សេន

គាត់មិនជឿ គាត់ស៊កឲ្យខ្ញុំមួយម៉ាត់ គាត់ថា "ចុះភ្លីស្រែសង្គមជាតិនិយមយើងទៅណា បើយួនវាយក អស់ទៅហើយអ៊ីចឹង?" ខ្ញុំលែងមាត់កើត ។ ដល់ថ្ងៃក្រោយមក ខ្ញុំមិនប៊ានសួរគិតគូរអីខ្លាំងជ្រាលជ្រៅពេកទេ ។ ខ្ញុំគិតថា ស្រួលមិនស្រួលមេសង្ស័យខ្ញុំមិនមានគោលជំហរច្បាស់លាស់ លង់ទៅឧបាយកលចិត្តសាស្ត្ររបស់ខ្មាំង ។ ដូច្នេះ ពីមុននោះ ការសួរចម្លើយបើតាមខ្ញុំចាំមិនយកចិត្តទុកដាក់លើការងារយោធាទេ ព្រោះអ្នកដែលមកជាប់ភាគច្រើនជាមនុស្សតូចតាច ថ្នាក់ភាគច្រើនមិនដល់អនុសេនីយ៍ផង យូរៗឃើញវរសេនីយ៍តែម្នាក់ពីរនាក់ទេ មួយជីវិតស-២១ ក្រៅពីនោះ អនុសេនីយ៍តិចតួច ហើយក្រៅពីនោះ ពួកនាយទាហានសាមញ្ញតូចតាច ។ នេះខ្ញុំសរុបឃើញអ៊ីចឹង ។ ដូច្នេះ ខ្ញុំមិនយកចិត្តទុកដាក់ពីផែនការវ៉ៃលុកអីដែលមានលក្ខណៈធំដុំទេ ។ នេះបើតាមខ្ញុំចាំ។ ដូច្នេះ ក៏ប៉ុន្តែរឿងចាំវាផ្សេង ឯចំណែកឯកសារបើសិនជានៅសល់វាមានបញ្ហានេះ មានស៊ីញ៉េខ្ញុំ មានអីៗវាច្បាស់លាស់ អាហ្នឹងខ្ញុំពិតជាទទួលស្គាល់តាមឯកសារជាង ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** ការសួរចម្លើយឈ្លើយសឹកនិងជនស៊ីវិលវៀតណាមហ្នឹង តើមានការប្រើទារុណកម្មដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន ទារុណកម្មតិចណាស់ ព្រោះបំណងយើងចង់បានតែប៉ុននុ៎ងចង់បានឲ្យឆ្លើយថា យួនឈ្លានពានទឹកដី ។ នេះបំណងប៉ុណ្ណឹង មិនមានទារុណកម្មអីក៏ថាបានដែរ ។ បំណងទីពីរ ដល់ក្រោយមក បក្សណែនាំពីខាងលើមកឲ្យឆ្លើយថាទាហានវៀតណាម ប្រជាជនវៀត-ណាមអត់អីស៊ីៗកន្ទក់ ។ ដូច្នេះ បំណងរបៀបនេះ មិនបាច់ទារុណកម្មក៏សឹងតែថាបាន ។ នេះជម្រាបប្រសាសន៍លោកប្រធាន ។

**ស៖** ក្នុងករណីអ្នកទោសមិនព្រមឆ្លើយសារភាព ឬក៏ឆ្លើយសារភាពមិនបានត្រឹមត្រូវសមតាមបំណងនៃអ្នកសួរ តើការប្រើទារុណកម្មហ្នឹងមានលក្ខណៈដូចម្តេចដែរ?

[១៥:៣៨:១៤]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ទីមួយសូមនិយាយអំពីអ្នកទោសខ្មែរ បើកាលណាអ្នកឆ្លើយគេឆ្លើយមិនពេញចិត្តយើងទេ មានចំណារនៅសល់ ដែលខ្ញុំចារទៅ ទារុណកម្មកម្រិតនេះថែមទៀតយ៉ាងម៉េចអីនៅមានសល់ចំណារខ្ញុំជាភស្តុតាង ។ ដូច្នេះ ខ្ញុំជាអ្នកតម្រូវ អ្នកបញ្ជាឲ្យគេធ្វើទារុណកម្មថែមទៀត ។ ឯចំណែកចម្លើយវៀតណាម ខ្ញុំជឿថា មិនមានទារុណកម្មអីធ្ងន់ធ្ងរទេ យ៉ាងច្រើនត្រឹមកំហែងអីទៅ គេធ្វើហើយ ព្រោះអ្នកណាក៏មិនចង់ឲ្យត្រូវរំពាត់ដែរ ។

**ស៖** នៅក្នុងអង្គហេតុព្រមព្រៀងគឺមានសរសេរត្រង់កថាខណ្ឌ២២៨ អ្នកទោសនៅមន្ទីរស-២១ ម្នាក់ឈ្មោះ ជុំ ម៉ី ត្រូវបានវាយនឹងដំបងមួយកំណាត់នៅលើខ្នងរបស់គាត់ជាច្រើនលើកច្រើនសា ហើយក្រចកជើងទាំងសងខាងរបស់គាត់ត្រូវបានចាប់ដកចេញ ។ គាត់បានទទួលរងនូវការឆក់ខ្សែភ្លើងនៅនឹងទងត្រចៀករបស់គាត់ ហើយបីថ្ងៃនៃការសួរចម្លើយ គាត់បានសន្លប់ចំនួនពីរដង ។ ជុំ ម៉ី ត្រូវបានគេប្រព្រឹត្តបែបនេះចំពោះគាត់អស់រយៈពេលដប់ពីរថ្ងៃ និងដប់ពីរយប់ ។ អង្គហេតុនេះលោកដាក់ថា "មិនតវ៉ា" តើលោកទទួលស្គាល់ថា អង្គហេតុនេះពិតជាកើតមានដូច្នេះមែនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំនឹងជុំ ម៉ី ខ្ញុំមិនដែលតវ៉ាមែន ។ ខ្ញុំមិនដែលតវ៉ាទេ ។ ខ្ញុំជឿ ហើយនៅមានមួយរឿងទៀត ដែលគាត់តែងតែនិយាយពីរឿង មិត្តសេង ទៅអង្គុយលើក្បាលគាត់។ ខ្មែរយើងប្រកាន់ក្បាលណាស់ ។ ហើយដល់មិត្តសេង ក្មេងល្អកទៅអង្គុយលើក្បាលជុំ ម៉ី គាត់ខឹងមិនតិចទេ ។ រឿងនេះអត់មាននៅក្នុងឯកសារអីទេ ប៉ុន្តែ ខ្ញុំទទួលស្គាល់ប៉ុណ្ណោះ អានេះមួយថែមទៀត ។ នេះសូមបញ្ជាក់ជូនលោកប្រធានប៉ុណ្ណោះ ។

**ស៖** អង្គហេតុមួយទៀតគឺ លេខកថាខណ្ឌ២២៩ អ្នកទោសនៅមន្ទីរស-២១ម្នាក់ឈ្មោះ ប៊ូ ម៉េង ត្រូវបានបង្ហាញអំពីឧបករណ៍ធ្វើទារុណកម្មផ្សេងៗនៅក្នុងបន្ទប់សួរចម្លើយ ហើយប្រាប់ឲ្យគាត់ជ្រើសរើសឧបករណ៍ ដែលនឹងត្រូវប្រើសម្រាប់ធ្វើទារុណកម្មលើរូបគាត់ ។ គាត់ត្រូវបានគេវាយនឹងខ្សែតីរំពាត់ផ្តៅ និងខ្សែភ្លើងលើខ្នងរបស់គាត់ ដែលពេលដែលដៃទាំងពីររបស់គាត់ជាប់ខ្នោះ និងត្រូវបង្ខំឲ្យដេកផ្កាប់មុខនៅលើដី ។ ខ្នងរបស់គាត់មានស្នាមរបួសពាសពេញ ហើយឈាមហូរពាសពេញលើកម្រាលឥដ្ឋ គាត់ក៏ត្រូវគេឆក់ខ្សែភ្លើងផងដែរ ។ ប៊ូ ម៉េង ត្រូវគេធ្វើទារុណកម្មពីរដងក្នុងមួយថ្ងៃ អស់រយៈពេលពីរសប្តាហ៍ ។ លោកអាចនិយាយថា លោកមិនតវ៉ាទេ នៅអង្គហេតុនេះ ។ តើលោកជឿទេថា អង្គហេតុនេះមានដូច្នេះមែនទេ?

[១៥:៤១:៥៨]

**ឆ៖** ខ្ញុំទទួលស្គាល់ ជនរងគ្រោះទាំងអស់នៅក្នុងមន្ទីរស-២១ ខ្ញុំមិនដែលប៊ានប្រកែកទេ ។ ជាទុក្ខសោកវេទនាដែលគេបានទទួល ខ្ញុំអត់ប្រកែកទេ ។

**ស៖** ឥឡូវនេះចូលមករូបភាពទារុណកម្មមួយចំនួនទៀត យើងកត់សម្គាល់ឃើញថា លោកបានឆ្លើយបញ្ជាក់នៅរូបភាពធ្វើទណ្ឌកម្មនេះមួយចំនួនហើយ ក្រៅពីរូបភាពបួនដែលកំណត់អនុញ្ញាតឲ្យធ្វើទារុណកម្មនោះ ។ ហើយនៅក្នុងនេះគឺមានពាក់ព័ន្ធជាមួយនឹងប្រភេទមួយទៀត គឺបង្ខំឲ្យស៊ីលាមក

តើរឿងហេតុនេះមានដែរទេ នៅក្នុងការធ្វើទារុណកម្មបង្ខំមនុស្សឲ្យស៊ីលាមកខ្លួនឯងនេះ?

**ឆ៖** រឿងនេះមានឡើងមួយករណី គឺជាមួយនឹងលោកគ្រូ កែ គឹមហួត ពីរឿងមិត្ត ទុយ ហ្នឹងឯង ។ ខ្ញុំមិនចាំក៏ពិតមែន ក៏ប៉ុន្តែវាមានចំណារមិត្តទុយ ខ្ញុំជឿថាហេតុផលនេះ ទោះបីខ្ញុំដឹងក៏ដោយ មិនដឹងក៏ដោយ វាពិតជាកើតទៅលើគ្រូខ្ញុំ ។ គេធ្វើមែន ក៏ប៉ុន្តែ ខ្ញុំអនុគ្រោះគេ ទោះបីគេខុសយ៉ាងនេះក៏ខ្ញុំនៅតែអនុគ្រោះគេដែរ ។ នេះវាជារឿងមួយដែលខ្ញុំទទួលស្គាល់ថា វាមានកើតរួចមកហើយ ពិត ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** ចុះមានប្រភេទទារុណកម្មផ្សេងទៀត គឺបង្ខំឲ្យផឹកទឹកនោមដែរទេ?

**ឆ៖** រូបភាពបែបនេះ ខ្ញុំមិនបានអនុញ្ញាតទេ មិនបានដឹងទេ ។ ក៏ប៉ុន្តែ ជឿថាមាន ជឿថាមាន វាស្រួលធ្វើណាស់មនុស្ស ។

**ស៖** អម្បាញ់មិញនេះលោកបានឆ្លើយជាមួយនឹងលោកស្រីចៅក្រម ខាតវ៉ាយថ៍ រួចហើយ អំពីរូបភាពទណ្ឌកម្មមួយទៀត គឺការបង្ខំឲ្យជនរងគ្រោះលុតជង្គង់សំពះរូបផ្កែ ប៉ុន្តែ ឯកសារបានបង្ហាញថាមានករណីផ្សេងពីនេះខ្លះទៀតដែលមានរូបភាពផ្សេង ដូចជាការបង្ខំជនរងគ្រោះឲ្យលុតជង្គង់សំពះតុ សំពះកៅអីជាដើម ។ តើមានករណីនេះដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំជឿថាមាន១ ការអប់រំពីខាងលើទៅពីខ្ញុំ ។ ខ្ញុំមិននិយាយពីគេអប់រំខ្ញុំទេ ខ្ញុំនិយាយពីខ្ញុំអប់រំគេតទៅទៀត ត្រូវបែងចែកព្រំដែនវណ្ណៈឲ្យច្បាស់លាស់រវាងយើងនិងខ្មាំង ។ បន្តិចនៅក្នុងស-២១ អ្នកណាទៅហៅជនរងគ្រោះដែលជាប់ទោសនៅនុ៎ងថា មិត្ត ថាលោកអ៊ំ សុទ្ធតែត្រូវបញ្ហា ។ ដូច្នេះ យើងបែងចែក អប់រំក្នុងការបែងចែករវាងខ្មាំង និងយើងអ៊ីចឹង ក្មេងៗជ្រួលជ្រើមណាស់ ។ មិននៅ១មិត្តសេង ទៅអង្គុយលើក្បាលជុំ ម៉ី ។ លេងហៅអា ជាទូទៅ ក្មេងល្អក៏ហៅ ជុំ ម៉ី អាដែរ ។ កុំថាតែខ្ញុំ ។

[១៥:៤៦:០៨]

ដូច្នេះ អារឿងថ្វាយបង្គំផ្កែ ហើយមកថ្វាយបង្គំតុ ថ្វាយបង្គំកៅអី ប្រហែលជាកើតមុនអាថ្វាយបង្គំផ្កែហ្នឹងផង ថ្វាយបង្គំតុ ថ្វាយបង្គំកៅអី ។ នេះខ្ញុំជឿ ។ ដូច្នេះវាមិនមែនខុសពីគេទាំងស្រុងទេ ហើយខ្ញុំអត់បានអប់រំឲ្យថ្វាយបង្គំតុ ថ្វាយបង្គំកៅអីក៏ពិតមែន ក៏ប៉ុន្តែការអប់រំឲ្យបែងចែកខ្មាំង ហើយនិងយើងឲ្យដាច់ស្រឡះពីគ្នា អាហ្នឹងវាស្រួលជំរុញឲ្យគេប្រព្រឹត្តបទពាសវាលពាសកាលអ៊ីចឹង ។ នេះសូមទទួលហើយរកមូលដ្ឋាន គឺនៅឯការអប់រំហ្នឹងឯង ។ សូមជម្រាបលោកប្រធានប៉ុណ្ណេះ សូមទោស សូមអស់ ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញា សូមលោកជួយឱ្យអ្នកបច្ចេកទេសខាងការិយាល័យសហព្រះរាជអាជ្ញា បញ្ចាំងនូវឯកសារដែលមានឯកសារជាភាសាខ្មែរ ដែលមានលេខ ERN00195373 ដល់ 00195377 ។ អាចធ្វើបានទេ?

ឯកសារនេះបញ្ចាំងពីម្សិលមិញរួចម្តងហើយ អំពីរូបភាពមួយចំនួនដែលពាក់ព័ន្ធជាមួយនឹងមន្ទីរអគារឃុំខ្លួនជាមួយគ្នាហ្នឹងឯង ។

**លោក វីលៀម ស្មីត៖**

នោះគឺជារូបភាព តើត្រឹមត្រូវដែរឬទេលោកចៅក្រម?

**ប្រធានអង្គជំនុំ៖**

ត្រឹមត្រូវហើយ ។ ផ្នែកសោតទស្សន៍សូមភ្ជាប់ប្រព័ន្ធរូបភាពមកកុំព្យូទ័ររបស់អ្នកជំនួយការរបស់សហព្រះរាជអាជ្ញា ។

**លោក វីលៀម ស្មីត៖**

សូមអរគុណ ។ គឺយើងមានរូបភាព គឺមកពីអ្នកជំនាញ *អាឡិកស៊ីស* ដែលបង្ហាញអំពីទីតាំង ស-២១ និងបន្ទប់ផ្សេងៗនៅក្នុងទីតាំងស-២១ នេះ ។

[១៥:៤៩:២២]

**ប្រធានអង្គជំនុំ៖**

ត្រឹមត្រូវហើយ រូបភាពនេះគឺខាងសហព្រះរាជអាជ្ញាបានរៀបចំជាឯកសារ ជាសៀវភៅ បានចែកជូនមកដល់ខាងភាគីទាំងអស់ ។ សូមបញ្ចាំងបង្ហាញនូវរូបភាពទី ៣៦, ៣៧ និង៣៨ ។

សូមជនជាប់ចោទពិនិត្យមើលអំពីរូបភាពនេះ ដែលមានបង្ហាញនូវបង្គោលដែកឈរ ហើយមានដែកទទឹងភ្ជាប់បង្គោលទាំងពីរ ហើយមានពាងទឹកនៅពីខាងក្រោមចំនួនពីរ ។ សូមតទៅ៣៧ ទៅមួយទៀត ។

នេះជារូបមួយទៀតគឺមានការជិតជាង ហើយមួយទៀតគឺ៣៨ ។ នេះប្រភេទនៃទម្រង់ធ្វើទណ្ឌកម្មចំនួនពីរផ្សេងទៀត ដែលមានការបង្ហាញនៅក្នុងសំណុំរឿង ។ ឥឡូវនេះ លោកបានមើលរូបភាពនេះហើយ គឺការប្រើប្រាស់អាងទឹកដើម្បីធ្វើទារុណកម្មជនរងគ្រោះ ដោយចាប់ជនរងគ្រោះជ្រមុជចូលទៅក្នុងទឹក ដែលទទឹក ។ ហើយនិងទីពីរគឺប្រភេទមួយទៀត គឺចងជើងជនរងគ្រោះ រួចទាញព្យួរឡើងទៅ

លើដោយខ្សែព្យួរនឹងបង្គោល រួចសម្រូតទម្លាក់ចុះជ្រមុជក្បាលចូលទៅក្នុងពាងទឹក ដូចដែលរូបភាពបានបញ្ចាំងចំនួនពីរអម្បាញ់មិញនេះ គឺលេខ ៣៦ ហើយនិងលេខ ៣៧ ។

**ស៖** តើលោកមានអ្វីនិយាយអំពីបញ្ហាទម្រង់នៃរូបភាព នៃការធ្វើទារុណកម្មចំនួនពីររូបភាពនេះដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! រូបភាពនេះខ្ញុំមិនដែលយល់ព្រមទេ កាលនៅសម័យតទល់ក៏ខ្ញុំមិនយល់ព្រម ។ ពីព្រោះអី ពីព្រោះវាខុសអំពីសេចក្ដីណែនាំរបស់ខ្ញុំឆ្ងាយពេក ហើយការធ្វើបែបនេះមានមនុស្សមិនតិចទេ ដែលឃើញ ។ ដូច្នេះ បើខុសពីសេចក្ដីណែនាំរបស់ខ្ញុំ ច្បាស់ជាខ្ញុំដឹង ដូចជាទម្លាក់កុមារពីលើអគារបីជាន់ វាខុសខ្លាំងពេក ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ ខ្ញុំអស់សំណួរហើយ តើលោក លោកស្រីចៅក្រមមានសំណួរអ្វីត្រូវសួរដល់ជនជាប់ចោទរូបនេះទៀតទេ អំពីអង្គហេតដែលយើងកំពុងតែធ្វើសវនាការនេះ?

សូមអញ្ជើញលោក ហ្សង់ម៉ាក ។

[១៥:៥៣:៥៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមិនមានសំណួរទាក់ទងទៅនឹងអង្គហេតុចុងក្រោយដែលលោកចៅក្រមលើកឡើងនោះទេ ខ្ញុំមានសំណួរទាក់ទងទៅនឹងអ្វីដែលយើងបានលើកឡើងមុននេះ ។ ទាក់ទងទៅនឹងការបូមឈាម តើយើងអាចឈប់បញ្ចាំងរូបភាពនេះ? តើយើងអាចដករូបភាពនេះចេញសិនទៅ?

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍សូមផ្ដាច់ប្រព័ន្ធមកប្រក្រតីភាពវិញ ។ សូមអញ្ជើញលោកចៅក្រម ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ដូច្នេះ គឺយើងនិយាយអំពីការពិសោធន៍ផ្នែកវិជ្ជសាស្ត្រ ជាពិសេសគឺទាក់ទងទៅនឹងបញ្ហានៃការបូមឈាម ។ ខ្ញុំសូមធ្វើឲ្យការបញ្ជាក់ឲ្យបានច្បាស់លាស់ ថាតើជនជាប់ចោទនៅថ្ងៃនេះ គាត់ទទួលស្គាល់ថាគាត់បានដឹងអំពីការអនុវត្តការបូមឈាមបែបនោះដែរឬទេ? ឬក៏ជំហាររបស់គាត់មានការផ្លាស់ប្ដូរដូចជំហារដែលបានលើកឡើងនៅក្នុងពេលដែលនៅចំពោះមុខរបស់ចៅក្រមស៊ើបអង្កេត?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រមៗ! គោលជំហរខ្ញុំប្តូរពីរឿងការបូមឈាមនេះ ។ កាលពីសម័យស៊ើបអង្កេតខ្ញុំទទួលស្គាល់ថា បើមានគឺវាគ្រាន់តែជាបន្តពី ណាត មក ខ្ញុំមិនដឹង ។ ពាក្យខ្ញុំមិនដឹងនេះ ខ្ញុំបាននិយាយនៅក្នុងសម័យស៊ើបអង្កេត ។ ក៏ប៉ុន្តែ ខ្ញុំនឹកយូរៗទៅខ្ញុំឃើញ ខ្ញុំនឹកឃើញ រឿងដែលមេទូរស័ព្ទមកខ្ញុំ ប្រាប់ ដែលខ្ញុំនៅចាំច្បាស់ជាគេ គឺរឿងឈាមដែលយកទៅប្រើលើយុទ្ធជន វានាំឱ្យកើតជំងឺស្បែក ។ ឲ្យ ឌុច ហ្នឹងពិនិត្យ គាត់បញ្ជាឲ្យខ្ញុំនឹងទៅពិនិត្យឲ្យមែនទែន ជ្រើសរើសមនុស្សឲ្យគេ ។ ដូច្នេះ ខ្ញុំដឹង ខ្ញុំជួយជ្រើសរើសមនុស្ស។ នេះជារឿងពិតដែលខ្ញុំដឹង ក្រោយមកនឹកឃើញរឿងចាស់ឡើងវិញ នេះសូមទទួលថាវាមានការប្រែពីអ៊ីចឹង ។ សូមអស់ សូមជម្រាបជូនលោកចៅក្រមប៉ុណ្ណេះ ។

**ស៖** តើវាមានរយៈប៉ុន្មានដែលធ្វើការអនុវត្តនោះធ្វើឡើង? ហើយអ្នកណាគេជាអ្នកផ្តួចផ្តើមទៅការអនុវត្តបែបនេះ?

**ឆ៖** ដោយសាររឿងនេះវាកើតតាំងពីសម័យ ណាត ហើយវាតមកដល់សម័យខ្ញុំទៀត ។ អ្នកដែលបង្កើតរឿងនេះដំបូងគឺមេខ្ញុំ លោកគ្រូ សុន សេន ទាមទារបញ្ហានេះ ។

**ស៖** ថាតើគេអនុវត្តវិធីសាស្ត្រនេះរយៈពេលប៉ុនណាដែរ? រហូតដល់ពេលណា?

**ឆ៖** ខ្ញុំបើតាមខ្ញុំស្មាន គឺរហូតដល់នៅស-២១ រឿងមិត្តទ្រី ប្រធានពេទ្យ ស-២១ ខ្ញុំត្រូវចាប់ ។ ហើយប្រធានគណៈកម្មាធិការពេទ្យ៩៨១ ឈ្មោះ មិត្ត តៃ ឈ្មោះដើម ម៉ឹង សំណឹប ក៏មេចាប់ដែរ ។

ដូច្នេះ ចាប់មនុស្សពីរនាក់ហ្នឹងទៅ ខ្ញុំជឿថាការបូមឈាមចប់នៅពេលនេះ ។

**ស៖** ប្រសិនបើខ្ញុំយល់ត្រឹមត្រូវនូវអ្វីដែលលោកបានពន្យល់នោះ គឺថាការអនុវត្តនេះ គឺបានបន្តរហូតដល់ការសម្រិតសម្រាំងដែលនៅពេលនោះ គឺមិនមានបុគ្គលិកជំនាញអាចធ្វើការបូមឈាមបាន?

**ឆ៖** បញ្ហាបច្ចេកទេស វាបញ្ហាមួយទេលោក លោកចៅក្រម ។ ក៏ប៉ុន្តែ បញ្ហាមនុស្សដែលទុកចិត្តវាបញ្ហាមួយទៀត ។ បញ្ហាដែលប្រធានជឿទុកចិត្ត មិត្តតៃ ក្នុងបញ្ហាបច្ចេកទេសជាងអ្នកណាទាំងអស់។ ហើយក្រោយមកប្រធានគណៈកម្មាធិការ ប្រធានគណៈកម្មាធិការពេទ្យ៩៨ នេះប្តូរមកមនុស្សស្រីម្នាក់។ ហើយមនុស្សស្រីម្នាក់នេះមិនសូវមានការរាប់អានជិតស្និទ្ធនឹងខ្ញុំដូច មិត្តតៃ ទេ ។ បើនិយាយអំពីបញ្ហាបច្ចេកទេសវិញបាត់ មិត្តទ្រី មួយគឺបាត់ហើយ អារឿងបូមឈាម អត់មានអ្នកណាជំនួសទេ ។

សរុបមក រួមផ្សំគ្នាទាំងបញ្ហាបច្ចេកទេស ហើយនិងបញ្ហាដែលមេជឿទុកចិត្ត ។

**ស៖** ដូច្នេះ គឺដោយសារតែបញ្ហាបច្ចេកទេស ព្រមទាំងនិងបញ្ហាធនធានមនុស្សហ្នឹងហើយ បានការអនុវត្តបែបហ្នឹងមិនត្រូវបានគេបន្តទៀតនោះ ។ អ្វីដែលខ្ញុំចង់និយាយនោះ គឺថាមកពីមិនមានបុគ្គលិក

ដែលលោកជឿទុកចិត្ត ដើម្បីបន្តកិច្ចការនោះទៀត ។ តើនេះជាហេតុផលឬ?

**ឆ៖** បាទ ។

**ស៖** ខ្ញុំក៏បានឮសំណួរអំពីការវះកាត់ទៅលើអ្នកទោសដែលរស់រានមានជីវិតនៅស-២១ តើនរណាគេដែលអនុញ្ញាតឲ្យធ្វើការវះកាត់មនុស្សដែលនៅរស់រានមានជីវិតដូច្នេះ? ហើយតើអ្នកណាគេអ្នកទទួលបន្ទុកទៅលើប្រតិបត្តិការនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម រឿងគេយកមនុស្សរស់ទៅរៀន ឲ្យពេទ្យរៀនវះកាត់ រៀន *អានាតូមី* វាដំណើរមកពីមុនមានខ្លះ ។ នៅពេលដែលខ្ញុំនៅជាអនុប្រធាន ខ្ញុំមិនប៉ានទប់បញ្ហានេះទេ គ្រាន់តែខ្ញុំពេលដែលដឹងដំណឹងថា គេយកប្រពន្ធ ថាច់ ជា យកទៅឲ្យរៀនវះកាត់ ខ្ញុំទាមទារ ណាត ដែលនៅក្បែរខ្ញុំនោះ គេមកសុំគាត់ទេ ដែលក្បែរខ្ញុំនោះ ខ្ញុំមិនឲ្យប្រពន្ធ ថាច់ ជា ទៅ ឲ្យយកអ្នកណាទៅវិញផ្សេងទៀតទៅ ។ ខ្ញុំក៏ស្មានថារឿងគេធ្វើតាមខ្ញុំ ។ ដល់ទៅជួបមេ ណាត គាត់អួតក្អេងក្អាងថា គាត់ឲ្យគេយកទៅហើយប្រពន្ធ ថាច់ ជា ហ្នឹង ។ នៅពេលហ្នឹងបែបមេគាត់ថា អ្ហែ! ធ្វើហ្នឹងមិនកើតតែម្តង ណាត ។ ដូច្នេះ ពេលហ្នឹងបាន បានខ្ញុំដឹងថា យកប្រពន្ធ ថាច់ ជា ទៅហ្នឹងគឺមេណែនាំឲ្យយកមនុស្សរស់នៅឲ្យគេវះកាត់ ។ ឯគំនិតផ្តើមយកប្រពន្ធ ថាច់ ជា ទៅគឺ ណាត ។ បន្តទៅទៀតខ្ញុំអត់ដែលដឹងរឿងនេះទៀតទេ ។

[១៦:០៥:០០]

**ស៖** ខ្ញុំដូចជាការពិបាកនឹងយល់អ្វីដែលលោកនិយាយបន្តិច ។ លោកនិយាយអំពីប្រពន្ធរបស់ ថាច់ ជា តើនេះមនុស្សដែលត្រូវបានគេឃុំខ្លួនឬ? ហើយក្រោយមកដែលគេត្រូវបានប្រើសម្រាប់ការវះកាត់ហ្នឹង ឬក៏គាត់ហ្នឹងជាអ្នកដែលជាធ្វើការវះកាត់នោះ? ហើយតើមានអ្វីកើតឡើងនៅពេលនោះ? តើមានកើតឡើងចំពោះអ្នកដែលត្រូវបានគេធ្វើការវះកាត់នៅពេលដែលគាត់មានរស់រានមានជីវិតនោះ តើគាត់ស្លាប់នៅពេលហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ថាច់ ជា នេះជារដ្ឋលេខាធិការក្រសួងសិក្សាធិការជំនាន់ លន់ នល់ ហើយត្រូវស្លាប់ជាមួយនឹង កៅ សាំងគីម ដោយសារក្លូដកម្មរបស់និស្សិត ។ ហើយនៅសល់ប្រពន្ធមេម៉ាយ ហើយនិងកូនប្អូនខាក់ដែល ណាត ចាប់បាននៅពេលជម្លៀស ។ ដោយសារ ថាច់ ជា ជាមនុស្សល្បីល្បាញអីចឹងហើយ បានជាខ្ញុំមិនចង់ឲ្យឧក្រិដ្ឋកម្មហ្នឹងវាមានលក្ខណៈចំហពេក ។ បាន

ជាខ្ញុំខំបង្វែរ តែបង្វែរវាមិនបាន វាទៅផុតបាត់ទៅហើយ ។ ក្រោយពីយកប្រពន្ធ ថាច់ ជា ទៅវះកាត់ទៅ កូន ថាច់ ជា នៅជាប់នៅក្នុងបញ្ជីស-២១ហ្នឹង បួននាក់ ។ ដល់ក្រោយមកក៏កម្ទេចទៅតាមគោលការណ៍ ក្មេងមិនទុក ។ សូមសរុបជូនលោកចៅក្រមប៉ុណ្ណេះ ខ្ញុំនឹងរាយការណ៍ជម្រាបបន្ថែមទៀត ។

**ស៖** តើនរណាគេជាក់លាក់ជាអ្នកធ្វើការវះកាត់នោះ? ហើយធ្វើរហូតដល់កម្រិតណា? ហើយតើអ្វីទៅជាលទ្ធផលនៃការវះកាត់ទៅលើអ្នកទោសជាស្ត្រីនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ថ្វីត្បិតតែខ្ញុំមិនបានឃើញ ខ្ញុំសូមសន្និដ្ឋានព្រឹត្តិការណ៍នេះ ដូចតទៅ៖

មិនដឹងជាគេសម្លាប់ឲ្យស្លាប់ហើយ បានគេយកទៅឲ្យពេទ្យរៀនវះកាត់ ។ រៀន*អាណាតូមី* ឬ យ៉ាងម៉េច? សំខាន់ គឺយកទៅរៀន*អាណាតូមី* ដូច្នេះគ្នាស្លាប់ហើយ ត្រូវស្លាប់ ។ នេះខ្ញុំគ្រាន់តែប៉ាន់ប្រមាណបានបែបនេះ ។ ខ្ញុំសូមចប់ប៉ុណ្ណេះ ។

**ស៖** តើលោកអាចពន្យល់ប្រាប់យើងខ្ញុំបានទេ ថាហេតុអ្វីបានជាអ្នកហ្នឹង គាត់នៅមានជីវិត? អ្នកទោសហ្នឹង ហើយក្រោយមកត្រូវបានសម្លាប់ ដើម្បីឲ្យទៅសិក្សា*អាណាតូមី*នោះ តើជារៀងរាល់ថ្ងៃនោះ ពីព្រោះអី គឺមានអ្នកទោសដែលត្រូវស្លាប់រៀងរាល់ថ្ងៃ ហេតុអ្វីមិនយកអ្នកទោសដែលស្លាប់ហើយនោះទៅសិក្សា*អាណាតូមី*ទៅ?

[១៦:១០:៣៣]

**ឆ៖** សូមបញ្ជាក់ថា ការយកទៅរៀនវះកាត់នេះ គេធ្វើដើម្បីគ្រាន់តែរៀន*អាណាតូមី* ប៉ុននុ៎ង ។ គេយកមនុស្សរស់ទៅធ្វើ ហើយជាមួយនិងពេទ្យដែលទើបនឹងរៀនទៅទៀត ។ បើតាមខ្ញុំដឹងមកពេទ្យជើងចាស់ សុីវិស្បាង ជើងចាស់ៗ ដូចយ៉ាង ដុកទ័រ ជួន ជឿន គាត់ចូលលុយគ្នាទិញខ្មោចអណ្តែតទឹកយកទៅលាក់ទុករៀន*អាណាតូមី* ។ យកខ្មោចអណ្តែតទឹកទៅរៀនវះកាត់ ក៏ត្រូវច្បាប់ហាមឃាត់រួចទៅហើយ នេះសម្រាប់ប្រទេសនីតិរដ្ឋ នៅក្នុងប្រទេសនីតិរដ្ឋ ។ ហើយកម្ពុជាប្រជាធិបតេយ្យ បានអំណាចពេញបន្ទុកភ្លាម យកមនុស្សរស់ទៅរៀន*អាណាតូមី* ។ ការបូមឈាមក៏ដោយ នៅក្នុងប្រទេសនីតិរដ្ឋគេមានបូមដែរ ក៏ប៉ុន្តែគេបូមដោយចំនួនតិច ហើយសាមីខ្លួនស្ម័គ្រចិត្ត ហើយមានថែមរបបទៅក្រោយពីបូមឈាមហ្នឹង ជូនសាមីខ្លួនទៅទៀត ។ នេះ គឺបូមៗយកទាំងអស់ ឲ្យគ្នាស្លាប់ ។

សរុបមក អ្នកបូមឈាមក៏ស្លាប់ អ្នកគេយកទៅរៀន*អាណាតូមី* ក៏ស្លាប់ ។ ឧក្រិដ្ឋកម្មនេះវាចំហហើយឃោរឃៅ ។ ពេលនោះខ្ញុំមើលឃើញ មិនមែនមើលមិនឃើញទេ មើលឃើញតែមិនដឹងធ្វើម៉េច។

បើនិយាយគេថាយើងអត់ជំហរវណ្ណៈ គិតអាយុជីវិតខ្លាំងជាងអាយុជីវិតយុទ្ធជន ។ នេះហើយខ្ញុំសូមរាយការណ៍ជូនប៉ុណ្ណេះ ។

**ស៖** លោកក៏បាននិយាយផងដែរអំពីប្រតិបត្តិការខាងផ្នែកពេទ្យ អំពីការផ្តល់ឱសថដែល អ៊ំទួន បានផ្តល់ឲ្យលោក ហើយលោកបានចែកថ្នាំហ្នឹង ទៅឲ្យអ្នកទោសមួយចំនួនក្នុងអំឡុងពេលប៉ុន្មានថ្ងៃនោះ ។ តើអ្វីទៅដែលកើតមកជាឥទ្ធិពលពីការសាកពិសោធថ្នាំអស់ទាំងនុ៎ង? តើអ្នកទោសដែលផឹកថ្នាំគេឈឺ ហើយគេស្លាប់ ឬក៏យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ពេលនោះខ្ញុំពិតជាបានប្តូរម្សៅថ្នាំនុ៎ង ដោយចាក់ម្សៅថ្នាំនុ៎ងចោល ហើយ *បារ៉ាសេតាម៉ុល* ទៅក្នុង *កាប់ស៊ុល* ជំនួសវិញ ។ ដោយគ្រាប់ថ្នាំហ្នឹង វាជាប្រភេទ *កាប់ស៊ុល* ខ្ញុំដកវាចេញទៅចាក់ម្សៅចាស់ចោល ហើយខ្ញុំជូតនឹងសំឡីឲ្យស្អាតអាក្នុង *កាប់ស៊ុល* ហ្នឹងទៅ ហើយខ្ញុំដាក់ម្សៅ *បារ៉ាសេតាម៉ុល* ជំនួស ។ ខ្ញុំធ្វើនេះស្ងាត់មិនឲ្យអ្នកណាដឹងទេ សូម្បីតែប្រពន្ធក៏អត់ដឹងដែរ ។ ប្រពន្ធខ្ញុំៗ សូម្បីតែប្រពន្ធខ្ញុំក៏អត់ដឹងដែរ ។ ដូច្នេះ គ្រោះថ្នាក់អំពីថ្នាំនេះអត់មានទេ ក៏ប៉ុន្តែអ្នកណាក៏មើលឃើញដែរ ថាខ្ញុំពិសោធថ្នាំផ្ទាល់ជាមួយជនរងគ្រោះ ។ ជនរងគ្រោះខ្លួនគេដែលមកបួននាក់ ឬបីនាក់នុ៎ង គេដឹងថាខ្ញុំពិសោធថ្នាំទៅលើខ្លួនគេ ។ ដូច្នេះ គេភ័យ ជីវិតគេផុតដង្ហើមអង្កាល់? កូនចៅខ្ញុំនៅស-២១ ថា “អុញ! បងពិសោធថ្នាំលើអ្នកទោសខ្លួនឯងហើយ ដែងឯងហ្នឹង!” ។ ដូច្នេះ ឧក្រិដ្ឋកម្មវានៅត្រង់ហ្នឹង ឧក្រិដ្ឋនៅត្រង់អ្នកណា គេមើលមកក៏ឃើញរូបភាពហ្នឹង ក៏ប៉ុន្តែជីវិតគ្នាវាអត់ស្លាប់ទេ ។ សូមគោរពរាយការណ៍ជូនលោកចៅក្រមប៉ុណ្ណេះ ។

[១៦:១៩:២៥]

**ស៖** តើ អ៊ំទួន និយាយអ្វីខ្លះប្រាប់លោកទៅ? តើអ្វីទៅជាឥទ្ធិពលនៃថ្នាំដែលត្រូវពិសោធនោះ តើឥទ្ធិពលនៃថ្នាំយ៉ាងម៉េចទៅដែលនឹងអាចធ្វើឲ្យអ្នកទោសស្លាប់ឬក៏យ៉ាងម៉េច? ហើយអ៊ំទួន ហ្នឹង គាត់និយាយថាម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! មុននឹងគាត់ឲ្យថ្នាំនេះមក វាចម្លើយទៅពីស-២១ ។ ចម្លើយៗឆ្លើយថា មនុស្សម្នាក់នុ៎ង សាមីខ្លួនគាត់នុ៎ងមានថ្នាំពុលសម្រាប់ដាក់បំពុលបងប៉ុល ។ ប៉ុល ពត ហ្នឹង សម្រាប់ដាក់បំពុលប៉ុល ពត ។ ដូច្នេះហើយ ពូនួន គាត់ឲ្យគេទៅយកថ្នាំ គាត់បញ្ជាខ្លួនគាត់អី តែគាត់ឯណោះទេ ទេគាត់បញ្ជាហ្នឹង ខ្ញុំអត់ឃើញទេ ។ ប៉ុន្តែ ខ្ញុំសន្និដ្ឋាន វិភាគអ៊ីចឹង ។ ដល់ពេលគាត់ហៅ

ខ្ញុំទៅធ្វើការ គាត់ផ្ទាំមក គាត់ខ្ចប់ក្រដាស់សៀវភៅសរសេរហ្នឹង ថ្នាំហ្នឹងប្រហែលជាដប់ពីរគ្រាប់ ឬប៉ុន្មានគ្រាប់ទេ ជាងដប់គ្រាប់ ។ ដូច្នេះ គាត់ឲ្យមកខ្ញុំ គ្រាប់ប្រាប់ថា មិត្តឯងធ្វើខ្លួនណ៎ា កុំឲ្យអ្នកណាដឹង ។ ហើយអាថ្នាំហ្នឹង អានោះវាសារភាពហ្នឹង ដែលមិត្តឲ្យសេចក្ដីសារភាពមកខ្ញុំ ។ ដូច្នេះ ទាំងគាត់ទាំងខ្ញុំនៅសង្ស័យថា តើថ្នាំនេះជាថ្នាំពុលមែន ឬមិនមែន? ដល់ខ្ញុំយកមកធ្វើ ខ្ញុំបំបាត់អាលទ្ធភាពពុលអស់ទៅ ខ្ញុំទុកអាលទ្ធភាពជា ។ ហើយដល់ថ្ងៃក្រោយមក ខ្ញុំទៅជួយធ្វើការហ្នឹងគាត់ គាត់ថាម៉េចថ្នាំហ្នឹង? ខ្ញុំថាដូចមិនឃើញអីទេបង គាត់ធ្វើស្មឿក ។ ដូច្នេះ រឿងរ៉ាវហ្នឹង វាឆ្លងកាត់ទៅហ្នឹង វាមានសភាពបែបនេះ សូមរាយការណ៍ជូនលោកចៅក្រមប៉ុណ្ណេះ ។

**ស៖** ដូច្នេះ ប្រសិនបើខ្ញុំយល់បានត្រឹមត្រូវនោះ លោកបានជួយសង្គ្រោះជីវិតអ្នកទោស ដែលជាធម្មតាអ្នកទាំងអស់នោះត្រូវបានគេយកមកធ្វើការសាកល្បងថ្នាំ ដែលមានជាតិពុល ដោយសារតែនេះគឺជាការបង្ហាញទៅលើ ដូច្នេះលោកបានសង្គ្រោះជីវិតអ្នកទាំងអស់នោះ ហើយលោកបានរៀបរាប់ថាអ្នកទោសទាំងអស់នោះ គឺអត់ស្លាប់ទេ ។ អ៊ីចឹងតើមានអ្វីកើតឡើងចំពោះពួកគេ ក្រោយមក តើពួកគេនៅរស់ ឬក៏ពួកគេត្រូវបានគេកម្ទេចចោល?

**ឆ៖** លោកចៅក្រមជាទីគោរព! អ្នកដែលចូលទៅ ស-២១ គ្មានអ្នកណារួចជីវិតទេ ។ តែគ្នាវាស្លាប់តាមដំណើរអ្នកដែលត្រូវចាប់មកស-២១ មិនមែនស្លាប់ដោយថ្នាំពុល ។

**ស៖** ខ្ញុំហាក់ដូចជាមិនយល់ច្បាស់សោះទៅលើចំណុចនេះ ។ អ៊ីចឹងគឺថា បញ្ហានេះមិនសូវធ្ងន់ធ្ងរដូច្នេះ អ្នកទាំងអស់នោះ ត្រូវបានគេកម្ទេចចោលដោយសារដំណើរការចូលមកស-២១ ។ ឧក្រិដ្ឋកម្មនោះ គឺវាមានលក្ខណៈធ្ងន់ធ្ងរ មិនមែនជាជនរងគ្រោះដោយថ្នាំពុលនោះទេ ។ ខ្ញុំហាក់ដូចជាមិនសូវយល់នូវអ្វីដែលលើកឡើងនៅទីនេះ ។ ទោះបីជាចំណុចនេះ គឺមិនមានអ្នកណាដឹងទេ ហើយលោកបាននិយាយថា ប្រពន្ធលោកក៏មិនដឹងទៅលើបញ្ហានេះផងដែរ ។ លោកអាចពន្យល់ទេហេតុអ្វីបានជាលោកសង្គ្រោះអ្នកទាំងអស់នោះ? ហើយតើមានអ្វីកើតឡើងនៅថ្ងៃនោះ? លោកមានអារម្មណ៍យ៉ាងម៉េចនៅថ្ងៃនោះ បានជាជួយសង្គ្រោះដូច្នេះ?

[១៦:២៤:៥១]

**ឆ៖** លោកចៅក្រមជាទីគោរព! បើសិនជាខ្ញុំយកថ្នាំពិត ដែលពូនួន ឲ្យមក យកទៅដាក់ឲ្យជនរងគ្រោះ ។ បើគ្នានោះស្លាប់ទៅ គឺដៃខ្ញុំនេះទៅសម្លាប់គេដោយផ្ទាល់ ។ វាខុសប៉ុណ្ណឹងឯង ដែលខ្ញុំចៀសមិនឲ្យដៃខ្ញុំទៅសម្លាប់គេដោយផ្ទាល់ ។

**ស៖** ខ្ញុំអត់មានសំណួរបន្តទៀតទេ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វីលៀម ស្មីត៖**

អរគុណលោកប្រធាន ។ ទាក់ទងទៅនឹងនីតិវិធីរបស់យើងទៅលើការអនុវត្តការងាររបស់យើង ដែលថា ការតាំងសំណួររបស់សហព្រះរាជអាជ្ញា ឬក៏ដើមបណ្តឹងរដ្ឋប្បវេណី អាចចាប់ផ្តើមបន្ទាប់ពីថ្ងៃស្អែកដែរឬទេ? គឺខ្ញុំគិតថា លោក លោកស្រីចៅក្រម គួរតែចេញសម្រេចនៅក្នុងថ្ងៃនេះ ទាក់ទងទៅនឹងការរៀបចំ និងវិធីសាស្ត្រផ្សេងៗ ដើម្បីឲ្យយើងធ្វើការរៀបចំការងាររបស់យើង ទាក់ទងទៅនឹងការតាំងសំណួរទៅតាមការវិភាគរបស់លោកចៅក្រម ។ យើងសូមអរគុណ ចំពោះការធ្វើដូច្នេះរបស់លោកប្រធាន ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:២៧:២៦]

**ប្រធានអង្គជំនុំ៖**

ខ្ញុំបានជម្រាបទៅភាគី កាលពីព្រឹកមិញហើយ ដូចជាច្បាស់លាស់ហើយថា អង្គហេតុដែលយើងធ្វើ គឺយើងប្រកាន់ជំហរដដែល គឺអង្គហេតុនៃប្រតិបត្តិការស-២១ រួចទាំងជើងឯក យើងធ្វើតែមួយទេ ហើយស-២៤ ឬក៏ហៅថាព្រៃ-ស នោះ យើងធ្វើដោយឡែក ។ នេះយើងនៅប្រកាន់ជំហរដដែល ។ បញ្ហាទីពីរ គឺយើងបានប្រាប់ជម្រាបពីព្រឹកមិញថា អង្គហេតុដែលយើងធ្វើប្រតិបត្តិការ ស-២១ ជើងឯកនេះ អង្គជំនុំជម្រះប្រឹងប្រែងធ្វើទៅតាមកាលពេលវេលា ដែលប្រឹងប្រែងនេះ ប្រហែលជាចប់នៅថ្ងៃស្អែក ។ ហើយដូច្នេះទេ គឺផែនការនៃកាលវិភាគសម្រាប់ធ្វើសវនាការដេញដោលលើអង្គហេតុទាំងនេះ ភាគីដែលត្រូវចាប់ផ្តើមពីតំណាងសហព្រះរាជអាជ្ញាទៅនោះ ខ្ញុំគិតថា ថ្ងៃច័ន្ទសប្តាហ៍ក្រោយ នឹងត្រូវធ្វើហើយ ។ ដូច្នេះ អត់មានអីប្រែប្រួលទេ ។ ខ្ញុំសូមជូនដំណឹងព័ត៌មានប៉ុណ្ណឹង ។

សាជាថ្មីម្តងទៀត គ្រាន់តែបញ្ជាក់ឡើងវិញ ដោយសារហេតុផលថា នៅថ្ងៃព្រហស្បតិ៍នោះ ខានស្អែកនេះ យើងមិនមានធ្វើសវនាការទេ ដោយហេតុថា ថ្ងៃនោះគឺចំថ្ងៃឈប់សម្រាកបុណ្យជាតិ អ៊ីចឹងសប្តាហ៍នេះ យើងធ្វើតែបីថ្ងៃទេ រួមទាំងស្អែកផង ។ ហើយឯចំណែកសវនាការបន្តនោះ គឺបន្ទាប់ពីថ្ងៃស្អែក គឺយើងនឹងបន្តទៅសប្តាហ៍ក្រោយ ថ្ងៃច័ន្ទសប្តាហ៍ក្រោយ ដែលនឹងប្រគល់វេទិកានេះជូនទៅ

តំណាងសហព្រះរាជអាជ្ញា ហើយនិងតាមលំដាប់លំដោយ គឺភាគីដែលត្រូវចូលរួមក្នុងការសួរដេញដោលនេះ ។

អង្គជំនុំជម្រះប្រកាសផ្អាកដំណើរសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ហើយសវនាការនឹងលើកបន្តទៅថ្ងៃស្អែកចាប់ពីវេលាម៉ោងប្រាំបួនព្រឹក ។ ដូច្នេះ សូមអញ្ជើញភាគី អញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះឲ្យបានតាមពេលកំណត់ ។ អនុរក្សមន្ទីរឃុំឃាំង សូមនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនេះ ឲ្យបានមុនម៉ោងប្រាំបួនព្រឹកស្អែកមុនពេលកំណត់ ៕

*[សវនាការផ្អាកនៅម៉ោង១៦:៣០នាទី]*